លេខពិសេស ២០២៥

# ព្រឹត្តិបត្រគយ

## ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៤

តុលា-ធ្នូ ២០២៥

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
















# អារម្ភកថា

ក្នុងត្រីមាស៤ ឆ្នាំ២០២៥ កន្លងទៅនេះ កម្ពុជាបានប្រឈមមុខនឹងស្ថានការណ៍ដ៏ធ្ងន់ធ្ងរបណ្តាលមកពីសកម្មភាពឈ្លានពានរបស់ប្រទេសថៃ ដែលបានបើកការវាយប្រហារដោយសព្វាវុធធុនធ្ងន់គ្រប់ប្រភេទលើទីតាំងឈរជើងរបស់កម្ពុជាតាមតំបន់ព្រំដែន និងការទម្លាក់គ្រាប់បែកចូលក្នុងដែនអធិបតេយ្យជាតិកម្ពុជាជាច្រើនកន្លែង ដែលមានចម្ងាយជ្រៅហួសព្រំដែនរហូតដល់ជាង៩០គីឡូម៉ែត្រ។ ស្ថានការណ៍នេះ បានបង្កឱ្យមានការបាត់បង់ជីវិត ការរងរបួសដល់ប្រជាពលរដ្ឋស៊ីវិលមួយចំនួន និងការខូចខាតផ្ទះសម្បែង ទ្រព្យសម្បត្តិរបស់ពលរដ្ឋកម្ពុជា ព្រមទាំងការខូចខាតហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងវប្បធម៌ជាច្រើនកន្លែង។ ការឈ្លានពានដ៏គឃ្លើនរបស់យោធាថៃចូលដែនអធិបតេយ្យភាពកម្ពុជាបានធ្វើឱ្យប្រជាពលរដ្ឋ រួមទាំងសិស្សានុសិស្ស មនុស្សចាស់ និងកុមារ ត្រូវបង្ខំភៀសខ្លួនទៅកាន់ទីតាំងសុវត្ថិភាពជាបណ្តោះអាសន្ន។ មិនតែប៉ុណ្ណោះ សកម្មភាពប្រតិបត្តិការរបស់អង្គភាពគយនិងរដ្ឋាករកម្ពុជានៅតាមច្រកព្រំដែនគោកជាប់នឹងប្រទេសថៃត្រូវបានផ្អាកជាបណ្តោះអាសន្ន ហើយអគាររដ្ឋបាលនិងកន្លែងធ្វើការមួយចំនួនក៏រងការខូចខាតផងដែរ។

ទោះបីជួបប្រទះនឹងបញ្ហាប្រឈមដ៏លំបាកទាំងនេះក្តី ក្នុងឆ្នាំ២០២៥នេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានបន្តអនុវត្តភារកិច្ច ដោយការប្តេជ្ញានិងការទទួលខុសត្រូវខ្ពស់ ដើម្បីធានាការប្រមូលចំណូលជូនជាតិសម្រេចបានរហូតដល់ ១២៤ ភាគរយ នៃផែនការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ដែលជាលទ្ធផលដ៏ល្អប្រសើរគួរឱ្យកត់សម្គាល់។ ក្រៅពីលទ្ធផលចំណូល **អគរ** សម្រេចបានលទ្ធផលគួរជាទីមោទនៈ ដែលមានរៀបរាប់ជូនលម្អិតក្នុងព្រឹត្តិបត្រគយលេខពិសេសនេះ រួមមាន ការបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ ការបន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងធនធានមនុស្ស ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធលើការងារគយ ទាំងថ្នាក់ជាតិនិងអន្តរជាតិ។ ក្រៅពីលទ្ធផលការងារខាងលើ សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចូលរួមយ៉ាងសកម្មលើការងារមនុស្សធម៌-សប្បុរសធម៌ ជាពិសេសក្នុងការកៀរគរ និងនាំយកជំនួយចែកជូនដល់វីរកងទ័ពជាតិ វីរនគរបាលជាតិនៅសមរភូមិទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់ ព្រមទាំងជូនដល់ប្រជាពលរដ្ឋដែលកំពុងភៀសសឹកនៅជំរំជនភៀសសឹកខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងនៅទីដាច់ស្រយាលនានាផងដែរ។

លទ្ធផលការងារទាំងឡាយដែល **អគរ** សម្រេចបាននេះ អាស្រ័យលើការខិតខំអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីគយនិងរដ្ឋាករនៅទូទាំងប្រទេស ដែលបានបំពេញការងារប្រកបដោយស្មារតីបុរេសកម្មនិងទទួលខុសត្រូវខ្ពស់។ ខ្ញុំសូមយកឱកាសនេះលើកទឹកចិត្តដល់ថ្នាក់ដឹកនាំនិងមន្ត្រីគយគ្រប់ជាន់ថ្នាក់ បន្តលើកតម្កើង និងរួមគ្នាប្រឹងប្រែងកសាងស្ថាប័នគយឱ្យកាន់តែរីកចម្រើនធំធាត់ ដើម្បីបំពេញតួនាទី និងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ប្រកបដោយជំនាញវិជ្ជាជីវៈ សំដៅធានាបានប្រសិទ្ធភាពក្នុងការប្រមូលចំណូល និងធានាបាននូវបរិយាកាសធុរកិច្ចឱ្យកាន់តែល្អប្រសើរ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រគយនេះនឹងបន្តផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់សាធារណជន ក៏ដូចជា សិស្ស និស្សិត អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធ ដើម្បីទទួលបាននូវចំណេះដឹងកាន់តែទូលំទូលាយលើវិស័យគយ និងសមិទ្ធផលការងារដែលសម្រេចបានរបស់ **អគរ**។

ឆ្លៀតឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការនៃ **អគរ** និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ចកក្តីភាពដ៏ស្មោះស្ម័គ្របំផុតចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែផ្ដល់ការគាំទ្រ ណែនាំ និងយកចិត្តទុកដាក់ខ្ពស់ចំពោះ **អគរ** ដែលធ្វើឱ្យរដ្ឋបាលគយកម្ពុជា អាចសម្រេចបានសមិទ្ធផលនិងស្នាដៃជាប្រវត្តិសាស្ត្រថ្មីៗជាច្រើននាពេលកន្លងមកនេះ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំ **អគរ** ខ្ញុំសូមស្វាគមន៍នូវរាល់មតិយោបល់រិះគន់ស្ថាបនាពីបណ្ដាប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ដើម្បីបន្តកែលម្អព្រឹត្តិបត្រគយលេខក្រោយៗទៀតឱ្យកាន់តែល្អប្រសើរឡើង។ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គលគ្រប់ប្រការ ជូនដល់ប្រិយមិត្តអ្នកអានទាំងអស់ ទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃពុធ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម




**ក្រុមការងារចងក្រង**
**ព្រឹត្តិបត្រគយ**

ឯកឧត្តមបណ្ឌិត **គុណ ញឹម**
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

| | |
|---|---|
| លោក | ផា អេងវ៉េង |
| លោក | សែ សុយន |
| លោក | ចាន់ សុភាព |
| លោកបណ្ឌិត | ឈេន រឿន |
| លោក | វ៉ូ វណ្ណា |
| លោកបណ្ឌិត | សង់ ស៊ីណារិទ្យ |
| លោក | ទូច លីដែល |
| លោក | នូ ស៊ីថា |
| លោក | ប៊ុន ជីវ |
| លោក | អន ស៊ីនួន |
| លោក | ហ៊ីវ ពុទ្ធិរិទ្ធ |
| លោក | ក្តូវ ណុច |
| លោក | សុខ សុដារ៉ា |
| លោកបណ្ឌិត | ហ៊ុល ប៊ុនថា |
| លោក | នង សុខុម |
| លោក | អ៊ុំ ច័ន្ទរតនា |
| លោក | សំ សុវណ្ណារិទ្ធិ |
| លោក | សំ កុសល |
| លោក | យូ ហេង |
| លោក | លី ប៊ុនសុង |
| លោក | មួង ដារ៉ា |
| លោក | ចាន់ សំបូរ |
| លោក | ហេង សំបូរ |
| លោក | ប្រាក់ ចាន់ធី |
| លោក | ឈួន ហៃ |
| លោក | លី សារឿន |
| លោក | ជាប សៅ |
| លោក | ថេង ម៉ុងហាក់ |
| លោក | អ៊ួន សុវណ្ណារ៉ា |
| លោក | យឹម វណ្ណៈ |
| លោក | ឈួន សោភា |
| លោក | លាង ហ៊ីន់ |
| លោក | ឡាង ថាវរៈ |
| លោក | លាង រតនា |
| លោក | គិម វណ្ណាត |
| លោក | ប៊ូ តង់ឡេង |


# មាតិកា
# Contents

ទំព័រ


**ផ្នែកទី១ ព្រឹត្តិការណ៍សំខាន់ៗ ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥** ........ ៥
- វេទិកាស្តីពី "ការវិនិយោគនិងការធ្វើពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក" ........ ៦
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង និងការិយាល័យគយនិងរដ្ឋាករបុសមននៃសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង ........ ១០
- វេទិកាគយកម្ពុជាលើកទី៣ ........ ១៣
- ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហការជំរុញការប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment) រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានិង ធនាគាររីង (ខេមបូឌា) ម.ក ........ ១៥
- ពិធីផ្សព្វផ្សាយអំពីសេវាកម្មពិនិត្យ និងព្យាបាលជំងឺរបស់មន្ទីរពេទ្យ Sunway Medical Centre និងសេវាកម្មធានារ៉ាប់រងរបស់ក្រុមហ៊ុន AIA ជូនដល់មន្ត្រីគយនិងរដ្ឋាករ ........ ១៨
- កិច្ចប្រជុំផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ........ ២០
- កិច្ចប្រជុំទ្វេភាគីគយព្រំដែនលើកទី៦ រវាងរដ្ឋបាលគយកម្ពុជា និងរដ្ឋបាលគយវៀតណាម ........ ២២
- ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និងអ្នកជំនាញការ EU GERMAN GATE, GIZ, GATF និងUNCTA ........ ២៤
- វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាគយ ជំនាន់ទី១២ និងការប្រឡងបញ្ចប់ ........ ២៦
- សារលិខិតជូនពរ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រី-បុគ្គលិកជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៦ ........ ២៨

**ផ្នែកទី២ ការយល់ដឹងអំពីនីតិវិធីគយ** ........ ៣០
- ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ ........ ៣១
- សិក្ខាសាលាផ្សព្វផ្សាយ "និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញ ទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក" ........ ៣៤
- សិក្ខាសាលាស្តីពី ការអនុវត្តយេនឌ័រនិងចម្រុះភាព ........ ៣៨
- វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ........ ៤០
- សេចក្តីប្រកាសព័ត៌មាន សិក្ខាសាលាស្តីពី "ការពង្រឹងពាណិជ្ជកម្មធានាសន្តិសុខកុងតឺន័រ និងខ្សែប្រវាក់ផ្គត់ផ្គង់" ........ ៤២
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ" ........ ៤៦
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងអនាគត" ........ ៤៨
- សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល "Training of Trainers" ........ ៥០
- សិក្ខាសាលាស្តីពី "ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ លើកទី៥" ........ ៥២

**ផ្នែកទី៣ លទ្ធផលការងារសម្រេចបានមួយចំនួនរបស់បណ្តានាយកដ្ឋាន និងអង្គភាពមូលដ្ឋាន** ........ ៥៤
- ការងារសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន ........ ៥៥
- ការងារគ្រប់គ្រងហិរញ្ញវត្ថុនិងបុគ្គលិក ........ ៥៨
- ការងារផែនការនិងបច្ចេកទេស ........ ៦១
- ការងាររដ្ឋាករ ........ ៦៤
- ការងាររបបគយ ........ ៦៦
- ការងារគ្រប់គ្រងតំបន់រួចពន្ធ ........ ៧១
- ការងារគ្រប់គ្រងការនាំចេញ ........ ៧៣
- ការងារគយនិងរដ្ឋាករផៃស្ងួត ........ ៧៦
- ការងារគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ........ ៧៨
- សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ........ ៨០
- សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង ........ ៨២
- សាខាគយនិងរដ្ឋាករខេត្តកណ្តាល ........ ៨៤
- សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ........ ៨៦
- សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ........ ៨៨
- សាខាគយនិងរដ្ឋាករខេត្តព្រៃវែង ........ ៩១
- សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ........ ៩៣
- សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ ........ ៩៤
- សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ ........ ៩៥
- ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់ ១ ........ ៩៦

**ផ្នែកទី៤ ការងារសង្គម** ........ ៩៨

# ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៤ ឆ្នាំ២០២៥

# ផ្នែកទី១
# ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី៤ ឆ្នាំ២០២៥

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចូលរួមនិងរៀបចំដូចខាងក្រោម៖**

- វេទិកាស្ដីពី "ការវិនិយោគនិងការធ្វើពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក"
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង និងការិយាល័យគយនិងរដ្ឋាករបុសមននៃសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង
- វេទិកាគយកម្ពុជាលើកទី៣
- ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហការជំរុញការប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment) រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងធនាគារ វីង (ខេមបូឌា) ម.ក
- ពិធីផ្សព្វផ្សាយអំពីសេវាកម្មពិនិត្យ និងព្យាបាលជំងឺរបស់មន្ទីរពេទ្យ Sunway Medical Centre និងសេវាកម្មធានារ៉ាប់រងរបស់ក្រុមហ៊ុន AIA ជូនដល់មន្ត្រីគយនិងរដ្ឋាករ
- កិច្ចប្រជុំផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា
- កិច្ចប្រជុំទ្វេភាគីគយព្រំដែនលើកទី៦ រវាងរដ្ឋបាលគយកម្ពុជា និងរដ្ឋបាលគយវៀតណាម
- ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និងអ្នកជំនាញការ EU GERMAN GATE, GIZ, GATF និងUNCTAD
- វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈជើងសាគយ ជំនាន់ទី១២ និងការប្រឡងបញ្ចប់
- សារលិខិតជូនពរ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រី-បុគ្គលិកជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៦

# វេទិកាស្តីពី "ការវិនិយោគនិងការធ្វើពាណិជ្ជកម្ម ជាមួយសហរដ្ឋអាមេរិក"

នាថ្ងៃព្រហស្បតិ៍ ១០ កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែតុលា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អ.គ.រ**) បានរៀបចំវេទិកាស្តីពី "ការវិនិយោគនិងការធ្វើពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក" នៅសាលាជាតិគយ ដើម្បីផ្សព្វផ្សាយអំពីច្បាប់និងបទប្បញ្ញត្តិជាធរមាន ដល់វិនិយោគិនក្នុងវិស័យឧស្សាហកម្មកែច្នៃនាំចេញផលិតផលទៅទីកាន់ទីផ្សារសហរដ្ឋអាម៉េរិក ។ វេទិកានេះ មានគោលបំណងផ្សព្វផ្សាយសក្តានុពលទីផ្សារសហរដ្ឋអាមេរិក និងការពង្រឹងអនុលោមភាពភាព ជាពិសេសលើវិធានដើមកំណើតទំនិញ នាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក។ អង្គវេទិកាបានប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (**ក.អ.ក**) និងជាប្រធានក្រុមការងារចំពោះកិច្ចសម្របសម្រួលទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគទ្វេភាគីកម្ពុជា-សហរដ្ឋអាមេរិក។ វេទិកានេះ មានការចូលរួមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (**ក.អ.ក**) សភាពាណិជ្ជកម្មកម្ពុជា អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម (**ក.ព.ណ**) ទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សភាពាណិជ្ជកម្មអាម៉េរិកប្រចាំកម្ពុជា (AmCham) សមាគមភស្តុភារកម្មកម្ពុជា (CLA) សមាគមផលិតគ្រឿងអេឡិចត្រូនិកនិងបច្ចេកវិទ្យាកម្ពុជា ជើងសាគយរួមជាមួយថ្នាក់ដឹកនាំនិងមន្ត្រីពីក្រសួង-ស្ថាប័នប្រមាណ ១០០ រូប និងវិស័យឯកជនជាតិ និងអន្តរជាតិប្រមាណ ២៤០ រូប សរុបប្រមាណ ៣៤០ រូប។

ក្នុងមតិស្វាគមន៍, អ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា បានថ្លែងអំណរគុណដល់ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលតែងតែគាំទ្រនិងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មនៅកម្ពុជា ។ ពាក់ព័ន្ធនឹងប្រធានបទនៃវេទិកាអ្នកឧកញ៉ាបានលើកឡើង ពីការប្រែប្រួលជាគន្លឹះនៃគោលការណ៍ពហុភាគីនិយម និងវិធានពាណិជ្ជកម្មអន្តរជាតិ ក្នុងបរិបទដែលកម្ពុជាកំពុងចរចាជាមួយសហរដ្ឋអាម៉េរិក វិស័យឯកជនត្រូវយកចិត្តទុកដាក់ និងសហការជាមួយក្រសួង-ស្ថាប័នរដ្ឋ ដើម្បីការពារកុំឱ្យមានអ្នកវិនិយោគ ឬអ្នកក្លែងបន្លំបទល្មើសផ្ទេរមធ្យោបាយដឹកជញ្ជូន (Transshipment frauds) និងការបន្លំដើមកំណើតទំនិញ ។

មានប្រសាសន៍ក្នុងពិធីបើកវេទិកា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានលើកអំពីវឌ្ឍនភាពនៃការចរចាពន្ធគយបដិការកម្ពុជា-អាម៉េរិក និងបានគូសបញ្ជាក់អំពីផលប៉ះពាល់នៃបទល្មើសផ្ទេរមធ្យោបាយដឹកជញ្ជូន (Transshipmentfrauds) ការបន្លំដើមកំណើតទំនិញដែលជាកង្វល់ និងបញ្ហាដែលលើកឡើងដោយសហរដ្ឋអាម៉េរិក ហើយអាចប៉ះពាល់ដល់ឧស្សាហកម្មផលិតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក។ ទន្ទឹមនេះ ឯកឧត្តមបានស្នើ **អ.គ.រ**, **ក.អ.ក**, និង **ក.ព.ណ** បន្តធ្វើការរួមគ្នាដោះស្រាយបញ្ហានិងសំណូមពររបស់វិស័យឯកជន រួមទាំងណែនាំឱ្យវិស័យឯកជនត្រូវគោរពច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ឯកឧត្តមបានលើកឡើងថា **កអក** បានធ្វើការយ៉ាងសកម្មក្នុងការទាក់ទាញវិនិយោគិនមកបណ្តាក់ទុននៅកម្ពុជាហើយការទាក់ទាញវិនិយោគជាការលំបាកមួយហើយ តែការថែរក្សាវិនិយោគិនដែលមានស្រាប់កាន់តែមានសារៈសំខាន់ហើយវិនិយោគិនដែលផលិតទំនិញនាំចេញក៏ត្រូវគោរពច្បាប់និងបទប្បញ្ញត្តិជាតិជាធរមាន រួមទាំងគោលការណ៍និងវិធាននានាដែលតម្រូវដោយប្រទេសនាំចូល ផងដែរ។

លោក **Casey Banett** ប្រធានសភាពាណិជ្ជកម្មអាម៉េរិកប្រចាំកម្ពុជា បានចូលរួមធ្វើបទបង្ហាញលើប្រធានបទ "American Trade and Investment in Cambodia Statusand Overview" ។ ក្នុងនោះលោកបានលើកឡើងអំពីតួលេខស្ថិតិពាណិជ្ជកម្មរវាងកម្ពុជា និង សរអ និង

វិស័យសេដ្ឋកិច្ចមួយចំនួន ដែលអ្នកវិនិយោគអាម៉េរិកកំពុងបណ្តាក់ទុននៅកម្ពុជា។ លោកបានលើកឡើងអំពីបញ្ហាប្រឈមមួយចំនួន ដែលកម្ពុជាត្រូវដោះស្រាយដើម្បីថែរក្សាទីផ្សារសហរដ្ឋអាម៉េរិក ជាពិសេសគឺត្រូវទប់ស្កាត់បទល្មើសផ្ទេរមធ្យោបាយដឹកជញ្ជូន ដែលបាតុភាពអសកម្មនេះ អាចធ្វើឱ្យកម្ពុជាប្រឈមហានិភ័យក្នុងការនាំចេញទំនិញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក (លោកបានលើកឡើងជាឧទាហរណ៍ករណីបន្ទះសូឡា)។ ទន្ទឹមនេះ លោក Casey Banett បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និង **អ.គ.វ** ជាសេនាធិការ បានអនុវត្តវិធានការបង្ការ និងទប់ស្កាត់បទល្មើសបន្លំដើមកំណើតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ដែលប្រការនេះបង្ហាញពីអភិក្រមបុរេសកម្ម និងឆន្ទៈច្បាស់លាស់របស់រាជរដ្ឋាភិបាលក្នុងទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក។

បន្ទាប់មកអង្គវេទិកាបានរៀបចំកិច្ចពិភាក្សា ដើម្បីឆ្លើយតបនឹងសំណួរ និងសំណូមពរដែលជាកង្វល់របស់វិស័យឯកជន ដោយមានវាគ្មិនកិត្តិយសមកពី **អ.គ.វ**, **ក.អ.ក**, **ក.ព.ណ** និងទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី។ សំណួរនិងសំណូមពរ ដែលបានលើកឡើង ត្រូវបានពន្យល់និងបំភ្លឺជូនយ៉ាងច្បាស់លាស់ដោយវាគ្មិនកិត្តិយស។

ថ្លែងក្នុងពិធីបិទអង្គវេទិកា ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានលើកឡើងពីសារៈសំខាន់នៃវេទិកានេះ ហើយបានរំលេចពីចំណុចគន្លឹះក្នុងសន្ទរកថាបើក របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** និងក្នុងបទអន្តរាគមន៍របស់វាគ្មិនកិត្តិយសនៃអង្គវេទិកា។ ឯកឧត្តមបណ្ឌិត បានសង្កត់ធ្ងន់ថា ដើម្បីរក្សាទីផ្សារសហរដ្ឋអាម៉េរិក ដែលស្រូបយកប្រមាណជា ៤០% នៃការនាំចេញសរុបរបស់កម្ពុជា ការអនុវត្តវិធានការបង្ការនិងទប់ស្កាត់បទល្មើសបន្លំដើមកំណើតទំនិញ ដែលជាកង្វល់និងបញ្ហាដែលបានលើកឡើងដោយសហរដ្ឋអាម៉េរិក គឺជាការងារសំខាន់ និងចាំបាច់បំផុត។ ថ្មីៗនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតក្រុមការងារចម្រុះដែលមានសមាសភាពពី **អ.គ.វ**, **ក.អ.ក**, **ក.ព.ណ** និងតំណាងទីប្រឹក្សាផ្ទាល់របស់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ដើម្បីអនុវត្តវិធានការនេះប្រកបដោយតម្លាភាពប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។ ម្យ៉ាងទៀតក្រុមការងារនេះត្រូវត្រៀមសហការជាមួយ U.S. Customs and Border Protection (CBP) ក្នុងករណី CBP ចុះអង្កេតដល់ទីតាំងរោងចក្ររបស់គម្រោងវិនិយោគណាមួយបើមានការសង្ស័យបន្លំដើមកំណើតទំនិញ។

ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានជម្រាបជូនអង្គវេទិកា ដូចខាងក្រោម៖

១. បន្តអនុវត្តដោយម៉ឺងម៉ាត់នូវវិធានការទប់ស្កាត់បទល្មើសបន្លំដើមកំណើតទំនិញ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ។

២. ក្រុមហ៊ុនវិនិយោគផលិតទំនិញនាំចេញទៅទីផ្សារអាម៉េរិកត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ជាពិសេសត្រូវអនុលោមតាមវិធានដើមកំណើតទំនិញដែលកំណត់ឬតម្រូវដោយប្រទេសនាំចូល ។

៣. បន្តរៀបចំវេទិកានេះ តាមពេលវេលាសមស្រប ដើម្បីជាយន្តការតាមដាន វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពនៃវឌ្ឍនភាព និងស្ថានភាពនៃការវិនិយោគ និងពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាម៉េរិក ។

ឯកឧត្តមបណ្ឌិត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់វាគ្មិនកិត្តិយសនិងសមាជិក/សមាជិកាអង្គវេទិកា ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងវេទិកាដ៏មានសារៈសំខាន់នេះ។












Forum on Investment and Trade with the United States


ស្តីពីការវិនិយោគនិងការធ្វើពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក
Forum on Investment and Trade with the United States





# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង និងការិយាល័យគយនិងរដ្ឋាករបុសមន នៃសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង

នាព្រឹក ថ្ងៃសុក្រ ១០កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង និងការិយាល័យគយនិងរដ្ឋាករបុសមន នៃសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង។

អគាររដ្ឋបាល អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង ត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ ក្នុងនោះមានអគាររដ្ឋបាល ទំហំ ២០ម៉ែត្រ x ២១ម៉ែត្រ កម្ពស់ ២ជាន់, អគារស្នាក់នៅនិងអាហារដ្ឋានសម្រាប់មន្ត្រីគយនិងរដ្ឋាករ ទំហំ ៧,៥ម៉ែត្រ x ២០,១ម៉ែត្រ កម្ពស់ ២ជាន់ និងហេដ្ឋារចនាសម្ព័ន្ធនានា មានជាអាទិ៍ ប៉ុស្តិ៍សន្តិសុខ, រោងម៉ាស៊ីនភ្លើង, ចំណតរថយន្ត, ទីសក្ការៈ, ដងទង់ជាតិ, បណ្តាញទឹកស្អាត, បណ្តាញអគ្គិសនី, ប្រព័ន្ធលូ, កែលម្អរបង, បំពាក់សម្ភារៈការិយាល័យនិងគ្រឿងសង្ហារឹម, ដំឡើងបង្គោលភ្លើងនិងអំពូលសឡា និងសួនច្បារ។

អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករបុសមន ត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ក្នុងនោះមាន អគាររដ្ឋបាល ទំហំ ២០ម៉ែត្រ x ២៣ម៉ែត្រ កម្ពស់ ២ជាន់, អគាររួមមានបន្ទប់ស្នាក់នៅនិងអាហារដ្ឋានសម្រាប់មន្ត្រីគយនិងរដ្ឋាករ ទំហំ ១៨ ម៉ែត្រ x ៦,៤ម៉ែត្រ និងហេដ្ឋារចនាសម្ព័ន្ធនានា មានជាអាទិ៍ ប៉ុស្តិ៍សន្តិសុខ, ឃ្លាំងទំនិញ, រោងម៉ាស៊ីនភ្លើង, ចំណតរថយន្ត, របង, បន្ទប់ទឹកសាធារណៈ, ខ្សែ, ទីសក្ការៈ, ជួសជុលអគារអ៊ិនតាក់, ដងទង់ជាតិ, បណ្តាញទឹកស្អាត, បណ្តាញអគ្គិសនី, ប្រព័ន្ធលូ, បំពាក់សម្ភារៈការិយាល័យនិងគ្រឿងសង្ហារឹម, ដំឡើងបង្គោលភ្លើងនិងអំពូលសឡា និងសួនច្បារ។

សមិទ្ធផលនេះ បង្ហាញឱ្យឃើញពីការគិតគូរខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័នតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបំពាក់មធ្យោបាយបំពេញការងារឱ្យបានសមស្រប ដើម្បីពង្រឹងសមត្ថភាពស្ថាប័នក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ និងការផ្តល់សេវាសាធារណៈឱ្យបានកាន់តែល្អប្រសើរ និងស្របតាមការអនុវត្តគោលដៅយុទ្ធសាស្ត្រទី៦ «សមត្ថភាពស្ថាប័ន» នៃយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ ឆ្នាំ២០២៤-២០២៨។

ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានណែនាំដល់ថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករប្រចាំការនៅការិយាល័យគយនិងរដ្ឋាករដូង និងការិយាល័យគយនិងរដ្ឋាករបុសមនទាំងអស់ ត្រូវខិតខំអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាពិសេស ការងារគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ នាំចូល ឬឆ្លងកាត់ ស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីគយ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាអគារនិងហេដ្ឋារចនាសម្ព័ន្ធនានាឱ្យបានល្អ ព្រមទាំងប្រើប្រាស់ទឹក និងអគ្គិសនីប្រកបដោយភាពសន្សំសំចៃ។















អបអរសាទរ
ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ

អបអរសាទរ
ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ


# វេទិកាគយកម្ពុជាលើកទី៣

នាព្រឹកថ្ងៃសុក្រ ៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលាជាតិគយ មានរៀបចំវេទិកាគយកម្ពុជាលើកទី៣ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានគណៈកម្មការសេម្របសម្រួលក្រុមការងារផ្នែកឯកជន សម្រាប់យន្តការវេទិការាជរដ្ឋាភិបាលផ្នែកឯកជន ព្រមទាំងមានវត្តមានចូលរួមពីសមាជិក-សមាជិកាសភាពាណិជ្ជកម្មកម្ពុជា, សមាគមធុរកិច្ច, ធុរជននាំចេញនាំចូល, មន្ត្រីគយនិងរដ្ឋាករ និងអ្នកសារព័ត៌មានមួយចំនួនផងដែរ។ វេទិកាគយកម្ពុជាលើកទី៣ នេះ ត្រូវបានរៀបចំឡើងក្នុងមូលបទ "រដ្ឋបាលគយក្នុងបរិបទបច្ចេកវិទ្យាឌីជីថល" ដែលមានគោលបំណងផ្សព្វផ្សាយអំពីវឌ្ឍនភាពនៃឌីជីថលូបនីយកម្មនីតិវិធីគយ និងការផ្តល់សេវាសាធារណៈដើម្បីបង្កើនកិច្ចសម្រួលពាណិជ្ជកម្ម អនុលោមភាព និងបរិយាកាសធុរកិច្ចនៅកម្ពុជា ក៏ដូចជាផ្តល់ឱកាសជជែកពិភាក្សា និងផ្តល់មតិលើការអនុវត្តជាក់ស្តែងផងដែរ។

ក្នុងមតិចំណាប់អារម្មណ៍ អ្នកឧកញ៉ា **គិត ម៉េង** បានគូសរំលេចពីកិច្ចសហការល្អរវាងសភាពាណិជ្ជកម្មកម្ពុជា និង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅក្នុងយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ដែលបានជួយលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធ្វើធុរកិច្ចនៅកម្ពុជាកាន់តែប្រសើរពីមួយពេលទៅមួយពេល។ សម្រាប់វេទិកាគយកម្ពុជាលើកទី៣ នេះ អ្នកឧកញ៉ា បានកត់សម្គាល់ពីភាពចាំបាច់ និងសារៈប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថលសម្រាប់ជំរុញកំណើន និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច ដែលទាមទារឱ្យទាំងផ្នែកឯកជន និងសាធារណៈត្រូវចាប់យកបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងស្ថាប័នខ្លួន និង ជាពិសេសបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រេចបានក្នុងការកែទម្រង់និងទំនើបកម្មស្ថាប័ន។ ការធ្វើឌីជីថលូបនីយកម្មនេះបញ្ជាក់ពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែទម្រង់ឈានទៅជានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងការអនុវត្តតាមស្តង់ដាអន្តរជាតិ ក៏ដូចជាដើម្បីបង្កើនល្បឿននៃការបញ្ចេញទំនិញពីគយ ជំរុញកិច្ចសម្រួលពាណិជ្ជកម្ម និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងបរិបទសេដ្ឋកិច្ចឌីជីថលផងដែរ។

ជាមួយនឹងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះអង្គវេទិកា, ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានបញ្ជាក់ពីសារៈសំខាន់នៃវេទិកាគយកម្ពុជា ដែលជាយន្តការបញ្ជ្រាបការយល់ដឹងបន្ថែមអំពីនីតិវិធីគយ និងបង្កើនកិច្ចសហការរវាងរដ្ឋបាលគយនិងផ្នែកឯកជន ដើម្បីរួមគ្នាលើកស្ទួយវប្បធម៌សារពើពន្ធនិងកិច្ចសម្រួលពាណិជ្ជកម្មនៅកម្ពុជា។ បន្ថែមលើនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូបានសង្កត់ធ្ងន់ថា ទិសដៅក្លាយជារដ្ឋបាលគយឌីជីថល គឺជាការចាំបាច់ដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបាននិងកំពុងជំរុញអនុវត្តឱ្យបានជោគជ័យ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពនិងភាពជឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធ។ ទិសដៅនេះមានសង្គតិភាពជាមួយ "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" របស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់ ឈ្លាសវៃ និងប៉ិនប្រសប់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់អាទិភាពដល់ "មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា" ជាពិសេសបច្ចេកវិទ្យាឌីជីថល ជាសសរស្តម្ភនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងឱកាសនោះដែរ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ ក៏បានសង្ខេបអំពីវឌ្ឍនភាពសំខាន់ៗរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានាពេលថ្មីៗនេះ លើការធ្វើបរិវត្តកម្មឌីជីថលនីតិវិធីគយ និងការផ្តល់សេវាសាធារណៈ និងការអនុវត្តវិធានការចំនួន ១៤ចំណុច ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ ដែលសម្តេចធិបតីនាយករដ្ឋមន្ត្រី បានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩។

វេទិកាគយកម្ពុជាលើកទី៣ បានប្រព្រឹត្តទៅដោយមានការធ្វើបទបង្ហាញរបស់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្ដីពីបច្ចុប្បន្នភាពនីតិវិធីគយក្នុងបរិបទឌីជីថល និងមានកិច្ចពិភាក្សារវាងវាគ្មិនមកពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងផ្នែកឯកជន លើប្រធានបទអំពីដំណើរការនីតិវិធីនាំចូល-នាំចេញតាមថ្នាលប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងមានការលើកឡើងជាសំណួរនិងសំណូមពរពីសមាជិកអង្គវេទិកា លើការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈកិច្ចសម្រួលពាណិជ្ជកម្មការបំពេញបែបបទគយ ការពង្រឹងអនុលោមភាព និងប្រតិបត្តិការគយផ្សេងទៀតជាដើម៕





















# ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្ដីពី កិច្ចសហការជំរុញការប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយ អេឡិចត្រូនិក (e-Payment) រវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង ធនាគារ វីង (ខេមបូឌា) ម.ក

នារសៀលថ្ងៃសុក្រ ១៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ នៅទីស្នាក់ការកណ្ដាលធនាគារ វីង មានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីកិច្ចសហការជំរុញការប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment) រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង ធនាគារវីង (ខេមបូឌា) ម.ក ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អ្នកឧកញ៉ា **គិត ម៉េង** ប្រធានក្រុមប្រឹក្សាភិបាលធនាគារ វីង និងជាអគ្គនាយកប្រតិបត្តិក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប ព្រមទាំងវត្តមានចូលរួមពីសមាគមធុរកិច្ច, ថ្នាក់ដឹកនាំធនាគារ វីង មន្ត្រីគយនិងរដ្ឋាករ និងភ្ញៀវកិត្តិយជាច្រើនរូបផងដែរ។

ថ្លែងក្នុងឱកាសនោះ អ្នកឧកញ៉ា **គិត ម៉េង** បានបញ្ជាក់ពីការចូលរួមចំណែករបស់ធនាគារ វីង ក្នុងការអភិវឌ្ឍប្រទេសជាតិ តាមរយៈការសហការជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីធ្វើឱ្យការបង់ពន្ធនិងអាករចូលថវិកាជាតិ អាចដំណើរការប្រកដោយប្រសិទ្ធភាព។ការចុះអនុស្សរណៈនៃការយោគយល់គ្នានាឱកាសនេះគឺជាការបោះជំហានថ្មី ដើម្បីជួយសម្រួលឱ្យប្រតិបត្តិការបង់ពន្ធ-អាកររបស់ធុរជនកាន់តែមានភាពងាយស្រួលរហ័ស និងមានសុវត្ថិភាពបន្ថែមទៀត។ ជាមួយគ្នានេះផងដែរ ដើម្បីចូលរួមគាំទ្រដល់បរិយាកាសធុរកិច្ចនៅកម្ពុជា អ្នកឧកញ៉ាក៏បានប្រកាសអំពីការផ្តល់នូវ "កម្រិតឥណទាន"ដែលមានបរិមាណរហូតដល់ ២០០លានដុល្លារអាម៉េរិក មិនគិតអត្រាការប្រាក់រហូតដល់ទៅ ៥ថ្ងៃ ដល់ធុរជនដែលបង់ប្រាក់ពន្ធ-អាករ ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិកជាមួយធនាគារ វីង។

ថ្លែងមតិចំណាប់អារម្មណ៍នៅក្នុងកម្មវិធីនេះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានគូសរំលេចពីការខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការចាប់យកប្រព័ន្ធបច្ចេកវិទ្យាដើម្បីគាំទ្រដល់កិច្ចប្រតិបត្តិការរបស់រដ្ឋបាលគយ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកឯកជន ស្របតាមចក្ខុវិស័យរបស់ខ្លួនក្នុងការប្រែក្លាយស្ថាប័នគយឱ្យកាន់តែទំនើប សំដៅចូលរួមលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មក៏ដូចជាបរិយាកាសធុរកិច្ចនៅកម្ពុជា។ ជាក់ស្ដែង មុខងារ e-Payment ដែលត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ២០១៨ មក ត្រូវបានបន្តពង្រីកជាបន្តបន្ទាប់ ដែលគិតមកទល់ពេលនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានធនាគារជាដៃគូចំនួន ១០ស្ថាប័ន ដែលចូលរួមអនុវត្តមុខងារនេះ។ មុខងារ e-Payment អនុញ្ញាតឱ្យធុរជនអាចបង់ពន្ធដោយមានភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា ប្រកបដោយសុវត្ថិភាពខ្ពស់ ក៏ដូចជាជៀសវាងការភាន់ច្រឡំចំនួនប្រាក់ពន្ធ និងលេខគណនីធនាគារដោយថាហេតុ។ ឯកឧត្តមបណ្ឌិត ក៏បានកោតសរសើរនិងវាយតម្លៃខ្ពស់ ព្រមទាំងបានថ្លែងអំណរគុណដល់ធនាគារ វីង ដែលមានគំនិតផ្តួចផ្តើមឱ្យមានឥណទានជូនដល់ធុរជនសម្រាប់បង់ប្រាក់ពន្ធ-អាករ ដែលប្រមូលដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងការសហការរៀបចំអនុស្សរណៈនៃការយោគយល់គ្នាជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីជំរុញការប្រើប្រាស់ e-Payment ឱ្យកាន់តែទូលំទូលាយ។

តាមរយៈអនុស្សរណៈនៃការយោគយល់គ្នានេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង ធនាគារ វីង នឹងលើកកម្ពស់កិច្ចសហការក្នុងការជំរុញការប្រើប្រាស់មុខងារ e-Payment ដល់ធុរជន, សហការចែករំលែកចំណេះដឹង

និងបទពិសោធពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសុវត្ថិភាពប្រព័ន្ធ, ក៏ដូចជាបង្កើតឱ្យមានក្រុមការងារបច្ចេកទេសដើម្បីគាំទ្រ និងដោះស្រាយបញ្ហានានាផងដែរ។

សម្រាប់ធុរជនដែលចង់ជ្រាបព័ត៌មានបន្ថែមអំពី "កម្រិតឥណទាន" សូមទាក់ទងមកការិយាល័យធនាគារ វីង ដោយផ្ទាល់ឬក៏ហ្វេសប៊ុកផ្លូវការរបស់ធនាគារ វីង៕

















Win
MEMORANDUM OF UNDERSTANDING SIGNING CEREMONY
TO PROMOTE THE USE OF E-PAYMENT SERVICES
BETWEEN GENERAL DEPARTMENT OF CUSTOMS AND EXCISE OF CAMBODIA AND WING BANK (CAMBODIA) PLC


Wing Bank
H.E Dr. Kun Nhem


H.E Dr. Kun Nhem


Wing Bank


MEMORANDUM OF UNDERSTANDING SIGNING CEREMONY
TO PROMOTE THE USE OF E-PAYMENT SERVICES
BETWEEN GENERAL DEPARTMENT OF CUSTOMS AND EXCISE OF CAMBODIA AND WING BANK (CAMBODIA) PLC


MEMORANDUM OF UNDERSTANDING SIGNING CEREMONY
TO PROMOTE THE USE OF E-PAYMENT SERVICES
BETWEEN GENERAL DEPARTMENT OF CUSTOMS AND EXCISE OF CAMBODIA AND WING BANK (CAMBODIA) PLC


Wing Bank

# ពិធីផ្សព្វផ្សាយអំពីសេវាកម្មពិនិត្យ និងព្យាបាលជំងឺ របស់មន្ទីរពេទ្យ Sunway Medical Centre និងសេវាកម្មធានារ៉ាប់រង របស់ក្រុមហ៊ុន AIA ជូនដល់មន្ត្រីគយនិងរដ្ឋាករ

នារសៀល ថ្ងៃចន្ទ ៦រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ លោក **តាំ ច័ន្ទកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមជាអធិបតីក្នុងពិធីផ្សព្វផ្សាយអំពីសេវាកម្មពិនិត្យ និងព្យាបាលជំងឺរបស់មន្ទីរពេទ្យ Sunway Medical Centre និងសេវាកម្មធានារ៉ាប់រងរបស់ក្រុមហ៊ុន AIA ជូនដល់មន្ត្រីគយនិងរដ្ឋាករ, មន្ត្រីបុគ្គលិកជាប់កិច្ចសន្យា, ដើងសាគយនិងធុរជននាំចេញនាំចូលមួយចំនួន។ ពិធីផ្សព្វផ្សាយនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីការថែទាំសុខភាព និងការទទួលបាននូវព័ត៌មានបន្ថែមអំពីសេវាកម្មពិនិត្យនិងព្យាបាលជំងឺ និងសេវាធានារ៉ាប់រងសុខភាពនិងអាយុជីវិតផងដែរ។ ក្រៅពីការទទួលសេវាកម្មពិនិត្យ និងព្យាបាលជំងឺពីមន្ទីរពេទ្យក្នុងស្រុក កម្មវិធីផ្សព្វផ្សាយនេះជាឱកាសមួយក្នុងការទទួលបានព័ត៌មានអំពីសេវាកម្មពិនិត្យនិងព្យាបាលជំងឺរបស់មន្ទីរពេទ្យ Sunway Medical Centre ប្រទេសម៉ាឡេស៊ី ដែលអាចជាជម្រើសមួយប្រសិនបើមានបំណងចង់ទៅស្វែងរកសេវាពិនិត្យនិងព្យាបាលជំងឺនៅបរទេស ។























# កិច្ចប្រជុំផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈ មន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា

នារសៀល ថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ក្រោមអធិបតីភាព លោកអគ្គនាយករង **សែ សុឃន** តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានការចូលរួមពីមន្ត្រីគយនិងរដ្ឋាករមកពីទូទាំងប្រទេស ក្នុងនោះចូលរួមដោយផ្ទាល់ចំនួន ១៩០ នាក់ និងចូលរួមតាមរយៈប្រព័ន្ធវីដេអូនៅតាមបណ្ដាអង្គភាពគយនិងរដ្ឋាករជាច្រើនរូបផងដែរ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយគោលការណ៍ និងវិធានរួមសម្រាប់ប្រតិបត្តិរបស់មន្ត្រីរាជការគយនិងរដ្ឋាករ សំដៅលើកកម្ពស់សីលធម៌ សេចក្ដីថ្លៃថ្នូរ ជំនាញវិជ្ជាជីវៈ គុណភាពការងារ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្ដល់សេវាសាធារណៈ។

ថ្លែងក្នុងកិច្ចប្រជុំនេះ លោកអគ្គនាយករង **សែ សុឃន** បានគូសបញ្ជាក់ថា កន្លងមក អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឱ្យអនុវត្តនូវក្រមសីលធម៌និងកិរិយាមារយាទមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ប៉ុន្តែដោយពិនិត្យឃើញថាក្រមសីលធម៌និងកិរិយាមារយាទនេះ នៅមានភាពខ្វះចន្លោះនោះ តម្រូវឱ្យមានការរៀបចំធ្វើបច្ចុប្បន្នភាពបន្ថែម ដើម្បីពង្រឹងសមត្ថភាពផ្នែកក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករ ធានាបាននូវការគោរពអភិក្រម ៤ប្រការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល។ នៅក្នុងកិច្ចប្រជុំនេះដែរ លោកអគ្គនាយករងបានផ្ដល់មតិណែនាំ និងធ្វើបទឧទ្ទេសនាមក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ព្រមទាំងបើកឱ្យមានកម្មវិធីសំណួរ-ចម្លើយ ដើម្បីឱ្យមន្ត្រីគយនិងរដ្ឋាករយល់ដឹងកាន់តែច្បាស់ថែមទៀត។

ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជានេះត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ កន្លងមក។



















# កិច្ចប្រជុំទ្វេភាគីគយព្រំដែនលើកទី៦ រវាងរដ្ឋបាលគយកម្ពុជា និងរដ្ឋបាលគយវៀតណាម

កិច្ចប្រជុំទ្វេភាគីគយព្រំដែនលើកទី៦ រវាងរដ្ឋបាលគយកម្ពុជា និងរដ្ឋបាលគយវៀតណាម ត្រូវបានរៀបចំធ្វើនៅខេត្តឡាមដុង ប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃ៣០ ខែតុលា ឆ្នាំ២០២៥ ដែលដឹកនាំដោយសហប្រធានលោក **នូ ស៊ីថា** ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស និងលោក **Vu Quang Toan** ប្រធាននាយកដ្ឋានប្រឆាំងការរត់គេចពន្ធនិងស៊ើបអង្កេតបទល្មើសគយ។ កិច្ចប្រជុំលើកនេះ រៀបចំឡើងក្នុងគោលបំណង តាមដានវឌ្ឍនភាពការងារសម្រេចបានបន្ទាប់ពីកិច្ចប្រជុំលើកទី៥, ពិនិត្យលើយន្តការនៃការផ្លាស់ប្តូរព័ត៌មានបទល្មើសឆ្លងដែន និងទិន្នន័យស្ថិតិពាណិជ្ជកម្មនាំចេញនាំចូល, ធ្វើបច្ចុប្បន្នភាពមន្ត្រីទំនាក់ទំនងសម្រាប់កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយទាំងពីរ ជាពិសេសលើការងារបង្ការនិងបង្ក្រាបអំពើរត់ពន្ធ និងបទល្មើសឆ្លងដែន ស្របតាមខ្លឹមសារនៃអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខានាឆ្នាំ២០១៩ និងកំណត់ហេតុនៃកិច្ចប្រជុំកម្រិតអគ្គនាយកគយនៃរដ្ឋបាលគយទាំងពីរនាឆ្នាំ២០២៤។ លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំមានដូចខាងក្រោម៖

១.ភាគីទាំងពីរបានពិភាក្សានិងឯកភាពគ្នាលើចំណុចមួយចំនួន រួមមាន៖ ក). ធ្វើបច្ចុប្បន្នភាពឈ្មោះមន្ត្រីទំនាក់ទំនងទទួលបន្ទុកការងារផ្លាស់ប្តូរព័ត៌មានពីកម្រិតថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋានពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើរត់គេចពន្ធ និងបទល្មើសឆ្លងដែន ដើម្បីធានាឱ្យការធ្វើទំនាក់ទំនងគ្នាបានឆាប់រហ័សទាន់ពេលវេលា និងមានប្រសិទ្ធភាព ព្រមទាំងរក្សាបាននូវការសម្ងាត់វិជ្ជាជីវៈខ្ពស់ ខ). បន្តពង្រឹងកិច្ចសហប្រតិបត្តិការលើការបង្ការនិងបង្ក្រាប និងស៊ើបអង្កេតបទល្មើសរត់គេចពន្ធឱ្យមានប្រសិទ្ធភាពខ្ពស់ដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសទាំងពីរ និងកិច្ចព្រមព្រៀងអន្តរជាតិដែលប្រទេសទាំងពីរជាប្រទេសហត្ថលេខី គ). ពិនិត្យពិភាក្សា និងសិក្សាស្វែងរកមធ្យោបាយ ដើម្បីពង្រឹងកិច្ចសម្របសម្រួលដើម្បីបង្ការនិងបង្ក្រាបទំនិញរត់គេចពន្ធដែលមានហានិភ័យខ្ពស់នៅតំបន់ជាប់ព្រំដែន, រៀបចំកសាងយន្តការត្រួតពិនិត្យរួមគ្នា ព្រមទាំងពង្រឹងការអនុវត្តកម្មវិធីត្រួតពិនិត្យរួមគ្នាលើការងារគយសំខាន់ៗ ឃ). បន្តរៀបចំប្រជុំទ្វេភាគីថ្នាក់ខេត្តជាប់ព្រំដែនឱ្យបានទៀងទាត់ និងតាមករណីចាំបាច់ និង ង). បន្តរៀបចំសហការផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសទាំងពីរ ដើម្បីលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋរស់នៅតាមព្រំដែន និងធុរជនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងដែន អំពីផលវិបាកនៃការរត់គេចពន្ធ ការក្លែងបន្លំពាណិជ្ជកម្ម និងឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀនដែលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចសង្គម និងសន្តិសុខជាតិនៃប្រទេសទាំងពីរ។

២.ភាគីវៀតណាមបានដឹកនាំគណៈប្រតិភូគយកម្ពុជាធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីស្ថានភាពនៃការអនុវត្តការងារនិងនីតិវិធីគ្រប់គ្រងការបញ្ចេញទំនិញពីគយ នៅការិយាល័យគយដាឡាត។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលសម្រេចកន្លងមក និងចាត់ទុកកិច្ចប្រជុំទ្វេភាគីនេះមាន សារៈសំខាន់ដែលនឹងក្លាយជាយន្តការនៃការធ្វើកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមកឱ្យកាន់តែល្អ ជាពិសេស ការងារប្រយុទ្ធប្រឆាំងអំពើរត់គេចពន្ធ និងបទល្មើសឆ្លងដែនស្របតាមសភាពការណ៍វិវត្តន៍ថ្មីៗ របស់ប្រទេសទាំងពីរ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងការប្រមូលចំណូលថវិការដ្ឋរបស់ប្រទេសរៀងៗខ្លួន។


HỘI NGHỊ HẢI QUAN BIÊN GIỚI


VU QUANG TOAN








HỘI NGHỊ HẢI QUAN BIÊN GIỚI
VIỆT NAM – CAMPUCHIA LẦN THỨ 6
THE 6th VIET NAM – CAMBODIA









# ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និង អ្នកជំនាញការ EU GERMAN GATE, GIZ, GATF និងUNCTAD

នាព្រឹកថ្ងៃអង្គារ ០៦រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកអគ្គនាយករង **ផា អេងវ៉េង** តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានអញ្ជើញទទួលស្វាគមន៍គណៈប្រតិភូនៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និងអ្នកជំនាញការ EU GERMAN GATE, GIZ, GATF និង UNCTAD ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធ លើភាពជោគជ័យរបស់កម្ពុជាក្នុងការអនុវត្ត PAP សម្រាប់បញ្ញើឆាប់រហ័ស ដោយប្រើប្រាស់ប្រព័ន្ធ ASYHUB និងក្របខ័ណ្ឌការវិភាគហានិភ័យ និងនីតិវិធីគយពាក់ព័ន្ធបញ្ញើប្រៃសណីយ៍ រយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅតាមបណ្តាអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ។

លោកអគ្គនាយករង បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈប្រតិភូទាំងអស់និងបានជម្រាបជូនអំពីបទពិសោធការងារ និងភាពជោគជ័យរបស់ **អគរ** តាមរយៈឆន្ទៈគាំទ្រយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជា និង ការដឹកនាំប្រកបដោយទស្សនវិស័យច្បាស់លាស់របស់ **អគរ** ដែលមានឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានដឹកនាំសម្របសម្រួលជំរុញការចូលរួមពីសមាជិកដែលមានសមាសភាពមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជនតំណាងដោយសភាពាណិជ្ជកម្មកម្ពុជា, និងដៃគូអភិវឌ្ឍន៍នានាដែលបានសហការចូលរួមគាំទ្រការងាររបស់ **អគរ**។

លោកស្រី **Dusanka Jovanvic** ប្រធានគណៈប្រតិភូនៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ថ្នាក់ដឹកនាំ **អគរ** និងតំណាង EU GERMAN GATE ដែលបានសហការរៀបចំដំណើរទស្សនកិច្ចដ៏មានសារៈសំខាន់នេះ។ ជាមួយគ្នានេះ លោកស្រីប្រធានគណៈប្រតិភូ រួមទាំងអ្នកជំនាញការទាំងអស់ ក៏បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **អគរ** ក្នុងកិច្ចការកំណែទម្រង់ ដែលបាន និងកំពុងផ្តោតលើការងារដូចជា៖ ស្វ័យប្រវត្តិកម្មនីតិវិធីគយនិងឌីជីថល កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (AEO) កម្មវិធីប្រព័ន្ធបញ្ជរតែមួយជាតិ (NSW)និងនីតិវិធីបំពេញបែបបទមុនពេលទំនិញមកដល់ (PAP)។ល។

ទន្ទឹមនេះ គណៈប្រតិភូបានបន្តដំណើរទស្សនកិច្ចស្វែងយល់អំពីការងារមួយចំនួននៅតាមអង្គភាពមួយចំនួនរបស់ **អគរ**៖ ១). នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ដោយបានចុះពិនិត្យស្វែងយល់អំពីការអនុវត្តការងារបំពេញបែបបទគយនៅឃ្លាំងទំនិញ នៃអាកាសយានដ្ឋានអន្តរជាតិតេជោ, ២). សាខាគយនិងរដ្ឋាករប្រៃសណីយ៍ ដោយបានជួបប្រជុំពិភាក្សាការងារកម្រិតបច្ចេកទេសលើការងារគ្រប់គ្រងហានិភ័យក្នុងប្រព័ន្ធ ASYHUB និងការបំពេញបែបបទបញ្ចេញទំនិញសម្រាប់បញ្ញើប្រៃសណីយ៍ និង ៣). សាលាជាតិគយ ដោយបានរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសលើការងារគ្រប់គ្រងហានិភ័យក្នុងប្រព័ន្ធ ASYHUB ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករ មកពីសាលាជាតិគយ នាយកដ្ឋានសវនកម្មគយ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន សាខាគយនិងរដ្ឋាករប្រៃសណីយ៍ ព្រមទាំងតំណាងប្រៃសណីយ៍កម្ពុជា។

នាថ្ងៃបញ្ចប់នៃដំណើរទស្សនកិច្ចនេះ គណៈប្រតិភូនៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និងមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធ បានបន្តចូលរួមសិក្ខាសាលាកម្រិតបច្ចេកទេស ដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធលើនិន្នាការនិងការអភិវឌ្ឍន៍ចុងក្រោយ នៃការបំពេញបែបបទគយសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិក (e-commerce)

ដែលបានប្រព្រឹត្តទៅមួយថ្ងៃពេញ នៅសណ្ឋាគារណូវ៉ូថែល ភ្នំពេញ ក្រោមកិច្ចសម្របសម្រួល និងរៀបចំដោយ EU GERMAN GATE។

ដំណើរទស្សនកិច្ច ៣ថ្ងៃ របស់គណៈប្រតិភូនៃរដ្ឋបាលគយ BOSNIA AND HERZEGOVINA និងអ្នកជំនាញការ EU GERMAN GATE, GIZ, GATF និង UNCTAD មកកាន់ **អគរ** បានបញ្ចប់ទៅប្រកបដោយលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ។ គណៈប្រតិភូបានសំដែងនូវសេចក្ដីសោមនស្សរីករាយ និងបានថ្លែងអំណរគុណចំពោះ **អគរ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចែករំលែកបទពិសោធន៍ទាំងលើផ្នែកទ្រឹស្ដីនិងការអនុវត្តជាក់ស្ដែង ដែលជាធាតុចូលដ៏សំខាន់សម្រាប់រដ្ឋបាលគយ Bosnia and Herzegovina ក្នុងការយកទៅអនុវត្តឱ្យបានកាន់តែល្អប្រសើរបន្ថែមទៀត នាពេលអនាគត។

















# វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាគយ ជំនាន់ទី១២ និងការប្រឡងបញ្ចប់

ចាប់ពីថ្ងៃទី៦ ខែតុលា ដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលាជាតិគយ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាគយជំនាន់ទី១២ ដែលមានសិក្ខាកាមសរុបចំនួន៤១២នាក់។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងផ្តល់ជូនសិក្ខាកាមនូវចំណេះដឹងអំពីច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីគយ ព្រមទាំងជំនាញសំខាន់សម្រាប់ប្រតិបត្តិការគយ។ សិក្ខាកាមដែលបានបញ្ចប់និងប្រឡងជាប់វគ្គបណ្តុះបណ្តាលនឹងទទួលបានវិញ្ញាបនបត្របញ្ចប់វគ្គដែលអាចជាអត្ថប្រយោជន៍នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបធុរកិច្ចជាជើងសាគយ ឬការងារដែលមានការពាក់ព័ន្ធ។

ជើងសាគយដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម សេវាកម្ម និងជួយជំរុញខ្សែច្រវាក់ផ្គត់ផ្គង់នូវទំនិញឬវត្ថុធាតុដើមនាំចូល នាំចេញ និងឆ្លងកាត់ ហើយក៏ជាអន្តរការីយ៉ាងសំខាន់រវាងម្ចាស់ទំនិញ/អ្នកនាំចូល/អ្នកនាំចេញជាមួយនឹងរដ្ឋបាលគយផងដែរ។ ដូច្នេះ ជើងសាគយចាំបាច់ត្រូវមានសមត្ថភាព ចំណេះដឹង ជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌ច្បាស់លាស់ ដើម្បីរក្សាការពារផលប្រយោជន៍របស់ម្ចាស់ទំនិញរក្សាបានសុចរិតភាព និងតម្លាភាពក្នុងការធ្វើពាណិជ្ជកម្ម ជាពិសេសទទួលខុសត្រូវប្រកាសឬធ្វើសេចក្តីរាយការណ៍ចំពោះសមត្ថកិច្ចគយ។

ដើម្បីឱ្យស្របតាមបរិបទការងារជើងសាគយខាងលើ វគ្គបណ្តុះបណ្តាលនេះបានផ្តោតលើមុខវិជ្ជាសំខាន់ៗមួយចំនួន រួមមាន ច្បាប់និងបទប្បញ្ញត្តិគយ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងការនាំចេញ នាំចូល និងឆ្លងកាត់ នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ ការធ្វើចំណាត់ថ្នាក់តាមតារាង វិធានដើមកំណើតទំនិញ ការកំណត់តម្លៃគិតពន្ធគយ ការងារគ្រប់គ្រងហានិភ័យនិងការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដែលក្នុងនោះ ជើងសាគយត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការរបស់ខ្លួន។

ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានរៀបចំការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាគយ ជំនាន់ទី១២ នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលាជាតិគយ ដែលមានបេក្ខជនមានសិទ្ធិចូលរួមប្រឡងសរុបចំនួន ៤១២នាក់ (ស្រី ១៥៤នាក់) ក្នុងនោះ អវត្តមានចំនួន ២៥នាក់ (ស្រី ៧នាក់)។ ជាលទ្ធផល បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរមានចំនួន ៣៥៧នាក់ (ស្រី ១៣៦នាក់)។
















**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

## សារលិខិតជូនពរ
## ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រី-បុគ្គលិកជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២៦

*លោកជំទាវ ឯកឧត្តម អស់លោក លោកស្រីថ្នាក់ដឹកនាំ និងមន្ត្រីរាជការគយនិងរដ្ឋាករ ព្រមទាំងមន្ត្រី-បុគ្គលិកជាប់កិច្ចសន្យាទាំងអស់ជាទីរាប់អានដ៏ជ្រាលជ្រៅ !*

អស់រយៈពេលពេញមួយឆ្នាំទៀតហើយ ដែលយើងទាំងអស់គ្នាបានរួមដំណើរជាមួយគ្នាក្នុងនាមជាមហាគ្រួសារគយនិងរដ្ឋាករកម្ពុជា ដោយបានបំពេញតួនាទី និងភារកិច្ចជូនជាតិមាតុភូមិ និងរាជរដ្ឋាភិបាលរបស់យើង ប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធផលខ្ពស់។

សម្រាប់ឆ្នាំ២០២៥ នេះ ភាពមិនប្រាកដប្រជា ភាពតានតឹងនៃការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ និងការប្រកាន់យកគោលនយោបាយគាំពារនិយមដោយប្រទេសមហាអំណាច នៅតែបន្តកើតមាន ហើយមានសកម្មភាពកាន់តែខ្លាំងក្លាឡើង។ បន្ថែមពីលើនេះទៀត ចាប់តាំងពីចុងខែកក្កដា ឆ្នាំ២០២៥ មក ប្រទេសជាតិយើងទាំងមូលជួបនឹងបញ្ហាដ៏ធ្ងន់ធ្ងរថ្មីមួយទៀត ដែលបង្កឡើងដោយអំពើឈ្លានពានយ៉ាងកំរោលរបស់ប្រទេសថៃ ហើយបានអូសបន្លាយ និងរាលដាលកាន់តែធំដោយបំពានហ៊ានទម្លាក់គ្រាប់បែកកាន់តែជ្រៅឡើងៗចូលមកក្នុងដែនអធិបតេយ្យជាតិកម្ពុជា នាពេលបច្ចុប្បន្ននេះ។ អំពើឈ្លានពានដ៏គឃ្លើននេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយើងរាប់សែនគ្រួសារ និងបានបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធស៊ីវិលជាច្រើន។ សម្រាប់អង្គភាពយើង ដែលជាស្ថាប័នឈរជើងជួរមុខតាមបណ្តោយព្រំដែន សកម្មភាពការងារទាំងឡាយនៅតាមជួរព្រំដែនគោកជាប់នឹងប្រទេសថៃត្រូវបានផ្អាកទាំងស្រុង ហើយមិនតែប៉ុណ្ណោះ អគាររដ្ឋបាលនិងកន្លែងធ្វើការរបស់យើងមួយចំនួនក៏ត្រូវបានបំផ្លិចបំផ្លាញដោយអំពើដ៏ព្រៃផ្សៃនេះផងដែរ។

បើទោះបីជាស្ថានភាពទាំងនេះ បង្កើតនូវបរិយាកាសអាប់អួរ និងក្តីអំពល់ក្នុងអារម្មណ៍យើងទាំងអស់គ្នាក្តី ក៏យើងទាំងអស់គ្នាបានខិតខំពូនជ្រំកម្លាំងប្រឹងប្រែងជំនះការលំបាកនានា ប្រមូលចំណូលជូនជាតិរហូតសម្រេចបានប្រមាណ ១២៤% នៃផែនការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ដែលជាលទ្ធផលមួយដ៏ល្អប្រសើរ។ សមិទ្ធផលចំណូលនេះគឺការរួមចំណែកមិនអាចខ្វះបានជាមួយរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយភាពស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការដឹកនាំប្រទេសកម្ពុជាឆ្លងកាត់វិញ្ញាសាដ៏សែនលំបាក ដែលយើងទាំងអស់គ្នាកំពុងជួបប្រទះ។ ក្រៅពីលទ្ធផលចំណូលនេះ ស្ថាប័នយើងក៏សម្រេចបានលទ្ធផលគួរជាទីមោទនៈលើការដ្ឋានការងារដែលគាំទ្រដល់ការប្រមូលចំណូលផងដែរ ដែលរួមមាន ការងារបង្ការនិងបង្ក្រាបអំពីរត់គេចពន្ធ, ការបន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយ, ការកសាងហេដ្ឋារចនា-សម្ព័ន្ធរូបវន្តនិងធនធានមនុស្ស ព្រមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធលើការងារគយ ទាំងថ្នាក់ជាតិ និងអន្តរជាតិ។ ជាក់ស្តែង ក្នុងឆ្នាំនេះ រដ្ឋបាលគយយើងបានចាប់ផ្តើមអនុវត្តសាកល្បងនូវប្រព័ន្ធតាមដានការដឹកជញ្ជូនទំនិញ (ECTS), ប្រព័ន្ធប្រមូលផ្តុំរូបភាពស្កេន (CIISS) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសគយក្នុងប្រព័ន្ធអេឡិចត្រូនិក (CES) បន្ទាប់ពីបានគ្រោងអនុវត្តជាច្រើនឆ្នាំមកហើយ។ ជាមួយគ្នានេះ យើងបានធ្វើការយ៉ាងជិតស្និតជាមួយផ្នែកឯកជន ហើយសម្រេចបាននូវការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន ៣ ដែលរួមមានជាមួយ ក្រុមហ៊ុន DHL EXPRESS (CAMBODIA) LTD., សមាគមភស្តុភារកម្មកម្ពុជា, និងចុងក្រោយគឺ ជាមួយធនាគារ វីង (ខេមបូឌា) ម.ក។

សម្រាប់ឆ្នាំ២០២៦ នេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាប្តេជ្ញាចិត្តបន្តចូលរួមគាំទ្រយ៉ាងពេញទំហឹងដល់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា តាមរយៈការខិតខំប្រមូលចំណូលជូនជាតិឱ្យបានគ្រប់ផែនការដែលបានដាក់ចេញ ដើម្បីជាការជ្រោមជ្រែងរាជរដ្ឋាភិបាលក្នុងការការពារអធិបតេយ្យជាតិពីការឈ្លានពានរបស់សត្រូវ។ យើងទាំងអស់គ្នាជឿជាក់លើការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង **ជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** និង **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការដោះស្រាយបញ្ហាប្រកបដោយយុទ្ធសាស្ត្រ ដើម្បីស្វែងរកសុខសន្តិភាព និងសុខសុវត្ថិភាពយូរអង្វែងជូនដល់ប្រជាជាតិរបស់យើង ហើយយើងនឹងបន្តពង្រឹងសមត្ថភាពស្ថាប័ន, ធ្វើទំនើបកម្មនីតិវិធី និងអនុវត្តតួនាទីនិងភារកិច្ចផ្សេងទៀតដែលប្រមុខរាជរដ្ឋាភិបាលផ្តល់ជូនក្នុងស្មារតីស្វាហាប់ និងទទួលខុសត្រូវខ្ពស់។

ក្រៅពីលទ្ធផលការងារទាំងអស់ខាងលើ សមាគមសង្គហមិត្តមន្ត្រីរាជការគយយើងក៏បានរួមផ្តុំគ្នាយ៉ាងក្លៀវក្លាចូលរួមនូវសកម្មភាពមនុស្សធម៌-សប្បុរសធម៌យ៉ាងសកម្ម ជាពិសេសក្នុងកៀរគរ និងនាំយកជំនួយ ដែលមានជាសម្ភារៈ, ថវិកា, គ្រឿងឧបភោគ-បរិភោគ ជូនដល់វីរកងទ័ពជាតិ វីរនគរបាលជាតិ នៅសមរភូមិជួរមុខ ដែលកំពុងតស៊ូ ពុះពារយ៉ាងអង់អាចក្លាហានការពារបូរណភាពទឹកដី និងអធិបតេយ្យភាពរបស់កម្ពុជាពីអំពើឈ្លានពានយ៉ាងព្រៃផ្សៃរបស់ប្រទេសថៃ ក៏ដូចជាជូនដល់ប្រជាពលរដ្ឋដែលកំពុងភៀសសឹក។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ លំឱនកាយសង្រួមចិត្ត គោរពដល់វិញ្ញាណក្ខន្ធវីរកងទ័ពនិងវីរនគរបាលជាតិដែលបានលះបង់អាយុជីវិត ដើម្បីបុព្វហេតុការពារជាតិ ការពារមាតុភូមិជាទីស្រឡាញ់របស់យើងទាំងអស់គ្នា ដែលមិនអាចបំភ្លេចបាន។

ខ្ញុំមានជំនឿជឿជាក់ប្រកបដោយសុទិដ្ឋិនិយមថា មហាគ្រួសារក្រោមដំបូលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមួយនេះនឹងបន្តលើកតម្កើង និងរួមគ្នាប្រឹងប្រែងកសាងស្ថាប័នជំនាញមួយនេះ ឱ្យកាន់តែរីកចម្រើនធំធាត់ ដើម្បីបំពេញតួនាទី និងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ប្រកបដោយជំនាញវិជ្ជាជីវៈក្នុងនាមជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបានការទុកចិត្តដ៏ខ្ពង់ខ្ពស់ពីរាជរដ្ឋាភិបាល។

នៅក្នុងឱកាសឆ្នាំថ្មី ឆ្នាំ២០២៦ នេះ ក្នុងនាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងអំណរសាទរប្រកបដោយទឹកចិត្តរំភើបរីករាយ ក្នុងមនោសញ្ចេតនាគោរព ស្រឡាញ់ ប្រកបដោយភាតរៈ។ ខ្ញុំសូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមប្រោះព្រំសព្ទសាធុការពរជ័យបវរមហាប្រសើរថ្លៃថ្លា ជូនដល់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការគយនិងរដ្ឋាករទាំងអស់ រួមទាំងមន្ត្រី-បុគ្គលិកជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សូមប្រកបដោយសុខសុវត្ថិភាព សុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន បញ្ញាភ្លឺថ្លា អាយុយឺនយូរ សុភមង្គលក្នុងក្រុមគ្រួសារ និងសម្រេចបានជោគជ័យថ្មីៗ លើគ្រប់ភារកិច្ចបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍ជាតិមាតុភូមិកម្ពុជាដ៏បវរថ្លៃថ្លានៃយើងទាំងអស់គ្នា។

សូមសហការីទាំងអស់ព្រមទាំងគ្រួសារបានប្រកបដោយពុទ្ធពរ និងពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!

**សួស្តីឆ្នាំថ្មី ! Happy New Year !**

ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

# ផ្នែកទី២
# ការយល់ដឹងអំពីនីតិវិធីគយ

- ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ
- សិក្ខាសាលាផ្សព្វផ្សាយ "និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញ ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក"
- សិក្ខាសាលាស្តីពី ការអនុវត្តយេនឌ័រនិងចម្រុះភាព
- វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ
- សេចក្តីប្រកាសព័ត៌មាន សិក្ខាសាលាស្តីពី "ការពង្រឹងពាណិជ្ជកម្មធានាសន្តិសុខកុងតឺន័រ និងខ្សែច្រវាក់ផ្គត់ផ្គង់"
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ"
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងអនាគត"
- សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល "Training of Trainers"
- សិក្ខាសាលាស្តីពី "ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ លើកទី៥"

# ការលើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសគយ

សាលាជាតិគយជាថ្នាលបណ្តុះបណ្តាលធនធានមនុស្ស និងបានបន្តពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីគយនិងរដ្ឋាករគ្រប់លំដាប់ថ្នាក់ជូន **អគរ** ដើម្បីធានានូវប្រសិទ្ធភាពការងារនិងការបំពេញភារកិច្ចតាមក្រមសីលធម៌វិជ្ជាជីវៈខ្ពស់បំផុត។ រយៈកាលកន្លងមកក្នុងឆ្នាំ២០២៥នេះសាលាជាតិគយបានរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីគយ ច្បាប់និងនីតិវិធីគ្រប់គ្រងរដ្ឋបាល ជំនាញបច្ចេកទេសគយ និងវគ្គសិក្ខាសាលារយៈពេលខ្លីជាច្រើន ដើម្បីបង្កើនសមត្ថភាពជំនាញនិងចំណេះដឹងការងារគយនិងរដ្ឋាករជូនដល់មន្ត្រីជាច្រើនរូបក្នុងអង្គភាព **អគរ** និងបុគ្គលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ទន្ទឹមនេះ គោលបំណងចម្បងរបស់សាលាជាតិគយ គឺជួយពង្រឹងសមត្ថភាពនិងចំណេះដឹងជូនមន្ត្រីគយនិងរដ្ឋាករទាំងអស់ ក្នុងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល កិច្ចសម្រួលពាណិជ្ជកម្មជូនធុរកិច្ចស្របច្បាប់ កិច្ចការពារសង្គម ការចូលរួមថែរក្សាសន្តិសុខ និងពង្រឹងខឿនសេដ្ឋកិច្ចជាតិ។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ សាលាជាតិគយបានសហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងបណ្តានាយកដ្ឋានជំនាញចំណុះ **អគរ** ព្រមទាំងដៃគូអភិវឌ្ឍនានា បានរៀបចំវគ្គបណ្តុះបណ្តាល/សិក្ខាសាលាសរុបចំនួន ១៥ដង ក្នុងនោះ មានសិក្ខាកាមជាមន្ត្រីគយនិងរដ្ឋាករ ៥៤៤នាក់, បុគ្គលិកជាប់កិច្ចសន្យា ១នាក់, មន្ត្រីនៃស្ថាប័នពាក់ព័ន្ធ ១៣៤នាក់, និងវិស័យឯកជន ៦៦១នាក់។ ដោយឡែក សម្រាប់ឆ្នាំ២០២៥នេះ ក្នុងនាមជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សាលាជាតិគយបានអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសគយជូនដល់មន្ត្រីគយនិងរដ្ឋាករគ្រប់ជាន់ថ្នាក់ស្របតាមផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួនដោយបានរៀបចំវគ្គបណ្តុះបណ្តាល/សិក្ខាសាលាសុបចំនួន ៥២ដង ដែលមានមន្ត្រីគយចំនួន ១ ៩៧២នាក់, មន្ត្រីជាប់កិច្ចសន្យាចំនួន ១០នាក់, មន្ត្រីនៃក្រសួងស្ថាប័នពាក់ព័ន្ធចំនួន ១៣៤នាក់ និងវិស័យឯកជនចំនួន ២ ២១១នាក់។ ក្នុងនោះ សាលាជាតិគយក្នុងនាមជាមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់អង្គការគយពិភពលោកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាថ្នាក់ជាតិនិងតំបន់បានចំនួន ៥ដង រួមមាន៖ ១). វគ្គបណ្តុះបណ្តាលស្តីពី "ការលើកកម្ពស់ការយល់ដឹងអំពីការរាវរកវិទ្យុសកម្ម និងនុយក្លេអ៊ែរ (RN)", ២). កម្មវិធីសិក្សាស្តីពី " ASIA-PACIFIC CUS_TOMS LEADERSHIP PROGRAM (CLP) FOR 2025", ៣). វគ្គសិក្ខាសាលាស្តីពី "ការពង្រឹងពាណិជ្ជកម្ម៖ ធានាសន្តិសុខកុងតឺន័រនិងខ្សែច្រវ៉ាក់ផ្គត់ផ្គង់", ៤). សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល (Training of Trainers), និង៥). សិក្ខាសាលាស្តីពី "ការគ្រប់គ្រងហានិភ័យ"។ ទន្ទឹមនេះ ក្នុងឆ្នាំ២០២៥នេះ **អគរ** ក៏បានចាត់តាំងមន្ត្រីគយចំនួន ១០៣នាក់ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលានៅក្រៅប្រទេសចំនួន ៣១ដង ផងដែរ។




សាលាជាតិគយជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលាថ្នាក់ជាតិនិងតំបន់នានា




សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល "Training of Trainers"



វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជើងសាគយ ជំនាន់ទី១២

# សិក្ខាសាលាផ្សព្វផ្សាយ "និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញ ទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក"

នាព្រឹកថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី "និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក" នៅសាលាជាតិគយ។ អង្គសិក្ខាសាលានេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងជាប្រធានគណៈកម្មការសម្របសម្រួលក្រុមការងារផ្នែកឯកជន សម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា និងមានការចូលរួមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សភាពាណិជ្ជកម្មកម្ពុជា អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី តំណាងស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា សភាពាណិជ្ជកម្មអាម៉េរិកប្រចាំកម្ពុជា សមាគមភស្តុភារកម្មកម្ពុជា សមាគមផលិតគ្រឿងអេឡិចត្រូនិកនិងបច្ចេកវិទ្យាកម្ពុជា និងក្រុមហ៊ុនវិនិយោគដែលផលិតទំនិញនាំចេញទៅទីផ្សារសហរដ្ឋអាម៉េរិក ព្រមទាំងដើងសាគយ សរុបប្រមាណ ៥០០រូប។

ថ្លែងក្នុងពិធីបើកអង្គសិក្ខាសាលា អ្នកឧកញ៉ា **គិត ម៉េង** បានមានចំណាប់អារម្មណ៍ថា អង្គសិក្ខាសាលានេះ នឹងជំរុញវិនិយោគិនដែលនាំចេញទំនិញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ឱ្យអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទន្ទឹមនេះ អ្នកឧកញ៉ា ក៏បានស្នើក្រសួង-ស្ថាប័នពាក់ព័ន្ធផ្តល់កិច្ចសម្រួលពាណិជ្ជកម្មជាអតិបរមាជូនដល់ធុរជន និងត្រូវដាក់ទោសទណ្ឌដល់ធុរជនប្រព្រឹត្តបទល្មើស ព្រមទាំងបានអំពាវនាវដល់ធុរជនក្រុមហ៊ុនដឹកជញ្ជូន ភ្នាក់ងារផ្តល់សេវានិងដើងសាគយត្រូវចូលរួមការប្រកាសនាំចេញ-នាំចូលទំនិញឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ជៀសវាងការប្រព្រឹត្តបទល្មើសដែលអាចឈានដល់ការចុះមកអង្កេតពីសហរដ្ឋអាម៉េរិកដែលអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ទីផ្សារនាំចេញរបស់កម្ពុជា។

ក្នុងមតិស្វាគមន៍បើកអង្គសិក្ខាសាលា ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានគូសរំលេចពីសារៈសំខាន់នៃទីផ្សារសហរដ្ឋអាម៉េរិក ចំពោះទំនិញនាំចេញពីកម្ពុជា ដែលទីផ្សារនេះស្រូបយកប្រមាណ ៤៣% នៃការនាំចេញសរុបរបស់កម្ពុជា ដែលក្នុងន័យនេះ គ្រប់តួអង្គ និងភាគីពាក់ព័ន្ធត្រូវខិតខំថែរក្សាទីផ្សារនេះឱ្យបានល្អ។ ហេតុដូច្នេះហើយទើបភ្លាមៗបន្ទាប់ពីសហរដ្ឋអាម៉េរិកប្រកាសដាក់ពន្ធបដិការ ៤៩% លើទំនិញនាំចេញពីកម្ពុជា កាលពីខែមេសាឆ្នាំ២០២៥, រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងប៉ិនប្រសប់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចាត់វិធានការរហ័ស និងទាន់ពេលវេលា ស្នើសុំចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាម៉េរិក ដែលរហូតឈានដល់សម្រេចបាននូវ "កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មបដិការ" រវាងប្រទេសទាំងពីរ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ដែលពន្ធបដិការលើទំនិញរបស់កម្ពុជាត្រូវបានទម្លាក់ពី ៤៩% មកត្រឹម ១៩%។ ភ្ជាប់នឹងកិច្ចខិតខំប្រឹងប្រែងនេះ អង្គពិធីនៅថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយអំពីខ្លឹមសារនៃ "និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក" ដែលជាឯកសារគោលរបស់ក្រុមការងារអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការក្លែងបន្លំដើមកំណើត

ទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក សម្រាប់យកទៅអនុវត្តក្នុងការធានាថា ការនាំចូលវត្ថុធាតុដើមដើម្បីផលិតនិងកែច្នៃហើយនាំចេញទៅទីផ្សារសហរដ្ឋអាម៉េរិក មានអនុលោមភាពស្របតាមវិធានដើមកំណើតទំនិញដែលបានកំណត់ ដែលការណ៍នេះជាការរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាទីផ្សារ និងថែរក្សាអត្រាពន្ធបដិការដែលមានភាពប្រកួតប្រជែងធៀបជាមួយនឹងប្រទេសជិតខាងដែលកម្ពុជាទទួលបាន។ ឯកឧត្តម ក៏បានអំពាវនាវឱ្យគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសវិនិយោគិនដែលបណ្តាក់ទុននៅកម្ពុជាបច្ចុប្បន្នខិតខំចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកែលម្អបរិយាកាសវិនិយោគនៅកម្ពុជា និងខិតខំស្វែងរកវិនិយោគិនមកបណ្តាក់ទុនធ្វើធុរកិច្ចនៅកម្ពុជាបន្ថែមទៀត។

បន្ថែមលើនេះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានគូសបញ្ជាក់ជូនអង្គសិក្ខាសាលាថា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា គ្រោងនឹងស្នើសុំរៀបចំកិច្ចប្រជុំជាមួយរដ្ឋបាលគយនៃសហរដ្ឋអាម៉េរិក ដើម្បីពិនិត្យលទ្ធភាពរៀបចំកសាងឱ្យមានក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមកក្នុងវិស័យគយជាមួយនឹងរដ្ឋបាលគយរបស់សហរដ្ឋអាម៉េរិក ដោយផ្អែកលើមគ្គុទ្ទេសក៏គំរូ (CMAA) របស់អង្គការគយពិភពលោកដើម្បីងាយស្រួលឱ្យរដ្ឋបាលគយទាំងពីរអាចបន្តពង្រឹងកិច្ចសហការ ជាពិសេសសម្របសម្រួលក្នុងការចុះមកអង្កេតគម្រោងវិនិយោគនៅកម្ពុជា ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានចាំបាច់នានា។ ក្នុងករណីសម្រេចបាននូវការចុះហត្ថលេខាលើក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការនេះ ក្រុមការងារអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក នឹងត្រូវទទួលភារកិច្ចសម្របសម្រួលជាមួយរដ្ឋបាលគយរបស់សហរដ្ឋអាម៉េរិក។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយអំពីខ្លឹមសារៈ ១.និយាមនីតិវិធីប្រតិបត្តិសម្រាប់អនុវត្តវិធានការបង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ២.វឌ្ឍនភាពនៃការចរចាពន្ធគយបដិការជាមួយសហរដ្ឋអាម៉េរិក ៣.នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញនិងការចែករំលែកព័ត៌មានពីសក្តានុពលទីផ្សារសហរដ្ឋអាម៉េរិកដោយប្រធានសភាពាណិជ្ជកម្មអាម៉េរិកប្រចាំកម្ពុជា។

បន្ទាប់មក អង្គវេទិកាបានរៀបចំកិច្ចពិភាក្សា ដើម្បីឆ្លើយតបនឹងសំណួរ និងសំណូមពរដែលជាកង្វល់របស់វិស័យឯកជន ដោយមានវាគ្មិនកិត្តិយសមកពី **អគរ ក.អ.ក. ក.ព.ណ.** និងទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី។ ក្នុងកិច្ចពិភាក្សានេះ មានសំណួរដែលបានលើកឡើង ត្រូវបានពន្យល់និងបំភ្លឺជូនយ៉ាងច្បាស់លាស់ដោយវាគ្មិនកិត្តិយស។

ថ្លែងក្នុងពិធីបិទអង្គសិក្ខាសាលា លោក **ផា អេងថ៉េង** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានជំរុញនិងលើកទឹកចិត្តអ្នកវិនិយោគទាំងអស់ចូលរួមពង្រឹងអនុលោមភាពស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដើម្បីរក្សាឱ្យបាននូវការទុកចិត្តពីសហរដ្ឋអាម៉េរិក។ ជាចុងបញ្ចប់ លោក **ផា អេងថ៉េង** បានថ្លែងអំណរគុណដល់វាគ្មិនកិត្តិយស ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលអញ្ជើញចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់នៅថ្ងៃនេះ និងជូនពរដល់ក្រុមហ៊ុនវិនិយោគទាំងអស់ទទួលជោគជ័យក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។






















# សិក្ខាសាលាស្តីពី ការអនុវត្តយេនឌ័រនិងចម្រុះភាព

ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥, នៅសាលាជាតិគយ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) សហការជាមួយអង្គការគយពិភពលោក (World Customs Organization-WCO) បានរៀបចំសិក្ខាសាលាស្តីពី "ការអនុវត្តន៍សមភាពយេនឌ័រនិងចម្រុះភាពនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា" ដោយមានការចូលរួមពីសិក្ខាកាម ជាមន្ត្រីគយនិងរដ្ឋាករសរុបចំនួន២៦រូប និងមានគ្រូឧទ្ទេសជាមន្ត្រីបច្ចេកទេសផ្នែកយេនឌ័រនិងចម្រុះភាពនៃអង្គការគយពិភពលោក ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយមូលនិធិសហប្រតិបត្តិការគយកូរ៉េ។ សិក្ខាសាលានេះ ប្រារព្ធឡើងក្នុងគោលបំណងបង្កើនសមត្ថភាព, ជំនាញនិងចំណេះដឹងលើគោលការណ៍ស្តង់ដាជាសកលនៃសមភាពយេនឌ័រនិងចម្រុះភាពដើម្បីជំរុញការអនុវត្តក្នុង **អគរ** ឱ្យកាន់តែប្រសើរឡើងថែមទៀត និងឆ្លើយតបទៅនឹងបរិបទសង្គមនាពេលបច្ចុប្បន្ន។

ថ្លែងក្នុងពិធីបើកសិក្ខាសាលា លោកជំទាវ **ហេង សំអូន** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានជម្រាបជូនអង្គសិក្ខាសាលាថា ការពង្រឹងសមភាពយេនឌ័រត្រូវបានកំណត់ជាអាទិភាពនៅក្នុងឯកសារយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនៃប្រទេសកម្ពុជា, យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីនយោបាយរបស់រដ្ឋាភិបាលអាណត្តិទី៧ និងឯកសារយុទ្ធសាស្ត្រផ្សេងៗរបស់ក្រសួងនានា។ **អគរ** បានប្តេជ្ញាជំរុញសមភាពយេនឌ័រនិងចម្រុះភាព (Gender Equality and Diversity-GED) នៅទូទាំងស្ថាប័នទាំងមូល និងបានបញ្ចូលសកម្មភាពនេះក្នុងយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ ឆ្នាំ២០២៤-២០២៨ នៅចង្កោមសកម្មភាពស្តីពីការលើកកម្ពស់សមភាពយេនឌ័រនៃគោលដៅយុទ្ធសាស្ត្រទី៦ អំពី "សមត្ថភាពស្ថាប័ន"។

គួរបញ្ជាក់ផងដែរថា កន្លងមក **អគរ** តែងយកចិត្តទុកដាក់លើការលើកកម្ពស់សមភាពយេនឌ័រ ដូចជាការផ្តល់ឱកាសដល់មន្ត្រីជាស្ត្រីទទួលបានការតែងតាំង ដំឡើងឋានន្តរសក្តិជាបន្តបន្ទាប់ ចូលរួមធ្វើសេចក្តីសម្រេចចិត្តនានាក្នុងអង្គភាព, ចូលរួមអង្គប្រជុំ សិក្ខាសាលានិងវគ្គបណ្តុះបណ្តាលនានា ទាំងថ្នាក់ជាតិ និងអន្តរជាតិ និងការងារសង្គមជាច្រើន ដោយពុំមានការរើសអើងឡើយ។ នាឱកាសនោះដែរ លោកជំទាវអគ្គនាយករងបានផ្តាំផ្ញើលើកទឹកចិត្តដល់សិក្ខាកាមដែលជាមន្ត្រីគយនិងរដ្ឋាករឱ្យខិតខំក្រេបជញ្ជក់យកចំណេះដឹង និងពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីឈានទៅជាគ្រូបង្គោលលើការងារយេនឌ័រនិងចម្រុះភាពនាពេលអនាគត។

សិក្ខាសាលារយៈពេលបីថ្ងៃនេះ សិក្ខាកាមបានចូលរួមពិភាក្សាជាក្រុម ចែករំលែកការយល់ដឹងនិងបទពិសោធទាក់ទងនឹងប្រធានបទយេនឌ័រ និងបានលើកជាសំណួរ-ចម្លើយយ៉ាងផុលផុស។ ទន្ទឹមគ្នានេះ សិក្ខាកាមបានកត់សម្គាល់នូវចំណុចសំខាន់ៗ យន្តការ វិធីសាស្ត្រ និងអនុសាសន៍មួយចំនួន របស់អ្នកជំនាញការ WCO ដើម្បីពិនិត្យនិងកែសម្រួលនូវផែនការសកម្មភាពលម្អិត សម្រាប់ដាក់ឱ្យអនុវត្តសមភាពយេនឌ័រ និងចម្រុះភាពរបស់ **អគរ** ឱ្យកាន់តែប្រសើរឡើង នាពេលខាងមុខនេះ។ អង្គសិក្ខាសាលាបានបញ្ចប់ប្រកបដោយបរិយាកាសរីករាយ ស្និទ្ធស្នាល ព្រមទាំងទទួលបានផ្លែផ្កាគួរឱ្យកត់សម្គាល់៕




Gender Equality and Diversity (GED)








អគ្គនាយកដ្ឋាន
គយនិងរដ្ឋាករ
កម្ពុជា
General
Department of









# វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ

នៅសាលាជាតិគយ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានរៀបចំ វគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ជូនដល់មន្ត្រីគយនិងរដ្ឋាករចំនួន ៦០រូប ដែលជាសមាជិកក្រុមការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅតាមនាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករមួយចំនួន។ វគ្គបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅស្របតាមផែនការសកម្មភាពឆ្នាំ២០២៥ របស់ **អគរ** ក្នុងគោលបំណងលើកកម្ពស់បន្ថែមនូវចំណេះដឹងនិងសមត្ថភាពរបស់មន្ត្រីគយនិងរដ្ឋាករអំពីច្បាប់ គោលការណ៍ យន្តការ និងវិធីសាស្ត្រស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ នៅក្រោមដែនសមត្ថកិច្ចរបស់ **អគរ** ដើម្បីចូលរួមការពារប្រព័ន្ធហិរញ្ញវត្ថុ និងពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាម ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, លោកអគ្គនាយករង **សែ សុឃន** និងជាប្រធានក្រុមការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រចាំ **អគរ** បានថ្លែងក្នុងពិធីបិទវគ្គបណ្តុះបណ្តាលថា **អគរ** ផ្តល់អាទិភាព និងប្រកាន់ខ្ជាប់ធន្ទះអនុវត្ត ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យដោយអត់ថមថយឡើយ ជាក់ស្តែង **អគរ** បានបញ្ចូលការងារនេះក្នុងឯកសារយុទ្ធសាស្ត្រកែទម្រង់និងទំនើបកម្មគយ ២០២៤-២០២៨ និងផែនការសកម្មភាពប្រចាំឆ្នាំ។ ជាអង្គភាពអនុវត្តច្បាប់លើរំហូរទំនិញឆ្លងកាត់ព្រំដែន **អគរ** មានតួនាទីសំខាន់ក្នុងការទប់ស្កាត់និងបង្ក្រាបអំពើល្មើសពាក់ព័ន្ធការរត់ពន្ធសាច់ប្រាក់ ការប្រើប្រាស់រូបភាពពាណិជ្ជកម្ម ដើម្បីសម្អាតប្រាក់ ក៏ដូចជាការធ្វើពាណិជ្ជកម្មទំនិញយុទ្ធសាស្ត្រដោយគេចវេសទណ្ឌកម្មផ្តត់ផ្គង់ដល់ប្រទេសជាប់ទណ្ឌកម្ម។ ដើម្បីប្រសិទ្ធភាពការងារនេះ **អគរ** ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងកិច្ចសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពពាក់ព័ន្ធទាំងជាតិនិងអន្តរជាតិ និងការលើកកម្ពស់សមត្ថភាពស្ថាប័ននិងវិជ្ជាជីវៈរបស់មន្ត្រីគយនិងរដ្ឋាករ។ ហេតុដូច្នេះ ការបណ្តុះបណ្តាលមន្ត្រីគយនិងរដ្ឋាករត្រូវបន្តអនុវត្តជាប្រចាំ និងសម្របទៅតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (The FATF Recommendations) ដែលបានកែលម្អពីពេលមួយទៅពេលមួយ។

វគ្គបណ្តុះបណ្តាលនេះមានប្រធានបទសំខាន់ៗជាអាទិ៍ សញ្ញាណទូទៅនិងក្របខ័ណ្ឌគតិយុត្តនៃការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ ទំនិញយុទ្ធសាស្ត្រ ការគេចវេះទណ្ឌកម្ម និងវិធីសាស្ត្រស៊ើបអង្កេតប្រតិបត្តិការសង្ស័យ ហើយបានដំណើរការដោយជោគជ័យតាមកម្មវិធី ប្រកបដោយការយកចិត្តទុកដាក់៕











# សេចក្តីប្រកាសព័ត៌មាន សិក្ខាសាលាស្តីពី "ការពង្រឹងពាណិជ្ជកម្ម ធានាសន្តិសុខកុងតឺន័រ និងខ្សែច្រវាក់ផ្គត់ផ្គង់"

នាព្រឹកថ្ងៃសុក្រ ៣កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ នៅសាលាជាតិគយ មានរៀបចំពិធីបិទសិក្ខាសាលាស្តីពី "ការពង្រឹងពាណិជ្ជកម្ម ធានាសន្តិសុខកុងតឺន័រ និងខ្សែច្រវ៉ាក់ផ្គត់ផ្គង់" ក្រោមអធិបតីភាពលោក **ចាន់ សុភាព** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**), ឯកឧត្តម Olivier Richard ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជា និងមានការចូលរួមពីមន្ត្រីជាន់ខ្ពស់តំណាងរដ្ឋបាលគយបារាំង កាណាដា អាល្លឺម៉ង់ កម្ពុជា និងតំណាងកំពង់ផែស្វយ័តភ្នំពេញ។ សិក្ខាសាលានេះប្រព្រឹត្តទៅរយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ ដែលត្រូវបានសហការរៀបចំឡើងដោយ **អគរ** និងមានការគាំទ្រពី Canada Border Services Agency (CBSA) និង Direction Générale des Douanes et Droits Indirects (DGDDI) ក្នុងគោលបំណងពង្រឹងចំណេះដឹងបច្ចេកទេសរបស់មន្ត្រីគយកម្ពុជាពាក់ព័ន្ធនឹងសន្តិសុខកុងតឺន័រ, វិធីសាស្ត្រកំណត់មុខសញ្ញា, ការត្រួតពិនិត្យដោយម៉ាស៊ីនស្កេន X-ray និងការគ្រប់គ្រងហានិភ័យ តាមរយៈការសិក្សាលើទ្រឹស្តីក្នុងថ្នាក់ និងការចុះអនុវត្តជាក់ស្តែងនៅកំពង់ផែស្វយ័តភ្នំពេញ។

ថ្លែងក្នុងពិធីនេះ ឯកឧត្តម **Olivier Richard** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំកម្ពុជាបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងនិងកិច្ចសហការយ៉ាងល្អប្រសើររវាងរដ្ឋបាលគយកម្ពុជានិងរដ្ឋបាលគយបារាំងនាពេលកន្លងមកលើការងារកសាងធនធានមនុស្ស និងពង្រឹងសមត្ថភាពមន្ត្រីគយ និងបានគូសបញ្ជាក់ពីកិច្ចសហប្រតិបត្តិការល្អទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងវប្បធម៌ រវាងប្រទេសបារាំងនិងកម្ពុជា។ ឯកឧត្តមជឿជាក់ថា រដ្ឋបាលគយកម្ពុជានិងរដ្ឋបាលគយបារាំងនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅបន្ថែមទៀត ជាពិសេសពាក់ព័ន្ធនឹងការកសាងសមត្ថភាពនិងការបណ្តុះបណ្តាល ដើម្បីសម្រួលពាណិជ្ជកម្មស្របច្បាប់ ការពារសន្តិសុខ និងទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់។ ដោយឡែក តាមរយៈសាររវីដេអូ ឯកឧត្តម **Christian Desroches** ឯកអគ្គរាជទូតកាណាដាប្រចាំកម្ពុជា បានថ្លែងអំណរគុណដល់ **អគរ** រដ្ឋបាលគយបារាំង និងរដ្ឋបាលគយកាណាដា ដែលបានសហការរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង និងបានគូសបង្ហាញពីការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកាណាដានិងកម្ពុជា តាមរយៈការកសាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្រោមក្របខ័ណ្ឌអាស៊ានកាណាដា ទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគី និងការផ្លាស់ប្តូរបទពិសោធលើការងារបង្ការនិងបង្ក្រាបបទល្មើសឆ្លងដែនជាដើម។ ឯកឧត្តមជឿជាក់ថាកិច្ចសហការនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កំណើនសេដ្ឋកិច្ច និងរក្សាសន្តិសុខនៃប្រទេសទាំងពីរ។

ជាមួយគ្នានេះ លោកអគ្គនាយករង **ចាន់ សុភាព** បានលើកឡើងថា សិក្ខាសាលាដ៏មានសារៈសំខាន់នេះមិនត្រឹមតែបានផ្តល់នូវចំណេះដឹងបច្ចេកទេសគយពាក់ព័ន្ធនឹងការងារសន្តិសុខ និងកំណត់ហានិភ័យប៉ុណ្ណោះទេ ថែមទាំងបានពង្រឹងការយល់ដឹង និងការជឿទុកចិត្តគ្នាទៅវិញទៅមករវាង **អគរ** និងរដ្ឋបាលគយនៃប្រទេសដៃគូពាណិជ្ជកម្ម ដែលជាកត្តាដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងការសម្រួលពាណិជ្ជកម្មស្របច្បាប់ ធានាសន្តិសុខ និងសុចរិតភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់អន្តរជាតិ។ លោកអគ្គនាយករង ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតបារាំង, ឯកឧត្តមឯកអគ្គរាជទូតកាណាដាប្រចាំកម្ពុជា, លោក **Dieter Wurche** តំណាងស្ថានទូតអាល្លឺម៉ង់ប្រចាំប្រទេសថៃ

ព្រមទាំងអ្នកជំនាញការទាំងអស់ ចំពោះវត្តមាន និងការគាំទ្ររៀបចំសិក្ខាសាលាឱ្យទទួលបានលទ្ធផលជាផ្លែផ្កា។ បន្ថែមលើនេះ លោកអគ្គនាយករង ក៏បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ **អគរ** ក្នុងការបន្តបង្កើនកិច្ចសហប្រតិបត្តិការជាមួយ CBSA, DGDDI និងដៃគូអន្តរជាតិផ្សេងទៀត ដើម្បីដោះស្រាយហានិភ័យដែលកំពុងកើតមាន រួមទាំងការរត់ពន្ធ ឧក្រិដ្ឋកម្មឆ្លងដែន និងការគំរាមកំហែងតាមប្រព័ន្ធអ៊ីនធឺណិត។

ជាកិច្ចបញ្ចប់ លោកអគ្គនាយករងបានសម្តែងនូវការកោតសរសើរចំពោះការចូលរួមយ៉ាងសកម្មរបស់មន្ត្រីគយទាំងអស់ និងបានលើកទឹកចិត្តឱ្យសិក្ខាកាមយកចំណេះដឹង និងជំនាញថ្មីៗដែលទទួលបានពីសិក្ខាសាលានេះទៅអនុវត្តក្នុងកិច្ចការប្រចាំថ្ងៃ ដើម្បីពង្រឹងការងារគ្រប់គ្រងហានិភ័យ និងដំណើរការត្រួតពិនិត្យកុងតឺន័រឱ្យកាន់តែមានប្រសិទ្ធភាព សំដៅឆ្ពោះទៅរកអនាគតមួយដែលសន្តិសុខពាណិជ្ជកម្ម និងការសម្រួលពាណិជ្ជកម្មដើរទន្ទឹមគ្នា ទាំងសម្រាប់កំណើនសេដ្ឋកិច្ច និងការការពារសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនោះដែរ បន្ទាប់ពីពិធីបិទសិក្ខាសាលាជាផ្លូវការ លោកអគ្គនាយករង **ចាន់ សុភាព** តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានអនុញ្ញាតឱ្យលោក **Dieter Wurche** មន្ត្រីសម្របសម្រួលគយអាឡឺម៉ង់ នៃស្ថានទូតអាឡឺម៉ង់ប្រចាំទីក្រុងបាងកកប្រទេសថៃ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយអាឡឺម៉ង់ និង **អគរ** ផងដែរ។


















កំពង់ផែស្វយ័តភ្នំពេញ
Phnom Penh Autonomous Port (LM17)








NUCTECH
CHINA AID


NUCTECH




Hapag-Lloyd
TRITON

# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ"

នាថ្ងៃអង្គារ ៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលាជាតិគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ" ក្រោមអធិបតីភាពលោកអគ្គនាយករង **ផា អេងថ័ង** តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ សិក្ខាសាលានេះ រៀបចំឡើងជាលើកទី២ ប្រចាំឆ្នាំ២០២៥ អនុលោមតាមផែនការសកម្មភាព ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ដំណាក់កាលទី៤ សម្រាប់មន្ត្រីគយនិងរដ្ឋាករដែលកំពុងបម្រើការងារនៅទីចាត់ការកណ្តាល និងអង្គភាពគយនិងរដ្ឋាករមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សរុបប្រមាណជាង ១០០រូប ដើម្បីផ្សព្វផ្សាយនូវបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកគយសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសហគ្រាសធុនតូចនិងមធ្យម ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ថ្លែងក្នុងពិធីបើកសិក្ខាសាលា លោកអគ្គនាយករង **ផា អេងថ័ង** បានជម្រាបជូនអង្គសិក្ខាសាលាទាំងមូលអំពីវឌ្ឍនភាពថ្មីៗ ពាក់ព័ន្ធនឹងការផ្តល់ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការវិនិយោគ ដែលបានជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបង្កើននូវចំណូលសម្រាប់ប្រជាពលរដ្ឋជាពលករ និងកម្មករក្នុងវិស័យទាំងនេះ។អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការពិនិត្យនិងផ្តល់យោបល់លើការស្នើសុំការលើកទឹកចិត្តពន្ធនិងអាករនេះ នៅគ្រប់ដំណាក់កាល សម្រាប់គម្រោងវិនិយោគ និងសហគ្រាសធុនតូចនិងមធ្យម។ ទន្ទឹមនឹងការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបន្តអភិវឌ្ឍនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបទប្បញ្ញត្តិពាក់ព័ន្ធ សម្រាប់គាំទ្រកិច្ចដំណើរការបំពេញបែបបទបញ្ចេញទំនិញពីគយ ឱ្យកាន់តែមានភាពទុកចិត្តបានរហ័សសុវត្ថិភាពនិងមិនមានបន្ទុកដល់វិស័យឯកជន ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ និងកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម, កាត់បន្ថយចំណាយឡូជីស្ទីក, កែលម្អបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា ក្រោមការដឹកនាំប្រកបដោយថាមពលរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។

សិក្ខាកាមនៃអង្គសិក្ខាសាលា នឹងបានទទួលនូវចំណេះបន្ថែមលើប្រធានបទសំខាន់ៗដូចជា៖ ការលើកទឹកចិត្តផ្នែកគយសម្រាប់គម្រោងវិនិយោគក្រោមក្របខ័ណ្ឌច្បាប់វិនិយោគ និងអនុក្រឹត្យពាក់ព័ន្ធនឹងការអនុវត្តច្បាប់វិនិយោគ, ការត្រួតពិនិត្យបញ្ជីមេមុខទំនិញស្នើសុំរបស់គម្រោងវិនិយោគ, កិច្ចដំណើរការស្នើសុំលិខិតអនុញ្ញាតតាមប្រព័ន្ធបញ្ជរតែមួយជាតិ, យន្តការគ្រប់គ្រងការលើកទឹកចិត្តពន្ធគយនៅក្របខ័ណ្ឌអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត, ការលើកទឹកចិត្តសម្រាប់ការវិនិយោគនៅខេត្តព្រះសីហនុ និងការវិនិយោគកនៅភូមិភាគឦសាន, និងការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូចនិងមធ្យមជាដើម។ ចំណេះដឹងនាពេលនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់បន្ថែមទៀតសម្រាប់មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រើប្រាស់និងអនុវត្តក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការលើកទឹកចិត្តពន្ធនិងអាករ, ការកៀរគរចំណូលជូនរដ្ឋ និងបង្កើនកិច្ចសម្រួលពាណិជ្ជកម្ម ដោយធានាបាននូវតុល្យភាព និងភាពស្មើគ្នាក្នុងការធ្វើធុរកិច្ចវិនិយោគនៅកម្ពុជា។

ជាចុងបញ្ចប់ លោកអគ្គនាយករង បានផ្តាំផ្ញើ និងលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់ ខិតខំត្រងត្រាប់ស្តាប់ សាកសួរ

ឱ្យបានផុលផុស និងចែករំលែកបទពិសោធន៍ការងារថ្មីៗ ជាក់ស្តែង ពាក់ព័ន្ធនឹងការពង្រឹងការគ្រប់គ្រងការលើក ទឹកចិត្តពន្ធនិងអាករ នៅគ្រប់ដំណាក់កាល រួមទាំងការអនុវត្តកិច្ចដំណើរការស្នើសុំនៅកម្រិតអនុគណៈកម្មាធិការ វិនិយោគរាជធានី-ខេត្តផងដែរ។












# សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "សេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងអនាគត"

នាព្រឹក ថ្ងៃសៅរ៍ ១រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**), លោក **សៃ សុឃន** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានយុវជន **អគរ** បានដឹកនាំរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "សេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងអនាគត"ជូនដល់យុវជន**អគរ**ចំនួន១៤០នាក់ដោយមានការចូលរួមធ្វើបទឧទ្ទេសពី លោក **អៀច សេដ្ឋា** អគ្គនាយករងនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សិក្ខាសាលាផ្សព្វផ្សាយរយៈពេលមួយព្រឹកនេះ មានគោលបំណងចូលរួមអនុវត្តទិសដៅការងារដែលបានដាក់ចេញដោយអង្គសន្និបាតរបស់យុវជនថ្នាក់កណ្ដាល ដើម្បីលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់យុវជន **អគរ** អំពីបរិបទនៃឌីជីថ-លូបនីយកម្ម ជាពិសេសសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។

ថ្លែងក្នុងពិធីបើកសិក្ខាសាលា លោក **សៃ សុឃន** បានគូសរំលេចថា នៅក្នុងបរិបទប្រកួតប្រជែងខ្លាំង សកលភាវូបនីយកម្ម និងឌីជីថលូបនីយកម្ម កម្ពុជាកំពុងផ្តល់អាទិភាពខ្ពស់ដល់សេដ្ឋកិច្ចឌីជីថល ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងអាទិភាពគន្លឹះទាំង៥ (មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា) នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងទស្សនៈដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ច្បាស់ថា "សេដ្ឋកិច្ចឌីជីថល គឺជាប្រភពកំណើនសេដ្ឋកិច្ចថ្មី"។ ឆ្លៀតក្នុងឱកាសនោះ លោក **សៃ សុឃន** បានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជានិច្ចកាលតែងយកចិត្តទុកខ្ពស់លើការកសាងសមត្ថភាពរបស់យុវជនជំនាន់ក្រោយ និងជូនឯកឧត្តមបណ្ឌិត **ហ៊ើល ចំរើន** រដ្ឋលេខាធិការ និងជាប្រធានយុវជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានសម្របសម្រួលនិងផ្ដល់ការគាំទ្រដល់ការរៀបចំអង្គសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។

នៅក្នុងបទបង្ហាញជូនអង្គសិក្ខាសាលា លោក **អៀច សេដ្ឋា** បានអធិប្បាយអំពីប្រធានបទសំខាន់ៗមានជាអាទិ៍បដិវត្តឧស្សាហកម្មនិងឌីជីថល, តួនាទីនៃឌីជីថលក្នុងសង្គមនិងសេដ្ឋកិច្ច, ក្របខ័ណ្ឌគោលនយោបាយ សេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, និងតួនាទីយុវជនក្នុងការរៀបចំខ្លួនសម្រាប់បរិបទសេដ្ឋកិច្ចឌីជីថលជាដើម។ បន្ទាប់ពីការធ្វើបទបង្ហាញ វាគ្មិននិងសិក្ខាកាមបានចូលរួមពិភាក្សា និងចែករំលែកបទពិសោធន៍ដ៏មានតម្លៃជាច្រើនផងដែរ។

សិក្ខាសាលាបានប្រព្រឹត្តទៅដោយជោគជ័យ ធ្វើឱ្យសិក្ខាកាមទទួលបានចំណេះដឹង និងការយល់ដឹងកាន់តែទូលំទូលាយអំពីសេដ្ឋកិច្ចឌីជីថល។ ចំណេះដឹងទាំងនេះនឹងជួយអភិវឌ្ឍយុវជន **អគរ** អាចក្លាយជាយុវជនឆ្នើម និងជាមន្ត្រីមានគុណវុឌ្ឍ និងសមត្ថភាពបំពេញភារកិច្ចបានកាន់តែប្រសើរ៕











# សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល "Training of Trainers"

ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ នៅសាលាជាតិគយបានរៀបចំសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលគ្រូបង្គោល Training of Trainers ជូនមន្ត្រីគយនិងរដ្ឋាករដែលជាគ្រូបន្តវេន ក្រោមកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(**អគរ**), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង រដ្ឋបាលគយជប៉ុន។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់សមត្ថភាពចំណេះដឹងផ្នែកបច្ចេកទេស និងវិធីសាស្ត្របង្រៀន ចិត្តសាស្ត្រ និងគរុកោសល្យក្នុងការអប់រំជូនដល់មន្ត្រីគយនិងរដ្ឋាករកម្ពុជាដែលជាគ្រូបង្គោល និងគ្រូជំនួយប្រចាំ **អគរ** ចំនួន ៦០រូប។

ក្នុងនាមឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា លោក **ផា អេងម៉េង** អគ្គនាយករងនៃ **អគរ** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបន្តវេនលើកនេះដែលមានគោលដៅចម្បងគឺការជួយបណ្តុះបណ្តាល នូវប្រេកពធនធានមនុស្សជំនាន់ក្រោយដែលពោរពេញដោយចំណេះដឹង សមត្ថភាពជំនាញ និងវិជ្ជាជីវៈច្បាស់លាស់ដើម្បីបន្តអនុវត្តនូវបេសកកម្មចម្បងរបស់ **អគរ** ឱ្យកាន់តែមានប្រសិទ្ធភាព និងទាន់សម័យ ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន។ លោកអគ្គនាយករងបានលើកទឹកចិត្តដល់មន្ត្រីគយដែលជាសិក្ខាកាមទាំងអស់ឱ្យយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ក្នុងការក្រេបយកចំណេះដឹង បទពិសោធន៍បន្ថែមទៀតពីគ្រូឧទ្ទេសជាតិ និងអន្តរជាតិដែលសុទ្ធតែរៀមច្បងមានបទពិសោធន៍ជ្រៅជ្រះ ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាជាក្រុមហើយបន្តចែករំលែកចំណេះដឹងដែលទទួលបានក្នុងអំឡុងពេលសិក្សាទៅចែករំលែកដល់សហការី និងអង្គភាព ដើម្បីយកទៅអនុវត្តក្នុងការងារប្រចាំថ្ងៃរបស់ខ្លួនឆ្ពោះទៅរកការកែលម្អប្រតិបត្តិការ និងសម្រេចបានគោលដៅអភិវឌ្ឍន៍ធនធានមនុស្សរបស់ **អគរ**។

សិក្ខាសាលារយៈពេល ៤ ថ្ងៃនេះ បានបង្ហាញពីមាតិកាវិជ្ជាជីវៈសំខាន់ៗ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍគ្រូឧទ្ទេសផ្ទៃក្នុងរបស់ **អគរ** ដូចជា វិធីសាស្ត្របង្រៀនសម័យថ្មីការវិភាគអំពីតម្រូវការបណ្តុះបណ្តាល ការរៀបចំកម្មវិធីបណ្តុះបណ្តាល ការគ្រប់គ្រងថ្នាក់រៀន ការសិក្សាអំពីបច្ចេកទេសនៃការធ្វើបទបង្ហាញ វិធីសាស្ត្រសិក្សានិងការបង្រៀនសម្រាប់មនុស្សពេញវ័យ, ការសិក្សាអំពីចិត្តវិជ្ជានិងចិត្តសាស្ត្រគរុកោសល្យក្នុងការអប់រំរបស់គ្រូគរុកោសល្យថ្នាក់ជាតិ និងគ្រូឧទ្ទេសអន្តរជាតិមកពីវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ និងជំនាញការគយជប៉ុន។

ក្នុងនាមរដ្ឋបាលគយកម្ពុជា លោកអគ្គនាយករង **អគរ** បានវាយតម្លៃខ្ពស់ចំពោះការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីរដ្ឋបាលគយជប៉ុន និង JICA ក្នុងការរៀបចំសិក្ខាសាលា Training of Trainers (TOT) ដ៏មានសារៈសំខាន់នេះ។ ការចែករំលែកបទពិសោធន៍ និងជំនាញវិជ្ជាជីវៈពីគ្រូគរុកោសល្យថ្នាក់ជាតិ និងពីជំនាញការគយជប៉ុនបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់មន្ត្រីគយចូលរួមក្នុងការកែលម្អជំនាញបង្រៀន និងបង្កើនសមត្ថភាពបណ្តុះបណ្តាលផ្ទៃក្នុងរបស់ **អគរ**។ ទន្ទឹមនេះ ចំណេះដឹងនិងបទពិសោធដែលទទួលបានពីសិក្ខាសាលានេះ នឹងមានតម្លៃយ៉ាងខ្លាំងក្នុងការរៀបចំប្រព័ន្ធបណ្តុះបណ្តាលរបស់ **អគរ** ប្រចាំឆ្នាំឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែរឹងមាំថែមទៀត។






Objectives of this session






# សិក្ខាសាលាស្ដីពី "ការសិក្សារយៈពេលបំពេញបែបបទ បញ្ចេញទំនិញ លើកទី៥"

នាព្រឹកថ្ងៃពុធ ៥រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ នៅសាលាជាតិគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) បានរៀបចំសិក្ខាសាលាស្ដីពី "ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ លើកទី៥" ក្រោមអធិបតីភាព លោក **ផា អេងម៉េង** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីគយនិងរដ្ឋាករ អ្នកជំនាញការ JICA រយៈពេលវែងប្រចាំ **អគរ** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ សភាពាណិជ្ជកម្មកម្ពុជា និងវិស័យឯកជនពាក់ព័ន្ធ សរុបប្រមាណ ១៥៤ រូប។

សិក្ខាសាលានេះ មានគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍នៃការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញនាពេលកន្លងមក ការបំពេញបែបបទបញ្ចេញទំនិញពីគយ ការចេញអាជ្ញាបណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាត និងឯកសារផ្សេងៗ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងការចាប់ផ្តើម "ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញលើកទី៥ ក្នុងឆ្នាំ២០២៥"។

ថ្លែងក្នុងពិធីបើកអង្គសិក្ខាសាលា លោក **ផា អេងម៉េង** បានគូសបញ្ជាក់ថា ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញនៅក្នុងឆ្នាំ២០២៥នេះ ត្រូវបានរៀបចំឡើងដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក និងមគ្គុទេសក៍ស្តីពីការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញរបស់អង្គការគយពិភពលោក។ ការសិក្សានាពេលកន្លងមក **អគរ** ទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការគយពិភពលោក ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងដំណើរការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញ។ ការសិក្សានេះ ជាមធ្យោបាយសម្រាប់វាស់វែងរយៈពេល ស្វែងរកបញ្ហាប្រឈមក្នុងការបំពេញបែបបទ និងដាក់ចេញនូវអនុសាសន៍នានា ដើម្បីកែលម្អនីតិវិធីការងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ចូលរួមផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាតាមរយៈការកាត់បន្ថយការចំណាយនិងពេលវេលាដែលជាបញ្ហាប្រឈមរបស់ធុរជនក្នុងការធ្វើពាណិជ្ជកម្ម។

នៅក្នុងអង្គសិក្ខាសាលា មន្ត្រីជំនាញពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអ្នកជំនាញការ JICA រយៈពេលវែងប្រចាំ **អគរ** បានធ្វើការចែករំលែកនូវបទពិសោធន៍ និងវិធីសាស្ត្រនៃការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញរួមមានការរៀបចំកម្រងសំណួរ ការដកយកសំណាកគំរូ ការប្រមូលនិងការបញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យក្នុងប្រព័ន្ធរបស់អង្គការគយពិភពលោក។

ថ្លែងក្នុងពិធីបិទអង្គសិក្ខាសាលា លោក **សៃ សុឃន** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានគូសបញ្ជាក់ថា ការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញពុំមែនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **អគរ** តែមួយទេ គឺសិក្សាអំពីនីតិវិធីមុនពេលទំនិញមកដល់ ដែលរួមមានការស្នើសុំនិងចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ លិខិតអនុញ្ញាតរបស់ក្រសួង-

ស្ថាប័នពាក់ព័ន្ធ រហូតដល់ការបំពេញបែបបទបញ្ចេញទំនិញពីគយ សំដៅរកឱ្យឃើញនូវរយៈពេលដែលបានប្រើប្រាស់ និងស្វែករកចំណុចរាំងស្ទះដែលបានកើតឡើងក្នុងដំណាក់កាលនីមួយៗ។ ជាចុងក្រោយលោក **សែ សុឃន** បានស្នើអង្គសិក្ខាសាលាចូលរួមសហការឱ្យបានពេញលេញ ដើម្បីឱ្យការសិក្សានេះប្រព្រឹត្តទៅបានរលូននិងទទួលបានលទ្ធផលជាផ្លែផ្កា និងចូលរួមដោះស្រាយនូវបញ្ហានានាដែលបានរកឃើញ ដើម្បីឱ្យការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលតាមរយៈការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាទទួលបានជោគជ័យ។













# ផ្នែកទី៣

## លទ្ធផលការងារសម្រេចបានមួយចំនួន របស់បណ្ដានាយកដ្ឋាន និងអង្គភាពមូលដ្ឋាន

# ការងារសវនកម្មផ្ទៃក្នុងរបស់លេខាធិការដ្ឋាន

ក្នុងឆ្នាំ២០២៥ នេះ ក្រុមសវនកម្មផ្ទៃក្នុង **អគរ** បានអនុវត្តការងារធ្វើសវនកម្មផ្ទៃក្នុងនៅអង្គភាពគយនិងរដ្ឋាករ ចំនួន ១១សវនដ្ឋាន តាមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ តាមផែនការកំណត់ លោកអគ្គនាយករង **គាំ ច័ន្ទកុសល** ជាប្រធានសវនកម្មផ្ទៃក្នុង **អគរ** បានដឹកនាំក្រុមការងារចុះធ្វើសវនកម្មនៅសវនដ្ឋាន តាមកាលវិភាគដែលបានកំណត់ ដូចខាងក្រោម៖

- ក្រុមសវនកម្មផ្ទៃក្នុងទី១ ដឹកនាំក្រុមដោយលោក **ដួង បូលីន** នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ បានចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញនិងថ្ងៃទី១៦ខែធ្នូឆ្នាំ២០២៥ បានចុះទៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ហុង ឡេងហួរ
- ក្រុមសវនកម្មផ្ទៃក្នុងទី២ ដឹកនាំក្រុមដោយលោក **អ៊ុក គឹមសៀ** នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ បានចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង និងបន្តចុះទៅការិយាល័យគយនិងរដ្ឋាករបាវិត និងការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍
- ក្រុមសវនកម្មផ្ទៃក្នុងទី៦ ដឹកនាំក្រុមដោយលោក **ណាំ សុលាង** នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥ បានចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ ចុះទៅការិយាល័យគយនិងរដ្ឋាករផែស្ងួត តេង ឡាយ និងថ្ងៃទី១៥ខែធ្នូ ឆ្នាំ២០២៥ ចុះទៅការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន
- ក្រុមសវនកម្មផ្ទៃក្នុងទី៧ ដឹកនាំក្រុមដោយលោកស្រី **សុខ លក្ខស្មី** នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥ បានចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ ចុះទៅសាខាគយនិងរដ្ឋាករខេត្តកណ្ដាល និងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ ចុះទៅការិយាល័យគយនិងរដ្ឋាករជ្រៃធំ។

នៅក្នុងកិច្ចប្រជុំបើកដំណើរការធ្វើសវនកម្មផ្ទៃក្នុង, លោកអគ្គនាយករង បានផ្ដល់ការណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីគយនិងរដ្ឋាករដែលជាសវនដ្ឋាន ឱ្យយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តការងារឱ្យបានត្រឹមត្រូវតាមនីតិវិធីគយ និងបទប្បញ្ញត្តិជាធរមាន និងត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការគយនិងរដ្ឋាករ។ ទន្ទឹមនេះ លោកអគ្គនាយករង ក៏បានសង្កត់ធ្ងន់លើមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាកិច្ចប្រជុំប្រចាំខែកន្លងមក ដែលតែងតែក្រើនរំលឹកឱ្យយកចិត្តទុកដាក់លើការខិតខំអនុវត្តការងារប្រមូលចំណូលចូលថវិកាជាតិ និងការផ្ដល់សេវាសាធារណៈឱ្យបានល្អប្រសើរ និងឆាប់រហ័ស ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ប្រកបដោយការទទួលខុសត្រូវ ក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការនានាដែលបានដាក់ចេញដោយ **អគរ**។

ចុងបញ្ចប់នៃកិច្ចប្រជុំ លោកអគ្គនាយករង បានថ្លែងអំណរគុណចំពោះកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅពីលោកប្រធានសវនដ្ឋាន និងសហការី ហើយបានស្នើឱ្យមន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធសហការសម្របសម្រួលជាមួយក្រុមសវនកម្មផ្ទៃក្នុងរហូតដល់ការចុះបេសកកម្មបានបញ្ចប់ដោយជោគជ័យ។

នាព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ អមមន្ត្រីជំនាញមួយចំនួន បានទទួលជួបប្រជុំជាមួយគណៈប្រតិភូសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយ លោកជំទាវ **ម៉ៅ ម៉ូនីឡែន** អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ស្ដីពីកិច្ចប្រជុំដំបូងដើម្បីពិភាក្សាលើដំណើរការអនុវត្តការងារសវនកម្មនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។







ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំអមមន្ត្រីជំនាញមួយចំនួន ជួបប្រជុំជាមួយគណៈប្រតិភូសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយ លោកជំទាវ **ង៉ែត ម៉ូរីឡែន** អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង








សកម្មភាពលោកអគ្គនាយករង គាំ ច័ន្ទកុសល ដឹកនាំចុះទៅបើកដំណើរការធ្វើសវនកម្មផ្ទៃក្នុង នៅសាខាគយនិងរដ្ឋាករខេត្តកណ្ដាល និងការិយាល័យគយនិងរដ្ឋាករជ្រៃធំ







សកម្មភាពលោក ដួង បូលីន ដឹកនាំក្រុមសវនកម្មផ្ទៃក្នុងទី១ ចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ និងការិយាល័យគយនិងរដ្ឋាករផែស្ងួត ហុង ឡេងហួរ








សកម្មភាពលោក អ៊ុក គឹមសៀ ដឹកនាំក្រុមសវនកម្មផ្ទៃក្នុងទី២ ចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង, ការិយាល័យគយនិងរដ្ឋាករបាវិត និងការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍









សកម្មភាពលោក ណាំ សុលាង ដឹកនាំក្រុមសវនកម្មផ្ទៃក្នុងទី៦ ចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត តិច ស៊្រុន,
ការិយាល័យគយនិងរដ្ឋាករផែស្ងួត តេង ឡាយ និង ការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន









សកម្មភាពលោកស្រី សុខ លក្ខស្មី ដឹកនាំក្រុមសវនកម្មផ្ទៃក្នុងទី៧ ចុះទៅធ្វើសវនកម្មផ្ទៃក្នុងនៅការិយាល័យគយនិងរដ្ឋាករប្រចាំ
តំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា រីសស,សាខាគយនិងរដ្ឋាករខេត្តកណ្ដាល និងការិយាល័យគយនិងរដ្ឋាករជ្រៃធំ

# ការងារគ្រប់គ្រងហិរញ្ញវត្ថុនិងបុគ្គលិក

នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារហិរញ្ញវត្ថុនិងបុគ្គលិក ដែលគ្រប់គ្រងលើការងារផ្នែករដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ និងការអភិវឌ្ឍស្ថាប័នរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ក្រោមការដឹកនាំរបស់លោក **ឪ ចណ្ណា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានអនុវត្តការងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ នៅសាលប្រជុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាន់ទី៩ នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានប្រារព្ធពិធីប្រកាសតែងតាំងនិងផ្ទេរភារកិច្ចមន្ត្រីរាជការគយនិងរដ្ឋាករ ចំនួន ១២៧ នាក់ ក្រោមអធិបតីភាពរបស់ លោក **ឪ ចណ្ណា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអមដោយលោកអនុប្រធាននាយកដ្ឋាន ជំនួយការនាយកដ្ឋាន ប្រធានការិយាល័យ និងក្រុមការងាររបស់នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក។ ក្នុងពិធីខាងលើ លោកប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិកបានមានមតិណែនាំដល់មន្ត្រីទើបទទួលភារកិច្ចថ្មី ត្រូវខិតខំបំពេញការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ជាពិសេសលើការងារប្រមូលចំណូលចូលថវិកាជាតិ។



នារសៀល ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅបន្ទប់ប្រជុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាន់ទី១៨ លោកអគ្គនាយករង **ផា អេងម៉េង** បានដឹកនាំកិច្ចប្រជុំពិនិត្យសេចក្តីព្រាងភារកិច្ចលម្អិតរបស់នាយកដ្ឋាននិងសាលាជាតិគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែលនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានធ្វើការបូកសរុបបន្ទាប់ពីបានទទួលធាតុចូលពីអង្គភាពពាក់ព័ន្ធ។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធាននាយកដ្ឋាន លោកនាយកសាលាជាតិ លោកអនុប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធដើម្បីពិនិត្យរួមគ្នាលើសេចក្តីព្រាងភារកិច្ចលម្អិតរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមុនដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាពិនិត្យសម្រេច និងបញ្ជូនទៅអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ចូលក្នុងសេចក្តីព្រាងអនុក្រឹត្យកែសម្រួលថ្មីស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។









អនុវត្តតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លោក **សុខ ទ្រី** និងលោក **ជា សំអុន** បានដឹកនាំក្រុមការងារនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ចុះពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារសាងសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗរបស់អង្គភាពគយនិងរដ្ឋាករដូចខាងក្រោម៖







១. នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគាររដ្ឋបាលថ្មី សម្រាប់សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដែលជារួមការងារសម្រេចបានប្រមាណជាង ៦០% នៃការងារទាំងមូល។

២. នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករអូរយ៉ាដាវ ដែលជារួមការងារសម្រេចបានប្រមាណ ៤៥% នៃការងារទាំងមូល។

៣. នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយនិងរដ្ឋាករត្រពាំងក្រៀល ដែលជារួមការងារសម្រេចបានប្រមាណ ៤៣% នៃការងារទាំងមូល។

៤. នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយ និងរដ្ឋាករស្រែអំបិល ដែលជារួមការងារសម្រេចបានប្រមាណ ៤៣% នៃការងារទាំងមូល។

៥. នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគាររដ្ឋបាលថ្មី អគារស្នាក់នៅ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់សាខាគយ និងរដ្ឋាករខេត្តកំពត ដែលជារួមការងារសម្រេចបានប្រមាណ ៤០% នៃការងារទាំងមូល។

៦. នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥៖ បានចុះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការងារសាងសង់អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗសម្រាប់ការិយាល័យគយ និងរដ្ឋាករតន់ហាន់ដែលជារួមការងារសម្រេចបានប្រមាណ ៤៦% នៃការងារទាំងមូល។

ក្នុងអំឡុងពេលចុះត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងារសាងសង់ខាងលើ ក្រុមការងារបានពិនិត្យឃើញកន្លែងខ្វះខាតមួយចំនួនក្នុងការសាងសង់ និងបានណែនាំឱ្យក្រុមហ៊ុនសាងសង់កែលម្អបន្ថែម និងត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការបន្តសាងសង់ឱ្យស្របតាមបទដ្ឋានបច្ចេកទេស និងតាមផែនការដែលបានគ្រោងទុក។









# ការងារផែនការនិងបច្ចេកទេស

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៥ នេះ នាយកដ្ឋានផែនការ និងបច្ចេកទេស បានរៀបចំ និងចូលរួមសហការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាដូចមានរៀបរាប់ខាងក្រោម៖

១. សិក្ខាសាលាស្តីពី "Anti-Illicit Trade Workshop" នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥ ដោយមានកិច្ចសហការជាមួយសមាគមធុរកិច្ចជប៉ុន(JBAC) ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ Hyatt Regency Phnom Penh។ សិក្ខាសាលានេះមានការចូលរួមពីមន្ត្រីគយនិងរដ្ឋាករជាជនបង្គោលកម្មសិទ្ធិបញ្ញា ចំនួន ៣០រូប។














២. សិក្ខាសាលាផ្សព្វផ្សាយមុខងារប្រព័ន្ធស្នើសុំវិធានបញ្ជាក់ជាមុន ជូនដល់វិស័យឯកជន នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយមានការចូលរួមដោយផ្ទាល់ពីលោកអនុប្រធានសភាពាណិជ្ជកម្មកម្ពុជា, លោកប្រធានសមាគមកស្តុភារកម្មកម្ពុជា CLA, និងលោក លោកស្រី ជាតំណាងសមាគមពាណិជ្ជកម្មអឺរ៉ុប EUROCHAM, តំណាងសភាពាណិជ្ជកម្មចិនប្រចាំនៅកម្ពុជា CCCC, តំណាងសមាគមន៍ ធុរកិច្ចជប៉ុននៅកម្ពុជា JBAC, តំណាងសមាគមន៍អេឡិចត្រូនិចនិងបច្ចេកវិទ្យាកម្ពុជា CETA ព្រមទាំងលោក លោកស្រី ជាប្រធានក្រុមហ៊ុននាំចេញនាំចូល ឬតំណាង ធុរជន និងជើងសាគយ សរុបចំនួន ៧៥ រូប។









៣. វគ្គបណ្ដុះបណ្ដាលស្ដីពីចំណាត់ថ្នាក់ទំនិញ តម្លៃគិតពន្ធគយ វិធានដើមកំណើតទំនិញ និងកម្មសិទ្ធិបញ្ញា ចាប់ពីថ្ងៃទី៩ដល់ថ្ងៃទី១០ខែធ្នូឆ្នាំ២០២៥នៅសាលាជាតិគយ សម្រាប់មន្ត្រីគយនិងរដ្ឋាករ ជាថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេស មកពីនាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ ទូទាំងប្រទេសសរុប ១០០រូប។









៤. វគ្គបណ្តុះបណ្តាលស្តីពីចំណាត់ថ្នាក់ទំនិញ តម្លៃគិតពន្ធគយ វិធានដើមកំណើតទំនិញ និងកម្មសិទ្ធិបញ្ញា នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ នៅសាលាជាតិគយ ជូនដល់វិស័យឯកជនសរុបប្រមាណ ១២០រូប ដែលមានសមាសភាពមកពីសភាពាណិជ្ជកម្មកម្ពុជា(CCC),សមាគមភស្តុភារកម្មកម្ពុជា (CLA), សភាពាណិជ្ជកម្មអាម៉េរិក (AmCham), សភាពាណិជ្ជកម្មអឺរ៉ុប (EuroCham), សភាពាណិជ្ជកម្មចិនប្រចាំនៅកម្ពុជា (CCCC), សមាគមធុរកិច្ចជប៉ុននៃកម្ពុជា (JBAC), ទីភ្នាក់ងារជំរុញពាណិជ្ជកម្ម និងការវិនិយោគកូរ៉េប្រចាំនៅកម្ពុជា (KOTRA),ក្រុមហ៊ុននាំចេញ-នាំចូល នីតិបុគ្គល និងរូបវន្តបុគ្គលជើងសាគយមួយចំនួន។













# ការងាររដ្ឋាករ

នាយកដ្ឋានរដ្ឋាករនៅក្រោមការដឹកនាំរបស់លោក **អន ស៊ីនួន** រួមនឹងមន្ត្រីក្រោមឱវាទ បានអនុវត្តតួនាទីនិងភារកិច្ចប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ និងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន លើការងារគ្រប់គ្រងនិងប្រមូលពន្ធអាករពីការនាំចេញ នាំចូល ការចែកចាយ ការចរាចរដឹកជញ្ជូន និងសន្និធិផលិតផលតេលសិលានិងថាមពល ព្រមទាំងការគ្រប់គ្រងកិច្ចដំណើរការអគារលក់ទំនិញរួចពន្ធ និងការស្រាវជ្រាវបង្ក្រាបបទល្មើសគយពាក់ព័ន្ធ។ លទ្ធផលការងារសំខាន់ៗដែលសម្រេចបាន មានដូចខាងក្រោម៖

## ១- ការកៀរគរចំណូល

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នាយកដ្ឋានរដ្ឋាករ អនុវត្តការប្រមូលចំណូលបានលទ្ធផលល្អប្រសើរបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ក៏ដូចជាក្នុងត្រីមាសទី៣ ឆ្នាំ២០២៥ ។ ជាពិសេសនោះ លទ្ធផលនៃការប្រមូលចំណូលក្នុងរយៈពេលពេញមួយឆ្នាំ២០២៥ ក៏មានកំណើនជាងឆ្នាំ២០២៤ ផងដែរ។ ការប្រមូលចំណូលនៅក្នុងត្រីមាសទី៤ និងប្រចាំឆ្នាំ២០២៥ មានដូចខាងក្រោម៖

- ត្រីមាសទី៤ ឆ្នាំ២០២៥ បានចំនួន ៧២៨ ៩៤២ លានរៀល ឬ ១០១,២% នៃផែនការ ដែលកើនឡើងជាងត្រីមាសទី៤ ឆ្នាំ២០២៤ ប្រមាណ ៥២ ២៤២ លានរៀល ឬ ៧,៦%។
- រយៈពេល១២ខែ ឆ្នាំ២០២៥ បានចំនួន ២ ៨០២ ២៨០ លានរៀល ឬ ១០០,៤% នៃផែនការ ដែលកើនឡើងជាងរយៈពេល១២ខែ ឆ្នាំ២០២៤ ប្រមាណ ៣៨ ៣០០ លានរៀល ឬ ១,៤%។

បន្ថែមលើការប្រមូលចំណូលពីសកម្មភាពនាំចូល ការិយាល័យបង្ការបង្ក្រាបបទល្មើសនិងគ្រប់គ្រងផលិតកម្មនៃនាយកដ្ឋានរដ្ឋាករ ក៏បានបន្តជំរុញការត្រួតពិនិត្យអនុលោមភាពលើឃ្លាំងស្តុក អាជីវកម្មដ្ឋាន និងមធ្យោបាយដឹកជញ្ជូនផលិតផលតេលសិលានៅទូទាំងប្រទេស ដើម្បីចូលរួមលើកកម្ពស់កម្រិតអនុលោមភាពនៃការនាំចូល ចែកចាយ ចរាចរដឹកជញ្ជូន និងសន្និធិផលិតផលតេលសិលា។ ជាក់ស្តែងក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ការិយាល័យ បានបន្តចុះត្រួតពិនិត្យអនុលោមភាពនៅឃ្លាំងស្តុក និងមធ្យោបាយដឹកជញ្ជូនទំនិញ ដោយរកឃើញបទល្មើសគយចំនួន ១២ករណី ហើយប្រមូលបានប្រាក់ពន្ធអាករនិងពិន័យសរុប ១ ៥៥៩ លានរៀល។






## ២- ព្រឹត្តិការណ៍សំខាន់ៗ

- ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥ លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋានរដ្ឋាករ បានដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំនាយកដ្ឋាន ដើម្បីពិនិត្យវឌ្ឍនភាពនៃការប្រមូលចំណូល, ពិភាក្សាលើនិមុត្តិជានារបស់ធុរជន និងពិនិត្យប្លង់អគាររដ្ឋបាលនិងស្នាក់នៅរបស់មណ្ឌលសន្និធិផលិតផលតេលសិលាខេត្តព្រះសីហនុ ដែលគ្រោងនឹងសាងសង់នាពេលឆាប់ៗខាងមុខ។






- ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ លោក **អន ស៊ីនួន** ប្រធាននាយកដ្ឋានរដ្ឋាករ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋាន ដើម្បីផ្សព្វផ្សាយមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ និងដើម្បីប្រកាសប្រគល់ភារកិច្ចជូនលោក **ចាន់ ម៉ារឌី** ដែលទើបទទួលការតែងតាំងជាអនុប្រធាននាយកដ្ឋានរដ្ឋាករ។





- នៅខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២៥ មន្ត្រីនៃនាយកដ្ឋានរដ្ឋាករបានសហការជាមួយមន្ត្រីនៃការិយាល័យគយនិងរដ្ឋាករពាក់ព័ន្ធ ធ្វើការត្រួតពិនិត្យអនុលោមភាពច្បាប់នៃអគារលក់ទំនិញរួចពន្ធចំនួន ៥ ទីតាំង រួមមាន នៅក្រុងបាវិតខេត្តស្វាយរៀង ចំនួន ២ ទីតាំង, នៅក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ចំនួន ១ ទីតាំង និងនៅក្រុងសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ខេត្តសៀមរាប ចំនួន ២ ទីតាំង។





# ការងារបេបគយ

នាយកដ្ឋានរបេបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការងាររបេបគយ។

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់ លោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបេបគយ និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ នាយកដ្ឋានរបេបគយបាន លទ្ធផលការងារនិងសកម្មភាពសំខាន់ៗមួយចំនួនដូចជា៖

### ១. ការងារជំនាញ

- នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ នាយកដ្ឋានរបេបគយ បានទទួលចំណូលពីការបង់ពន្ធនិងអាករលើមុខទំនិញជាប្រភេទយានយន្តដែលបាននាំចូលបណ្ដោះអាសន្នក្រោមរបបប្រវេសន៍កាលិកបង្វែរជាការនាំចូលស្ថាពរប្រើប្រាស់ក្នុងស្រុក ដែលមានទឹកប្រាក់ពន្ធនិងអាករ និងកម្រៃសរុបចំនួន ១,១៥៩,០៧៧,៦០០ រៀល។
- ការពិនិត្យ និងផ្ដល់យោបល់ចំពោះឯកសារគម្រោងវិនិយោគ (បញ្ជីមេ) បានចូលរួមពិនិត្យសំណើសុំនាំចូលរបស់ **គលត** នូវសម្ភារៈសំណង់ គ្រឿងម៉ាស៊ីន វត្ថុធាតុដើមសារធាតុគីមីនិងសម្ភារៈផ្សេងៗសរុបចំនួន ៣៧៦ សំណើ។

### ២. សកម្មភាពចូលរួមប្រជុំរបស់លោក ម៉ុន ជីវ ប្រធាននាយកដ្ឋានរបេបគយ

- ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងរ៉ែនិងថាមពលលោក**ម៉ុនជីវ**ប្រធាននាយកដ្ឋានរបេបគយ និងមន្ត្រីនាយកដ្ឋានរបេបគយ បានចូលរួមកិច្ចប្រជុំពិនិត្យ និងចចារលើសំណើបច្ចេកទេស និងហិរញ្ញវត្ថុនៃគម្រោងអភិវឌ្ឍបណ្ដាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ពីមេមត់ទៅស្វាយទាប រួមទាំងអនុស្ថានីយ៍មេមត់ និងអនុស្ថានីយ៍ស្វាយទាបរបស់ក្រុមហ៊ុន SCH-NEITEC CO., LTD។





- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបេបគយ និងមន្ត្រីនាយកដ្ឋានរបេបគយ បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើការស្នើនាំចូលគ្រឿងអេឡិចត្រូនិក និងបរិក្ខារអគ្គិសនីដែលប្រើប្រាស់រួចសម្រាប់គម្រោងរោងចក្រកែច្នៃឡើងវិញ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**ទីប្រឹក្សាសម្ដេចធិបតីនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ។






- ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោកអគ្គនាយករង **ផា អេចម៉េង** អមដោយលោក **ម៉ុន ឌីម** ប្រធាននាយកដ្ឋានរបបគយ លោក **ខៀវ សារឿន** ប្រធានសាខាគយនិងរដ្ឋាករខេត្តរតនគិរី លោក **ហាក់ វណ្ណៈ** អនុប្រធានសាខាគយនិងរដ្ឋាករខេត្តក្រចេះ លោក **ម៉ុន រតនា** ជំនួយការសាខាគយនិងរដ្ឋាករខេត្តស្ទឹងត្រែង និងមន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំក្រុមការងារជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** ទីប្រឹក្សាសម្តេចធិបតីនាយករដ្ឋមន្ត្រី ប្រធានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ។





- ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ លោក **ម៉ុន ឌីម** ប្រធាននាយកដ្ឋានរបបគយ បានដឹកនាំកិច្ចប្រជុំជួបសម្ភាសលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ជាមួយអ្នកជំនាញការខាងសុវត្ថិភាពម្ហូបអាហារមកពីក្រសួងកសិកម្មនៃសហរដ្ឋអាម៉េរិក (USDA) និងសម្ព័ន្ធនាំចេញម្ហូបអាហារនិងកសិកម្ម (FAEA) ដែលសម្របសម្រួលដោយតំណាងអគ្គនាយកដ្ឋាន ក.ប.ប. ដោយមានការចូលរួមពីលោក **ទូច លីដែល** លោក **ហ៊ីម ពុទ្ធិរិទ្ធ** លោក **កែម ម៉ាន្នី** លោក **ស៊ុន ស៊ីថា** និងលោក **ខួន ផាន់ណា** ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមកពីនាយកដ្ឋានសាខាគយនិងរដ្ឋាករ និងការិយាល័យគយនិងរដ្ឋាករពាក់ព័ន្ធ។





- ថ្ងៃទី១៥ខែធ្នូ ឆ្នាំ២០២៥ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលោក **ម៉ុន ជីវ** ប្រធាននាយកដ្ឋានរបបគយ អមដោយមន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រុមការងារសហបង្កើតធុរកិច្ច (BCT)។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **ខា ឧទ្ធិ** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។





**៣. សកម្មភាពរបស់មន្ត្រីនៃនាយកដ្ឋានរបបគយ បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងចូលរួមការចុះត្រួតពិនិត្យអនុលោមភាពការប្រើប្រាស់ទំនិញនាំចូលដោយពន្ធអាករជាបន្ទុករបស់រដ្ឋ**

-ថ្ងៃទី៤ខែតុលា ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយបានសហការជាមួយតំណាងក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ (លោក **ហ៊ិន ធិរាជ**) ចុះពិនិត្យអនុលោមភាពលើការអនុវត្តគម្រោងរបស់ក្រុមហ៊ុនចំនួន ២ ដូចខាងក្រោម៖

១. ចុះត្រួតពិនិត្យអនុលោមភាពលើការអនុវត្តគម្រោងសាងសង់អចលនទ្រព្យ (ផ្ទះវីឡាសម្រាប់ជួល) របស់ក្រុមហ៊ុន HAI AN DI CHAN CO., LTD ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២. ចុះត្រួតពិនិត្យអនុលោមភាពលើការអនុវត្តគម្រោងសាងសង់អគារពហុមុខងារ សណ្ឋាគារ វីសេត អគារស្នាក់នៅរួម អគារពាណិជ្ជកម្ម ផ្សារទំនើប ហៅកាត់ថា "គម្រោងអគារខៀវ (Blue Building Project)" របស់ក្រុមហ៊ុនT.C CAPITAL CO., LTD ស្ថិតនៅភូមិ៦ សង្កាត់លេខ៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។





- ចាប់ពី ថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥ សមាជិកក្រុមការងារនៃអង្គភាព AEO Unit នៃ **អគគ** ដែលមាន មន្ត្រីនាយកដ្ឋានរបបគយ និងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធបានចូលរួមកម្មវិធី The Joint Validation Visit of ASEAN AEO MRA (AAMRA) នៅទីក្រុងហាណូយ ប្រទេសវៀតណាម។





- ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ លោកអគ្គនាយករង **ចាន់ សុភាព** អមដោយមន្ត្រីនាយកដ្ឋានរបបគយ និងមន្ត្រីនាយកដ្ឋានពាក់ព័ន្ធ បានចូលរួមពិធីបិទបញ្ចប់គម្រោងអភិវឌ្ឍន៍ផលផលក្រោយប្រមូលផល ក្រោមប្រធានបទ បរិវត្តកម្មផលផលកម្ពុជាដើម្បីកំណើនប្រកបដោយចីរភាព ដែលបានសហការរៀបចំឡើងដោយរដ្ឋបាលជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ (UNIDO) ក្រោមការគាំទ្រថវិកាដោយសហភាពអឺរ៉ុប។ ពិធីនេះបានរៀបចំ នៅសណ្ឋាគារ RAFLE HOTEL LE ROYAL រាជធានីភ្នំពេញ ក្រោមអធិបតីឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។






- ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយបានចូលរួមទស្សនកិច្ចសិក្សា ស្តីពីផលិតកម្ម និងគ្រឿងបង្គុំយានយន្តអគ្គិសនី នៅទីក្រុងសិនជិន ប្រទេសចិន ក្រោមអធិបតីភាពឯកឧត្តម **ជា ភុកហុង** អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ និងជាអនុប្រធានប្រចាំការក្រុមការងារបច្ចេកទេសដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យយានយន្តអគ្គិសនី ២០២៤-២០៣០ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីអញ្ជើញមកពីអគ្គនាយកដ្ឋានគោលនយោបាយ,អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋានថវិកា,អគ្គនាយកដ្ឋានពន្ធដារ,អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន,អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។





- ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសណ្ឋាគារប៉ាស៊ីហ្វិក ខេត្តសៀមរាប មន្ត្រីនាយកដ្ឋានរបបគយ រួមទាំងមន្ត្រីគយនិងរដ្ឋាករមកពីនាយកដ្ឋានសាខានិងការិយាល័យគយនិងរដ្ឋាករចំនួន ១០ សរុបចំនួន ២៣រូប បានចូលរួម "កម្មវិធីវិបស្សនា និងសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២៤-២០២៨" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីលោកជំទាវ **កែវ ចរិយា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីនេះ បានបែងចែងជា ២ថ្ងៃ។

- ថ្ងៃទី១ ជាកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ដែលមានគោលបំណង ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០២៤-២០២៨ ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែច្បាស់ពីផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធានាបាននូវការផ្តល់ជូនរបាយការណ៍លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំបន្តបន្ទាប់បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។

- ថ្ងៃទី២ជាកម្មវិធីវិបស្សនាបូកសរុបលទ្ធផលនៃការ

អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ឆ្នាំ២០២៥ តាមអង្គភាពក្រោមឱវាទ និងក្រោមអាណាព្យាបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីកំណត់នូវបញ្ហាប្រឈម ដំណោះស្រាយ ព្រមទាំងលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់។





- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយ បានចុះពិនិត្យជាក់ស្តែងលើសំណើសុំបង់ពន្ធអាករ និងផ្ទេរ-ទទួលយកនូវរថយន្ត គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ពីក្រុមហ៊ុន SPHP ( Cambodia ) Co., Ltd ជូនទៅក្រុមហ៊ុន Khmer Electrical Power Co., Ltd ស្ថិតនៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។





- ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ មន្ត្រីនាយកដ្ឋានរបបគយ បានចូលរួមជាមួយគណៈកម្មការអន្តរក្រសួង ស្ថាប័ន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះត្រួតពិនិត្យជាក់ស្តែងលើសំណើសុំផ្ទេរ និងទទួលយកនូវគ្រឿងម៉ាស៊ីន ចំនួន ០១ គ្រឿង ពីក្រុមហ៊ុន LUENTECH TEXTILE SOLUTIONS CO., LTD. ទៅឱ្យក្រុមហ៊ុន GREAT MEIBANG INTERNATIONAL ( CAMBODIA ) CO., LTD. ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៣ ភូមិក្រាំងទ្រា ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។





# ការងារគ្រប់គ្រងតំបន់រួចពន្ធ

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងតំបន់រួចពន្ធ មានការិយាល័យក្រោមឱវាទមួយចំនួនដូចជា ការិយាល័យគោលនយោបាយនិងគ្រប់គ្រងតំបន់រួចពន្ធ និងបណ្តាការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេសនានា។ ក្រៅពីការអនុវត្តការងារស្នូលប្រចាំថ្ងៃ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ មានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

១. នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ក្នុងនាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមជាមួយគណៈកម្មការអន្តរក្រសួង ដឹកនាំដោយឯកឧត្តម **ហេង សុខណាង** អគ្គលេខាធិការរង នៃគណៈកម្មាធិការវិនិយោគកម្ពុជា ចុះពិនិត្យទីតាំងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុនចំនួន ៣ រួមមាន៖ (១) នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០២៥ ក្រុមហ៊ុន SOKUN UP GLOBAL INVESTMENT CO., LTD. ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរពៅ និងភូមិព្រែកក្រែង សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត លើទំហំផ្ទៃដី ២៩១ហិកតា និងមានទុនវិនិយោគ ៦៥លានដុល្លារអាមេរិក, (២) នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ ក្រុមហ៊ុន PPLC SUPERPORT & INDUSTRIAL CO., LTD. ដែលមានទីតាំងស្ថិតនៅភូមិសំពៅ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ លើទំហំផ្ទៃដី ១៣២.២៨ហិកតា និងមានទុនវិនិយោគ ៧៥លានដុល្លារអាមេរិក និង (៣) នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ក្រុមហ៊ុន CAMBODIAN SHANGHAI SPECIAL ECONOMIC ZONE CO., LTD. ដែលមានទីតាំងស្ថិតនៅភូមិចេក ឃុំអូរ និងភូមិជន្លង់ម្លូ ឃុំព្រៃរំដួល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ លើទំហំផ្ទៃដី ៤៥៥.៧៤ហិកតា និងមានទុនវិនិយោគ ៤០លានដុល្លារអាម៉េរិក។






២. ការិយាល័យគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស នៃនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស ជូនដល់តំណាងអ្នកអភិវឌ្ឍន៍តំបន់,វិនិយោគិនក្នុងតំបន់និងជើងសាគយពាក់ព័ន្ធចំនួន ៣លើករួមមាន៖ ៖ នៅតំបន់សេដ្ឋកិច្ចពិសេសខេមបូឌាន ស៊ីណូ មេធលលីក មេធៀវៀល ចំនួន ១លើក នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥, នៅតំបន់សេដ្ឋកិច្ចពិសេសកោះកុងចេជាង ចំនួន ១លើក នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ និងនៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ចំនួន ១លើក នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។









# ការងារគ្រប់គ្រងការនាំចេញ

ក្រោមការដឹកនាំរបស់ លោក **គិន សុភាររក្ស** ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញ សម្រេចបានសកម្មភាពការងារសំខាន់ៗមួយចំនួនរួមមាន៖

**១. ផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិគយពាក់ព័ន្ធនឹងការនាំចេញ**

- ច្បាប់ស្តីពីគយ នីតិវិធីនាំចេញ បទប្បញ្ញត្តិស្តីពីការរាយការណ៍ កាផ្ញើចរាចរ ការផ្ញើសន្និធិ ការដឹកជញ្ជូនទំនិញនាំចេញ ការបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ ការនាំចេញបណ្តោះអាសន្ន ព្រមទាំងក្រមសីលធម៌ដើងសាគយជាដើម។

- ប្រកាសអន្តរក្រសួងលេខ ៣៧៩ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥ ស្តីពីវិធានការសម្រាប់បង្ការនិងទប់ស្កាត់ការក្លែងបន្លំដើមកំណើទំនិញសម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក។

- ប្រកាសលេខ ៧៧៨ សហវ.ប្រក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលកម្រៃបំពេញបែបបទគយចំពោះការនាំចេញកសិផល។

- ប្រកាសលេខ ២០៨ សហវ.ប្រក.អគរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ ស្តីពីការលើកលែងកម្រៃត្រួតពិនិត្យកុងតឺន័រដោយម៉ាស៊ីនស្កែនចំពោះការនាំចេញកសិផល។

- ប្រកាសលេខ ១១៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតនិងកិច្ចដំណើរការដើងសាគយ។

- ប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្តីពីក្រមសីលធម៌ដើងសាគយ។

- សេចក្តីណែនាំលេខ ២០៦២/២៥ អគរ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការបំពេញបែបបទនាំចេញមុខទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិកក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)។

- សេចក្តីណែនាំលេខ ៤៣៥៣/២៣ អគរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីនីតិវិធីលម្អិត និងភារកិច្ចទទួលខុសត្រូវ នៃកិច្ចដំណើរការការរាយការណ៍អំពីទំនិញ និងកិច្ចដំណើរការប្រតិវេទន៍គយ តាមមធ្យោបាយអេឡិចត្រូនិក។

- សេចក្តីណែនាំលេខ ១១១៤ អគរ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលនីតិវិធី និងតម្រូវការឯកសារសម្រាប់ការត្រួតពិនិត្យបែបបទគយលើទំនិញវាយនភ័ណ្ឌ និងកាត់ដេរនាំចូលត្រឡប់មកវិញ ក្រោយពីបាននាំចេញ។

- សេចក្តីណែនាំលេខ ២៣៣៧/២៤ អគរ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តមុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment) នៅក្នុងប្រព័ន្ធ e_Customs។

- សៀវភៅមគ្គុទ្ទេសក៍នីតិវិធីគយកម្ពុជា។

**២. ណែនាំអំពីការចុះបញ្ជិកាប្រតិវេទន៍គយឲ្យបានត្រឹមត្រូវ**

- បញ្ចូលទិន្នន័យប្រតិវេទន៍គយ និងពិនិត្យផ្ទៀងផ្ទាត់គ្រប់ប្រអប់ព័ត៌មាន ព្រមទាំងផ្ទុក (Upload) ឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក រួចចុះបញ្ជិកាប្រតិវេទន៍គយ (SAD) ក្នុង ប្រព័ន្ធស្វ័យ ប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)។

- ឯកសារគាំទ្រត្រូវផ្ទុកក្នុងប្រព័ន្ធ ដើម្បីអមភ្ជាប់ប្រតិវេទន៍គយ រួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ លិខិតផ្ទេរសិទ្ធិ លិខិតអនុញ្ញាតនាំចេញ (ចំពោះទំនិញជាប់អាយ័ត ឬទំនិញជាប់កម្រិតកំណត់) និង/ឬឯកសារតម្រូវផ្សេងទៀត។

- បំពេញលេខកូដរបបគយ និងលេខកូដទំនិញឱ្យបានត្រឹមត្រូវ ដើម្បីពង្រឹងគុណភាពស្ថិតិឲ្យកាន់តែល្អប្រសើរ និងចៀសវាងធ្វើឱ្យប៉ះពាល់ដល់អាករនាំចេញ ឬកម្រៃផ្សេងៗ។

- ប្រតិវេទករត្រូវជំរុញឱ្យអ្នកនាំចេញទៅស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ នៅក្រសួងពាណិជ្ជកម្មឱ្យបានទាន់ពេល ដើម្បីដាក់បញ្ចូលចូលក្នុងប្រតិវេទន៍គយ។

- ប្រតិវេទករត្រូវបំពេញលេខនិងកាលបរិច្ឆេទលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដែលចេញដោយក្រសួងពាណិជ្ជកម្មឱ្យបានត្រឹមត្រូវ។

- ក្នុងករណីពុំទាន់អាចទទួលបានលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញដែលចេញដោយក្រសួងពាណិជ្ជកម្ម ប្រតិវេទករត្រូវបំពេញពាក្យ "PENDING" ក្នុងប្រអប់លេខយោង និងត្រូវសងឯកសារនេះវិញ ដោយអនុវត្តនីតិវិធីកែតម្រូវប្រតិវេទន៍គយជាធរមាន។

**៣. ការពង្រឹងអនុលោមភាពការបំពេញបែបបទបញ្ចេញទំនិញពីគយ**

បានធ្វើការណែនាំដល់ជើងសាគយ និងធុរជនពាក់ព័ន្ធលើចំណុចមួយចំនួនដូចខាងក្រោម៖

- ត្រូវធ្វើលិខិតផ្ទេរសិទ្ធិ និងឯកសារអមប្រតិវេទន៍គយនាំចេញឱ្យបានត្រឹមត្រូវ និងពេញលេញ
- ការនាំចេញទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ត្រូវមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតនាំចេញ ឬឯកសារគតិយុត្តិប្រហាក់ប្រហែលពីក្រសួង-ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័ននោះ
- អ្នកនាំចេញដែលធ្វើការនាំចេញទំនិញខុសពីអាជីវកម្មចម្បងរបស់ក្រុមហ៊ុនខ្លួនត្រូវស្នើសុំធ្វើបណ្ណប៉ាតង់បន្ថែមដែលត្រូវនឹងទំនិញដែលក្រុមហ៊ុនត្រូវធ្វើការនាំចេញ និងធ្វើបច្ចុប្បន្នភាពបណ្ណប៉ាតង់ជាប្រចាំ។
- មិនត្រូវអនុញ្ញាតឲ្យអ្នកដទៃប្រើប្រាស់ User និង Password របស់ខ្លួន ដើម្បីចូលក្នុងប្រព័ន្ធអាស៊ីគូដាឡើយ។
- ត្រូវរូតរះស្នើសុំកែតម្រូវប្រតិវេទន៍គយដែលជំពាក់លិខិតអនុញ្ញាត បញ្ជាក់ដើមកំណើតទំនិញ (ប្រតិវេទន៍គយដែលបំពេញពាក្យ "PENDING" ក្នុងប្រអប់លេខយោង) នៅពេលដែលទទួលបានលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម។
- ត្រូវគោរពក្រមសីលធម៌ជើងសាគយ។

**៤. ការទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment)**

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងបន្តធ្វើឱ្យប្រសើរឡើងថែមទៀតនូវការផ្តល់សេវាបង់ពន្ធ-អាករ និងកម្រៃផ្សេងៗ ជូនសាធារណជន ដែលជាផ្នែកមួយនៃកិច្ចសម្រួលពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រេចដាក់ឱ្យអនុវត្តមុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក (e-Payment) ស្របតាមសេចក្តីណែនាំលេខ ១១៥២/១៨ អគរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។ ក្នុងសិក្ខាសាលានេះ ន.គច បានណែនាំដល់សិក្ខាកាមនូវរបៀបប្រើប្រាស់មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក ដើម្បីជំរុញការប្រើប្រាស់មុខងារនេះឱ្យបានជាអតិបរមា។

**៥. ផ្សព្វផ្សាយអំពីទោសទណ្ឌនៃការក្លែងបន្លំឯកសារ និងផលវិបាកនៃការប្រព្រឹត្តបទល្មើសគយ**

បានណែនាំដល់អ្នកនាំចេញ និងជើងសាគយដូចខាងក្រោម៖

- ត្រូវចូលរួមគោរព និងអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាជាធរមាន
- ត្រូវប្រើប្រាស់ឯកសារឲ្យបានត្រឹមត្រូវ ចៀសវាងការក្លែងបន្លំឯកសារ ការប្រើប្រាស់ឯកសារក្លែងក្លាយ ការប្រកាសដោយភូតកុហក ការផ្តល់លិខិតបញ្ជាក់មិនពិត
- ត្រូវចៀសវាងការប្រព្រឹត្តបទល្មើសគយដូចជាក្លែងបន្លំឯកសារ ការប្រកាសមិនត្រឹមត្រូវ ការលួចបង្កប់នូវទំនិញហាមឃាត់ ទំនិញជាប់កម្រិតកំណត់ ឬទំនិញក្លែងបន្លំម៉ាកសញ្ញាជាដើម ដែលអាចនឹងត្រូវរងការពិន័យជាប្រាក់ និង/ឬរងការផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ជាធរមាន។

បន្តអនុវត្តន៍ឲ្យមានប្រសិទ្ធភាពនូវសេចក្តីណែនាំ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាពិសេសអនុសាសន៍ណែនាំ ដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ។










# ការងារគយនិងរដ្ឋាករផែស្វួត

## I. ការពង្រឹងអនុលោមភាពតាមបណ្តាការិយាល័យគយនិងរដ្ឋាករផែស្វួតក្រោមឱវាទ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករផែស្វួតបានយកចិត្តទុកដាក់ខ្ពស់នៅក្នុងការងារកៀរគរចំណូលពន្ធអាករ ឱ្យសម្រេចបានតាមផែនការផ្ទៃក្នុងសម្រាប់អនុវត្តចំណូលពន្ធនិងអាករផ្សេងៗដែលប្រមូលដោយ **អគរ** ប្រចាំខែ និងស្របតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងកិច្ចប្រជុំបូកសរុបការងារគយនិងរដ្ឋាករប្រចាំខែនាពេលកន្លងដែល និងបានក្លាយជាអង្គភាពគយនិងរដ្ឋាករដែលប្រមូលចំណូលច្រើនជាងលំដាប់ទី១ នៅទូទាំងប្រទេសក្នុងរយៈពេលបីខែចុងក្រោយ ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

- ប្រាក់ពន្ធ 1,030,509,856,300៛ ស្មើនឹង 100.53% នៃផែនការត្រីមាសទី៤ ឆ្នាំ២០២៥ សរុប 1,025,100,000,000៛
- ប្រៀបធៀបនឹងចំណូលត្រីមាសទី៣ ឆ្នាំ២០២៥ មានការកើនឡើងប្រមាណ 15,105,870,600៛ ស្មើនឹង 1.49%
- ប្រៀបធៀបនឹងចំណូលត្រីមាសទី៤ ឆ្នាំ២០២៤ មានការកើនឡើងប្រមាណ 515,961,648,300៛ ស្មើនឹង 100.27%

ក្នុងន័យបង្កើនការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ និងបន្លំពន្ធតាមគ្រប់រូបភាព ជាពិសេសលើមុខទំនិញយានយាន្ត និងមុខទំនិញផ្សេងទៀតដែលជាប្រភពចំណូលដ៏សំខាន់ កម្លាំងក្រុមការងារពង្រឹងអនុលោមភាពរបស់នាយកដ្ឋានគយនិងរដ្ឋាករផែស្វួត បានបន្តការចុះសហការត្រួតពិនិត្យរូបវន្តលើទំនិញយានយន្ត និងមុខទំនិញផ្សេងគយនិងការធ្វើចំណាត់ថ្នាក់តាមតារាងពន្ធគយជាធរមាននៅបណ្តាការិយាល័យគយនិងរដ្ឋាករផែស្វួតក្រោមឱវាទ តាមការចង្អុលបង្ហាញរបស់ **អគរ** និងលោកប្រធាននាយកដ្ឋានគយនិងរដ្ឋាករផែស្វួត។ ជាលទ្ធផលក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករផែស្វួតបានចាត់តាំងឱ្យក្រុមការងារពង្រឹងអនុលោមភាពឱ្យសហការចុះត្រួតពិនិត្យទំនិញជាមួយក្រុមចម្រុះ **អគរ** និងមន្ត្រីគយនិងរដ្ឋាករនៃការិយាល័យគយនិងរដ្ឋាករផែស្វួតក្រោមឱវាទ ដោយបានរកឃើញការប្រកាសនាំចូលមិនត្រឹមត្រូវ និងបានកសាងកំណត់ហេតុល្មើសច្បាប់គយចំនួន ៨ករណី ប្រមូលប្រាក់ពន្ធអាករនិងពិន័យបន្ថែមចំនួន 36,979,600៛។

បន្ថែមពីលើនេះ នាយកដ្ឋានគយនិងរដ្ឋាករផែស្វួតបានសហការត្រួតពិនិត្យរូបវន្តលើទំនិញម៉ូតូនាំចូល ដែលក្រុមហ៊ុនម្ចាស់សិទ្ធិបានស្នើសុំព្យួរការនាំចូលនិងត្រួតពិនិត្យករណីសង្ស័យរំលោភលើកម្មសិទ្ធិបញ្ញា លើសិទ្ធិនៃការប្រើប្រាស់គំនូរឧស្សាហកម្ម ចំនួន ១ ករណី នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅការិយាល័យគយនិងរដ្ឋាករផែស្វួតហុងឡេងហួរ។ ក្រោយពីបញ្ចប់ការត្រួតពិនិត្យ មន្ត្រីគយនាយកដ្ឋានគយនិងរដ្ឋាករផែស្វួតបានសម្រេចរក្សាទំនិញទុកបណ្តោះអាសន្ននៅផែស្វួតហុងឡេងហួររួចបានដកយកគំរូក្បាំងក្រោយចំនួន ១បន្ទះ និងបានរៀបចំរបាយការណ៍ត្រួតពិនិត្យគោរពជូន ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់។





សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពទំនិញនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ឃែរី វើលដ៏ប្រីដ ឡូជីស្ទីក





សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពទំនិញនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត តេងឡាយ







សកម្មភាពចុះត្រួតពិនិត្យអនុលោមភាពទំនិញនៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ហុងឡេងហួរ









សកម្មភាពចុះត្រួតពិនិត្យរូបវន្តលើទំនិញម៉ូតូនាំចូល ដែលក្រុមហ៊ុនម្ចាស់សិទ្ធិបានស្នើសុំព្យួរការនាំចូល
និងត្រួតពិនិត្យករណីសង្ស័យរំលោភលើកម្មសិទ្ធិបញ្ញា នៅការិយាល័យគយនិងរដ្ឋាករផែស្ងួត ហុងឡេងហួរ

# ការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ

នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារប្រមូលចំណូលពន្ធ អាករ និងកម្រៃគ្រប់ប្រភេទ, គ្រប់គ្រង និងត្រួតពិនិត្យបែបបទគយលើទំនិញនាំចេញ នាំចូល និងទំនិញឆ្លងកាត់គ្រប់ប្រភេទ, ត្រួតពិនិត្យបែបបទគយលើអាកាសយាននិងអ្នកដំណើរចេញ-ចូល,បង្ការនិងបង្ក្រាបបទល្មើសគយ,ផ្តល់កិច្ចសម្រួលពាណិជ្ជកម្មនិងបំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់លោក **ហ៊ីង ពុទ្ធិរិទ្ធ** ប្រធាននាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ, នៅក្នុងត្រីមាសទី៤ឆ្នាំ២០២៥ នេះនាយកដ្ឋាន-គយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិប្រមូលចំណូលបានប្រមាណ ៥៩,២២ប៊ីលានរៀល។

ទន្ទឹមនឹងនេះនាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋាន-អន្តរជាតិក៏សម្រេចបាននូវលទ្ធផលការងារសំខាន់ៗមួយចំនួនផ្សេងទៀត ដូចខាងក្រោម៖

## I. ការងារបង្ការ និងបង្ក្រាបបទល្មើស

នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ១៥:៤០ នាទី នៅច្រកអ្នកដំណើរចេញ នៃអាកាសយានដ្ឋានអន្តរជាតិតេជោ ដោយមានការសង្ស័យ មន្ត្រីគយនិងរដ្ឋាករបានធ្វើការត្រួតពិនិត្យលើអ្នកដំណើរឈ្មោះ RAZIN ROMAN ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិកាហ្សាក់ស្ថាន កាន់លិខិតឆ្លងដែនលេខ N12811095 ធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី តាមជើងហោះហើរលេខ KT169 (ភ្នំពេញ-កូឡាឡាំពួរ)។ ក្រោយការត្រួតពិនិត្យមន្ត្រីគយនិងរដ្ឋាករបានរកឃើញម្សៅក្រាមពណ៌ស ច្រកក្នុងថង់ប្លាស្ទិកចំនួន ២ លាក់ក្នុងស្រោមពូកដាក់ក្នុងវ៉ាលិស ដែលសង្ស័យថាជាសារធាតុញៀនខុសច្បាប់។ មន្ត្រីគយនិងរដ្ឋាករបានអញ្ជើញសមត្ថកិច្ចចម្រុះចូលរួមត្រួតពិនិត្យលម្អិតជាក់ស្តែង ដោយបានធ្វើតេស្តម្សៅក្រាមពណ៌សនោះដោយប្រើម៉ាស៊ីន TruNarc ជាលទ្ធផលមានតម្រុយជាសារធាតុញៀនប្រភេទហេរ៉ូអ៊ីន (HEROIN) និងបានយកម្សៅសនោះទៅថ្លឹងដោយជញ្ជីងម៉ាក Kitchen Scale មានទម្ងន់សុទ្ធសរុប ២ ០៨៦ក្រាម។








## II. ការទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគយប្រទេស Bosnia and Herzegovina

នារសៀលថ្ងៃអង្គារ៦រោចខែកត្តិកឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិបានទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគយប្រទេស Bosnia and Herzegovina (Indirect Taxation Authority) ដើម្បីមកសិក្សាពីការអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ តាមប្រព័ន្ធ ASYHUB សម្រាប់បញ្ញើឆាប់រហ័ស ដោយមានការចូលរួម និងសម្របសម្រួលពីនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ នាយកដ្ឋានសវនកម្មគយ ក្រុមអ្នកជំនាញការ UNCTAD, GIZ និង GATF។










## III. ការទទួលដំណើរទស្សនកិច្ចរបស់អ្នកជំនាញការរយៈពេលវែង JICA ប្រចាំ អគរ

នារសៀលថ្ងៃពុធ ១២រោចខែមិគសិរ ឆ្នាំម្សាញ់ សប្តស័កព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ខែធ្នូឆ្នាំ២០២៥ នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ បានទទួលដំណើរទស្សនកិច្ចរបស់អ្នកជំនាញការរយៈពេលវែង JICA ប្រចាំ **អគរ** Ms. KOBAYASHI Aki ដែលមកសិក្សាពីនីតិវិធីនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ និងអង្កេតជាក់ស្តែងពីដំណើរការនៃការសិក្សារយៈពេលបញ្ចេញទំនិញនៅអាកាសយានដ្ឋានអន្តរជាតិតេជោ ដោយមានការចូលរួម និងសម្របសម្រួលពីនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ។









# សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ក្រោមការដឹកនាំដោយលោក **នង សុខុម** បានខិតខំអស់ពីកម្លាំងកាយចិត្ត ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងមានការចូលរួមយ៉ាងសកម្មពីមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទក្នុងការបំពេញតួនាទីនិងភារកិច្ច ជំរុញការអនុវត្តការងារសំខាន់ៗស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការប្រមូលចំណូលពន្ធនិងអាករ, សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ប្រមូលចំណូលបាន ៩០៧,៦៥៣,៩៨៤,៨០០ រៀល ស្មើនឹង ១០៦.១៦% នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឲ្យអនុវត្ត។

ទន្ទឹមនឹងនេះ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុក៏សម្រេចបាននូវលទ្ធផលការងារសំខាន់ៗមួយចំនួនផ្សេងទៀតដូចខាងក្រោម៖

១.កិច្ចប្រជុំស្តីពី "Regional Interagency Meeting on Combating Hazardous Waste Trafficking and Abandoned Containers"

ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ មន្ត្រីគយនៃសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ បានចូលរួមកិច្ចប្រជុំស្តីពី "Regional Interagency Meeting on Combating Hazardous Waste Trafficking and Abandoned Containers" នៅទីក្រុងCebu ប្រទេសហ្វីលីពីន ដែលរៀបចំដោយអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម UNODC។ កិច្ចប្រជុំនេះផ្តោតសំខាន់លើការពិភាក្សាស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់គ្រប់គ្រង និងដោះស្រាយចំពោះកុងតឺន័រដែលទុកចោល (Abandoned Containers) និងជួយពង្រឹងសមត្ថភាពបន្ថែមដល់សមត្ថកិច្ច និងអាជ្ញាធរពាក់ពន្ធ័ នៃប្រទេសក្នុងតំបន់ដែលចូលរួមដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងការជួញដូរដឹកជញ្ជូនកាកសំណល់គ្រោះថ្នាក់ (Hazardous Waste Trafficking)។







២.ដំណើរទស្សនកិច្ចរបស់ក្រុមការងារ GIZ

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ លោក **នង សុខុម** ប្រធានសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ និងសហការី បានទទួលដំណើរទស្សនកិច្ចរបស់ក្រុមការងារ GIZ ដែលបានមកស្វែងយល់អំពីការអនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយនៅកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ព្រមទាំងចូលរួមអង្កេតជាក់ស្តែងលើដំណើរការប្រមូលទិន្នន័យសម្រាប់ការសិក្សាអំពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញ ( Time Release Study ) លើកទី៥ ដោយមានការចូលរួម និងសម្របសម្រួលពីនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ និងនាយកដ្ឋានរបបគយ។






៣.វគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ ស្តីពីការអនុវត្តមុខងារគ្រប់គ្រងកុងតឺន័រឆ្លងកាត់ម៉ាស៊ីនស្កេន

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សហការជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បានបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយស្តីពីការអនុវត្តមុខងារគ្រប់គ្រងកុងតឺន័រឆ្លងកាត់ម៉ាស៊ីនស្កេន (Container Scanning Management) ដែលមុខងារនេះអនុញ្ញាតឱ្យធុរជនអាចរៀបចំផែនការចូលស្កេនកុងតឺន័រ អាចបង់កម្រៃដោយភាពច្បាស់លាស់ រហ័ស និងអនុញ្ញាតឲ្យមន្ត្រីទទួលបន្ទុកស្កេនទទួលព័ត៌មានអំពីការចូលស្កេនកុងតឺន័របានជាមុននិងគ្រប់គ្រងកាន់តែប្រសើរជាងមុន។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីអង្គភាពពាក់ព័ន្ធដូចជា មន្ត្រីគយនិងរដ្ឋាករ ជើងសាគយ អ្នកនាំចេញនាំចូល និងអាជ្ញាធរកំពង់ផែ មុខងារនេះដាក់ឲ្យអនុវត្តជាផ្លូវការចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ នៅសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ។









# សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង

សាខាគយនិងរដ្ឋាករខេត្តស្វាយរៀងក្រោមការដឹកនាំរបស់លោក **សំ សុវណ្ណារិទ្ធិ** មានការិយាល័យក្រោមឱវាទចំនួន ៦ រួមមាន ការិយាល័យរដ្ឋបាលនិងគ្រប់គ្រង ការិយាល័យគយនិងរដ្ឋាករបាវិតការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍ ការិយាល័យគយនិងរដ្ឋាករបុសមន ការិយាល័យគយនិងរដ្ឋាករសំពោង និងការិយាល័យគយនិងរដ្ឋាករដូង។ លោកប្រធានសាខា ក្នុងនាមថ្នាក់ដឹកនាំអង្គភាព បានណែនាំមន្ត្រីគយនិងរដ្ឋាករគ្រប់រូបត្រូវខិតខំប្រមូលចំណូលពន្ធនិងអាករ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ជៀសវាងអាកប្បកិរិយា និងសម្តីមិនសមរម្យនៅពេលផ្តល់សេវាជូនធុរជន ការផ្តល់សេវាដល់ធុរជនឱ្យបានឆាប់រហ័ស ដោយមិនត្រូវធ្វើឲ្យរាំងស្ទះដល់ការនាំចេញនាំចូលទំនិញ និងមិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីកេងយកប្រយោជន៍ផ្ទាល់ខ្លួន ឬដាក់បន្ទុកបន្ថែមលើធុរជន។

លទ្ធផលការងារ និងសកម្មភាពការងារសំខាន់ៗ ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ មានដូចខាងក្រោម៖

១.ការប្រមូលចំណូលរបស់សាខាគយនិងរដ្ឋាករខេត្តស្វាយរៀងសម្រេចបាន ចំនួន ១៧៩,៧៧៩,០៤៣,៦០០ រៀល ស្មើ ៩៦.៧៩% នៃផែនការប្រចាំត្រីមាសទី៤។ បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៥ឃើញថាមានការកើនឡើង ចំនួន +១៦,៧៤៣,៦៥៧,៣០០ រៀលស្មើនឹង +១០.២៦%។ ប្រៀបធៀបរយៈពេលដូចគ្នានៃឆ្នាំមុនឃើញថាមានការកើនឡើងចំនួន +៥១,១៩៤,៨៨៥១០០ រៀល ស្មើនឹង +៣៩.៧៦%។

៣.សកម្មភាពការងារសំខាន់ៗមួយចំនួនក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ មានដូចជា៖

- នារសៀលថ្ងៃសុក្រ ៣រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ លោក **សំ សុវណ្ណារិទ្ធិ** ប្រធានសាខាគយនិងរដ្ឋាករខេត្តស្វាយរៀង បានទទួលប្រតិភូនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំដោយលោកជំទាវ **ខ៉ែត ម៉ូទីឡែន** និងសមាជិក ដែលបានអញ្ជើញមកធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង អនុលោមភាព និងប្រសិទ្ធភាពប្រតិបត្តិការរបស់សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង។

- នារសៀលថ្ងៃព្រហស្បតិ៍ ៨រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពស ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ លោក **ខា សំណាង** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ អមដោយមន្ត្រីគយនិងរដ្ឋាករនៃការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍បានទទួលជួបប្រជុំជាមួយសមាគមធុរកិច្ចជប៉ុននៅកម្ពុជា(JBAC) ដែលបានធ្វើទស្សនកិច្ចនៅការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍ និងមាត់ច្រកទ្វារព្រំដែន ដើម្បីស្វែងយល់អំពីប្រតិបត្តិការប្រចាំថ្ងៃ និងនីតិវិធីផ្សេងៗ។

- នាថ្ងៃសុក្រ១០កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានដឹកនាំមន្ត្រីរាជការគយនិងរដ្ឋាករ និងមន្ត្រីជាប់កិច្ចសន្យា មកចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល អគារស្នាក់នៅ និង ហេដ្ឋារចនាសម្ព័ន្ធនានារបស់ការិយាល័យគយនិងរដ្ឋាករដូង និង ការិយាល័យគយនិងរដ្ឋាករបុសមន។

- នារសៀល ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ លោក **ខួន ផាន់ណា** ប្រធានការិយាល័យគយនិងរដ្ឋាករបាវិត ព្រមទាំងសហការី ដោយមានការសម្របសម្រួលពីលោក **ទីវ ម៉ូលីន** តំណាងនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ បានទទួលដំណើរទស្សនកិច្ចរបស់លោកស្រី TOKUORI Tomomi តំណាងទីភ្នាក់ងារJICA ដែលបានអញ្ជើញមកសិក្សាស្វែងយល់អំពីទិដ្ឋភាពទូទៅនៃប្រតិបត្តិការប្រចាំថ្ងៃ លំហូរ នីតិវិធី និង ស្ថិតិនាំចេញនាំចូល តាមមាត់ច្រកអន្តរជាតិបាវិត។




សកម្មភាពជួបប្រជុំជាមួយមន្ត្រី សវនករ នៃ **អគរ**





សកម្មភាពជួបប្រជុំផ្សព្វផ្សាយខ្លឹមសារប្រជុំនៅ **អគរ**




សកម្មភាពជួបប្រជុំជាមួយប្រតិភូនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅការិយាល័យគយនិងរដ្ឋាករព្រៃវល្លិ៍




សកម្មភាពជួបប្រជុំជាមួយសមាគមធុរកិច្ចជប៉ុននៅកម្ពុជា(JBAC)




សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនានា នៃការិយាល័យគយនិងរដ្ឋាករបុសមន

# សាខាគយនិងរដ្ឋាករខេត្តកណ្តាល

សាខាគយនិងរដ្ឋាករខេត្តកណ្តាលជាអង្គភាពប្រតិបត្តិពាក់កណ្តាលប្រដាប់អាវុធស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានការិយាល័យគយនិងរដ្ឋាករចំនួនបីដូចជាការិយាល័យរដ្ឋបាលនិងគ្រប់គ្រង ការិយាល័យគយនិងរដ្ឋាករក្អមសំណ និងការិយាល័យគយនិងរដ្ឋាករជ្រៃធំ។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ ចំណូលពន្ធនិងអាករប្រមូលបានមានចំនួន៖ ១៦៨,៣២៦,៩៨៣,០០រៀល ប្រៀបធៀបនឹងផែនការប្រចាំត្រីមាស ១៤៧,១០០,០០០,០០០ រៀល ស្មើនឹង ១១៤.៤៣% ។ បើប្រៀបធៀបនឹងត្រីមាសទី៤ឆ្នាំ២០២៤កើនឡើង៥៦,០៣៧,៥១៧,៨០០ រៀល ស្មើនឹង ៤៩.៩០%, បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៥ កើនឡើង ២៥,៨៥៧,៦០២,៦០០ រៀល ស្មើនឹង ១៨.១៥% ។ ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ សាខាគយនិងរដ្ឋាករខេត្តកណ្តាលបានឃាត់ចាប់ករណីល្មើសច្បាប់គយចំនួន ៦៦២ករណី រួមមាន ករណីតូច ៦៦១ករណី (ម៉ូតូ ៦៦០គ្រឿង ,នំស្រួយរសជាតិបន្លែម៉ាក MINGHAOJI) និងករណីធំចំនួន ០១ករណី (បង្គាក្លាសេ និងមឹកបង្គាក្លាសេ)។ ជាលទ្ធផលដែលទទួលបានពីការបង្ក្រាប គឺបានសម្រេចវិនិច្ឆ័យបទល្មើសគយចំនួន ៦៦៥ករណី (ករណីតូច ៦៦១ និងករណីធំ ០៤) បានប្រាក់ពន្ធអាករ និងពិន័យសរុបចំនួន ២,៩៩១,១៥១,៥០០រៀល។

បន្ថែមពីលើការងារប្រមូលចំណូល សម្រាប់ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តកណ្តាលបានចូលរួមអនុវត្តសកម្មភាពការងារ នៃផែនការសកម្មភាពឆ្នាំ២០២៥ ដោយសម្រេចបានលទ្ធផលតាមគោលដៅសូចនាករ និងក្របខណ្ឌពេលវេលា ដែលបានកំណត់សកម្មភាពជាក់លាក់សំខាន់ៗដូចជា បានចុះផ្សព្វផ្សាយ នៅតាមស្ថានីយប្រេងឥន្ធនៈ ផលិតផលតេលសិលា ,អាជីវកម្មដ្ឋានលក់រថយន្ត និងទំនិញចម្រុះ ចំនួន ៣៤ ដងសរុបចំនួន ២០ទីតាំង និងបានតាមដាន និងវាយតម្លៃអនុលោមភាពជើងសាគយ និង/ឬប្រតិវេទករ ចំនួន ០៦ក្រុមហ៊ុនដោយពិន័យជាប្រាក់បានចំនួន ៦០ ម៉ឺនរៀល និងបានចុះឃ្លាំមើលភូមិសាស្ត្រមានហានិភ័យខ្ពស់ចំនួន ៤៥ ដង ដោយបានបង្ក្រាបបានម៉ូតូជាប់សិទ្ធិផ្តាច់មុខ ៦៦០ករណី, បង្ក្រាបបទល្មើសគយបានចំនួន៦៦២ករណី(ម៉ូតូ,នំ,សាច់ក្លាសេ) និងសម្រេចវិនិច្ឆ័យចំនួន ៦៦៥ករណី ទទួលបានប្រាក់ពន្ធអាករ និងការពិន័យនានាចំនួន ២,៩៩១,១៥១,៥០០ រៀល ។

លើសពីនេះ សាខាបានទទួលជួបជាមួយក្រុមការងារការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មដែនសមុទ្រសកលនៃអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក UNODC ដឹកនាំដោយលោក **DAVID O' CANNELL**និងបានបញ្ជូនមន្ត្រីចំនួន២រូប ចូលរួមវគ្គបណ្តុះបណ្តាលការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដល់មន្ត្រីគយនិងរដ្ឋាករ។




សកម្មភាពពង្រឹងប្រសិទ្ធភាពប្រមូលចំណូលនៅតាមបណ្តាការិយាល័យគយនិងរដ្ឋាករមាត់ច្រក







សកម្មភាពចុះបំពេញភារកិច្ចរបស់ **អគរ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នផ្សេងៗ





សកម្មភាពចូលរួមការងារជាមួយអនុគណៈកម្មាធិការវិនិយោគខេត្តកណ្តាល





សកម្មភាពចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តតាមអាជីវកម្មដ្ឋានក្នុងភូមិសាស្ត្រខេត្តកណ្តាល






កិច្ចសហការមួយចំនួនជាមួយអាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធ

# សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង

ក្រោមការដឹកនាំដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់លោក **យូ ហេង** ជាប្រធានសាខាគយនិងរដ្ឋាករខេត្តបាត់ដំបងព្រមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទនៃសាខាគយនិងរដ្ឋាករខេត្តបាត់ដំបង បានរួមគ្នាខិតខំប្រឹងប្រែងអនុវត្តការងារគ្រប់គ្រង ប្រមូលពន្ធអាករ និងកម្រៃផ្សេងៗបង់ចូលថវិកាជាតិដែលជាភារកិច្ចរបស់អង្គភាព។ ទន្ទឹមនឹងនេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបងបាននឹងកំពុងចូលរួមចំណែកយ៉ាងសកម្មបំផុតដោយស្មារតីប្រុងប្រយ័ត្ននិងមានការទទួលខុសត្រូវខ្ពស់តាមជំនាញបច្ចេកទេសគយ។ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំសាខា ដែលជានិច្ចកាលតែងតែបានចុះជាប់តាមបណ្ដាការិយាល័យគយនិងរដ្ឋាករក្រោមឱវាទ ដើម្បីជំរុញ និងពង្រឹងការងារកៀរគរចំណូល។ ជាក់ស្ដែងក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ប្រមូលចំណូលបានចំនួន ២,៧១០,៧០៨,៣០០ រៀល គិតជាភាគរយប្រមាណ ២០៨.៥២ % នៃផែនការដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានដាក់ឲ្យអនុវត្ត ១,៣០០លានរៀលក្នុងត្រីមាស។ បើប្រៀបធៀបចំណូលត្រីមាសទី៤ ឆ្នាំ២០២៤ មានការថយចុះចំនួន ៤៣,៤៦២,៨៥៩,០០០ រៀល គិតជាភាគរយ ៩៤.១៣ % និងប្រៀបធៀបចំណូលត្រីមាសទី៣ ឆ្នាំ២០២៥ មានការកើនឡើងចំនួន ៩៥៩,៨២៨,៦០០ រៀល គិតជាភាគរយប្រមាណ ៣៥.៤១% ។ ប៉ុន្តែតួលេខចំណូលគឺបានមកពីការស្នើសុំបង់ពន្ធលើរថយន្តក្នុងស្រុកប៉ុណ្ណោះ ព្រោះបច្ចុប្បន្នច្រកទ្វារព្រំដែនទាំងអស់បន្តបិទទាំងស្រុងដោយឯកតោភាគីថៃ។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ លោកប្រធានសាខាតែងតែបន្តការយកចិត្តទុកដាក់ខ្ពស់ក្នុងពង្រឹងការងារប្រមូលចំណូលពន្ធគយដល់ការិយាល័យគយនិងរដ្ឋាករក្រោមឱវាទនិងការអនុវត្តនីតិវិធីគយជាធរមានប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ បន្តពង្រឹងការត្រួតពិនិត្យឯកសារនិងទំនិញរូបវន្តប្រកបដោយអប្បមាទខ្ពស់ អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្មក្នុងការទប់ស្កាត់រាល់បាតុភាពអសកម្មផ្សេងៗ ជាពិសេសអនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង តែងតែប្ដេជ្ញាចិត្តអនុវត្តតាមសេចក្ដីសម្រេច សេចក្ដីណែនាំ និងលិខិតបទដ្ឋានគតិយុត្តិថ្មីៗនានារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបម្រើសេវាសាធារណៈ និងការងារចំពោះមុខមួយចំនួនដែលត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនដោយខានមិនបាន។ មួយវិញទៀត សាខាគយនិងរដ្ឋាករតែងតែមានកិច្ចសហការល្អ និងចូលរួមតាមអញ្ជើញរបស់អាជ្ញាធរដែនដីស្ថាប័ន និងអង្គភាពពាក់ព័ន្ធជុំវិញខេត្តបាត់ដំបង។

ដោយឡែក ក្នុងកំឡុងខែមិថុនា ឆ្នាំ២០២៥ រហូតដល់បច្ចុប្បន្ន ច្រកទ្វារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបងតាមបណ្ដោយព្រំដែនកម្ពុជា-ថៃបានបិទទាំងស្រុងដោយភាគីថៃប្រកាសបិទដោយឯកតោភាគី ដូច្នេះធ្វើឲ្យប៉ុន្មានខែកន្លងទៅនេះ សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង ក៏ដូចជាបណ្ដាការិយាល័យមួយចំនួនតាមបណ្ដោយព្រំដែនពុំមានសម្មភាពទំនិញនាំចេញនាំចូលធ្វើប៉ះពាល់ដល់លទ្ធភាពប្រមូលចំណូលពន្ធគយ។







សកម្មភាពថ្នាក់ដឹកនាំចុះប្រគល់អំណោយដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី និងលោកជំទាវបណ្ឌិតនិងអំណោយរបស់សមាគមសង្គហមិត្តមន្ត្រីរាជការគយនិងរដ្ឋាករកម្ពុជា ជូនយោធភូមិទី៥ ព្រមទាំងអំណោយថ្នាក់ដឹកនាំ និងមន្ត្រីសាខាគយនិងរដ្ឋាករខេត្តបាត់ដំបងជូនរដ្ឋបាលខេត្តដើម្បីចូលរួមចំណែកជួយដល់វីរៈកងទ័ពជួរមុខ និងជនភៀសសឹកក្នុងខេត្តបាត់ដំបង




សកម្មភាពថ្នាក់ដឹកនាំមន្ត្រីសាខា និងការិយាល័យចូលរួមជាមួយអាជ្ញាធរមូលដ្ឋានចុះជួយប្រចាំការទទួលអំណោយរបស់សប្បុរសជនដើម្បីប្រគល់ជូនជនភៀសសឹកតាមមណ្ឌល







សកម្មភាពថ្នាក់ដឹកនាំមន្ត្រីសាខា និងការិយាល័យចូលរួមផ្សព្វផ្សាយកាតព្វកិច្ចបង់ពន្ធនិងអាករជូនអាជីវករ

# សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ

ក្រោមការដឹកនាំដោយលោក **ហេង សំបូរ** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ បានខិតខំអស់ពីកម្លាំងកាយចិត្ត ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការបំពេញតួនាទី និងភារកិច្ចក្នុងការប្រមូលចំណូលពន្ធ និងអាករ ឱ្យបានគ្រប់ និងលើសផែនការ ដែល **អគរ** បានដាក់ចេញ។

**លទ្ធផលប្រមូលចំណូល៖**

ជាលទ្ធផល ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ សាខាប្រមូលចំណូលបាន ១៧,៥៩៧,៣៥៩,៩០០ រៀល ស្មើនឹង ៩៦.៨៥% នៃផែនការដែល **អគរ** បានដាក់ឲ្យអនុវត្ត ១៨,១៧០ លានរៀល។ បើប្រៀបធៀបត្រីមាសទី៤ឆ្នាំ២០២៤ មានការកើនឡើងចំនួន ៤,០៦៧,៦៩៥,៦០០ រៀល ស្មើនឹង ៣០.០៧% ។ បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៥ គឺមានការកើនឡើងចំនួន ៩៩៥,៤១០,៤០០ រៀល ស្មើនឹង ៥.៦៦% ។

**លទ្ធផលបង្ការ និងបង្ក្រាបបទល្មើស៖**

ចំនួនបទល្មើសគយ (តូច) ០១ ករណី

ចំនួនបទល្មើសគយ (ធំ) ០១ ករណី

ប្រាក់ពន្ធ អាករ និងពិន័យសរុបចំនួន ១៧៣,៥៣០,៨០០ រៀល

**ការងារគ្រប់គ្រងមន្ត្រីរាជការ**

មន្ត្រីរាជការគយដែលកំពុងបំពេញការងារសរុបក្នុងសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុសរុបចំនួន ០៧រូប (ប្រុស ០៦រូប, ស្រី ០១រូប)

- ប្រធានសាខា ០១រូប
- អនុប្រធានសាខា ០៥រូប
- ប្រធានការិយាល័យ ០១រូប





សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការវិនិយោគខេត្តព្រះសីហនុ ដើម្បីពិនិត្យ និងអនុម័តលើសំណើសុំនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ





សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយសភាពាណិជ្ជកម្មខេត្តព្រះសីហនុ ក្រោមអធិបតីភាព ឯកឧត្តម ម៉ាង ស៊ីណេត អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ




សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ចូលរួមវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ជំនាន់ថ្មី ជូនអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅ Rock Royal Hotel & Resort ខេត្តកែប






សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (កម្មវិធី វីដេអូ ZOOM)






សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ ចូលរួមកិច្ចប្រជុំពិភាក្សាការងារស្តីពីការអនុវត្តច្បាប់ ជាមួយប្រតិភូគណៈកម្មការនីតិកម្មនិងយុត្តិធម៌ នៃរដ្ឋសភា ក្រោមអធិបតីភាព ឯឧត្តម អង្គ វង្សវឌ្ឍនា ប្រធានគណៈកម្មការទី៦ នៃរដ្ឋសភា








ចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា នៅតាមទីតាំងអាជីវកម្មដ្ឋាន ស្ថានីយ៍ប្រេងឥន្ធនៈ និងឃ្លាំងលក់រថយន្ត សរុបចំនួន ៣៩ ទីតាំងស្ថិតក្នុងភូមិសាស្ត្រ ខេត្តព្រះសីហនុ ដោយយោងតាមលិខិតលេខ១២៧៩/២៤ អគរ ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារគយដល់សាធារណជន






សកម្មភាពមន្ត្រីរាជការគយនៃសាខាគយនិងរដ្ឋាករខេត្តព្រះសីហនុចូលរួមចុះពិនិត្យទីតាំងចំនួន ០៥គម្រោង ជាមួយក្រុមការងារ លើគម្រោងវិនិយោគ និងធុរកិច្ច ដែលបានស្នើការលើកទឹកចិត្ត និងការអនុគ្រោះ

# សាខាគយនិងរដ្ឋាករខេត្តព្រៃវែង

ក្នុងត្រីមាសទី៤ នៃឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងបណ្តាការិយាល័យគយនិងរដ្ឋាករក្រោមឱវាទបានអនុវត្តការងារគយនិងរដ្ឋាករសំខាន់ៗមួយចំនួនក្នុងការប្រមូលចំណូលដោយទទួលបានលទ្ធផលចំនួន ៩,៧១៦,៥២១,៩០០ រៀលគត់ ប្រៀបធៀបនឹងផែនការបានប្រមាណ ១០៧.៣៦% ដោយក្នុងនោះបានបង្ក្រាបទំនិញគេចវេះពន្ធនិងកសាងកំណត់ហេតុល្មើសច្បាប់គយចំនួន ២៣ ករណីដោយប្រមូលបានប្រាក់ពន្ធអាករនិងពិន័យសរុបចំនួន ៥០៧,៤២៨,៣០០ រៀលផងដែរ។ បន្ថែមលើការងារប្រមូលចំណូលសាខាគយនិងរដ្ឋាករខេត្តព្រៃវែងក៏បានបំពេញការងារផ្សេងៗមួយចំនួនដូចខាងក្រោម៖

១- នាថ្ងៃសុក្រ ៩រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ លោក **មួង ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងសហការី បានអមដំណើរលោក **ពេជ្រ សុត្ថារ័ត្ន** អភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង ជាប្រធានគណៈប្រតិភូ បានចូលរួមកិច្ចប្រជុំស្តីពីការពិភាក្សា ឯកភាពគ្នា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម រវាងខេត្តព្រៃវែង ប្រទេសកម្ពុជា និងខេត្តដុងថាប់ ប្រទេសវៀតណាម។

២- នាថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងសហការី បានអមដំណើរលោក **ពេជ្រ សុត្ថារ័ត្ន** អភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែងជាប្រធានគណៈប្រតិភូជួបពិភាក្សាជាមួយគណៈប្រតិភូខេត្តតៃនិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាមដើម្បីត្រៀមរៀបចំពិធីប្រកាសសម្ពោធច្រកទ្វារព្រំដែនអន្តរជាតិម៊ីនជ័យ-តឹនណាម។

៣- នាថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ លោកប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងសហការី បានអមដំណើរឯកឧត្តម **ជា ឧុទ្ធិ** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឯកឧត្តម **សួន សុម៉ាលីន** អភិបាលនៃគណៈអភិបាលខេត្តព្រៃវែងដែលបានចុះពិនិត្យមើលវឌ្ឍនភាពនៃការដ្ឋានសាងសង់ផែស្ងួត សុខាស៊ីណា រដ្ឋា (អេស.អេស.អ) ឯ.ក ដែលមានទីតាំងនៅភូមិត្បូងវត្ត ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

៤- នាថ្ងៃចន្ទ ៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ លោក **មួង ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងសហការីបានអមដំណើរឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិម៊ីនជ័យ(ខេត្តព្រៃវែង) តឹន ណាម (ខេត្តតៃនិញ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ផាម មិញជីញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

៥- នាថ្ងៃអង្គារ ៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តព្រៃវែងបានដឹកនាំប្រតិភូចូលរួមកិច្ចប្រជុំទ្វេភាគី ផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការគយ ឆ្នាំ២០២៥ រវាងសាខាគយនិងរដ្ឋាករខេត្តព្រៃវែង នៃព្រះរាជាណាចក្រកម្ពុជា និងសាខាគយតំបន់២០ សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលប្រព្រឹត្តទៅនៅសាខាគយតំបន់២០(ខេត្តដុងថាប់)នៃសាធារណរដ្ឋសង្គមនិយមវៀតណាមក្រោមការដឹកនាំប្រជុំរបស់លោក **ខៀន ថាញ់សាង** ប្រធានសាខាគយតំបន់២០ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងលោក **មួង ដារ៉ា** ប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង។

៦- អំឡុងខែធ្នូ ឆ្នាំ២០២៥ មន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងបណ្តាការិយាល័យគយនិងរដ្ឋាករបានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានានៅតាមអាជីវកម្មដ្ឋាន និងស្ថានីយ៍ប្រេងឥន្ធនៈមួយចំនួននៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង។




សកម្មភាពចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ (ខេត្តព្រៃវែង) - តឺន ណាម (ខេត្តតៃនិញ)



សកម្មភាពចូលរួមកិច្ចប្រជុំស្តីពីការពិភាក្សា ឯកភាពគ្នា និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម រវាងខេត្តព្រៃវែង ប្រទេសកម្ពុជា និងខេត្តដុងថាប់ ប្រទេសវៀតណាម



សកម្មភាពត្រៀមរៀបចំពិធីប្រកាសសម្ពោធច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ-តឺនណាម



សកម្មភាពចុះពិនិត្យមើលវឌ្ឍនភាពនៃការដ្ឋានសាងសង់ ផែស្ងួត សុខា ស៊ីណា រដ្ឋា (អេស.អេស.អ) ឯ.ក



សកម្មភាពចូលរួមកិច្ចប្រជុំទ្វេភាគី ផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការគយឆ្នាំ២០២៥ រវាងសាខាគយនិងរដ្ឋាករខេត្តព្រៃវែងនៃព្រះរាជាណាចក្រកម្ពុជា និងសាខាគយតំបន់២០ សាធារណរដ្ឋសង្គមនិយមវៀតណាម



សកម្មភាពចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានានៅតាមអាជីវកម្មដ្ឋាន និងស្ថានីយ៍ប្រេងឥន្ធនៈមួយចំនួននៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង

# សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម

ការគ្រប់គ្រងអនុវត្តការងារប្រមូលពន្ធ អាករនិងកម្រៃផ្សេងៗដែលបានបង់ចូលថវិកាជាតិគឺជាភារកិច្ចស្នូលរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ដោយឡែកសាខាគយនិងរដ្ឋាករខេត្តកំពង់ចាមដែលជាសេនាធិការបានរួមចំណែកយ៉ាងសកម្មបំផុត ក្នុងស្មារតីប្រុងប្រយ័ត្ននិងមានការទទួលខុសត្រូវខ្ពស់ស្របតាមជំនាញបច្ចេកទេសគយស្ថិតក្រោមកិច្ចខិតខំប្រឹងប្រែងពីថ្នាក់ដឹកនាំសាខាក៏ដូចជាមន្ត្រីក្រោមឱវាទ ដើម្បីជំរុញនិងពង្រឹងបន្ថែមនូវការងារប្រមូលពន្ធអាករឱ្យបានគ្រប់ផែនការដែលបានដាក់ចេញដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ជាលទ្ធផលក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ នេះ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាមប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗបានចំនួន១,៦៣៣,៣៧៥,៨០០រៀលស្មើនឹង១៤២.០៣% នៃផែនការប្រចាំត្រីមាសទី៤ ចំនួន ១,១៥០ លានរៀល ដោយលើសផែនការចំនួន៤៨៣,៣៧៥,៨០០រៀលស្មើនឹង ៤២.០៣%។ ចំណូលទាំងនេះបានមកពីការសីមីរ៉ឺម៉កបង់ពន្ធស្ម័គ្រចិត្តចំនួន ១៨៨ គ្រឿង។ ក្រៅពីការងារប្រមូលចំណូល មន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ចាមបានចូលសិក្ខាសាលាផ្សេងៗនៅសាលាជាតិគយផងដែរ។

នៅថ្ងៃទី២១ខែតុលា ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាមបានចាត់លោកស្រី **សោម ចាន់ឌី** ចូលរួមប្រជុំពិនិត្យ ផ្ទៀងផ្ទាត់ ផ្ទួរផ្ទង និងវាយតម្លៃលើការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ២០២៤ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកំពង់ចាម។

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ លោក **ប្រាក់ ចាន់ធី** ប្រធានសាខាគយនិងរដ្ឋាករខេត្តកំពង់ចាម បានចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមកម្មវិធី Zoom Meeting នៅសាលាខេត្តកំពង់ចាម ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង១៤ និង៣០នាទី នៅសាខាគយនិងរដ្ឋាករខេត្តកំពង់ចាមបានទទួលប្រតិភូ នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង កសហវ ដឹកនាំដោយលោក **ទត សុខុម** និងសមាជិកចុះមកធ្វើសវនកម្ម លើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដើម្បីលើកកម្ពស់ក៏ដូចជាតម្រង់ទិសសម្រាប់ការងារអនុវត្តកន្លងមកឲ្យមានប្រសិទ្ធភាពនៅក្នុងសាខាគយនិងរដ្ឋាករខេត្តកំពង់ចាម។



កិច្ចប្រជុំពិនិត្យ ផ្ទៀងផ្ទាត់ ផ្ទួរផ្ទង និង វាយតម្លៃលើការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ២០២៤




ចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមកម្មវិធី Zoom Meeting និងទទួលគណៈប្រតិភូ នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង កសហវ



សកម្មភាពចុះធ្វើអនុលោមភាពត្រួតពិនិត្យបរន្តទំនិញ នៅរោងចក្រ Enson International (Cambodia) Co.,LTD

# សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ

ក្រោមការដឹកនាំរបស់លោក **ឈួន ហៃ** ជាប្រធានសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តមានស្មារតីទទួលខុសត្រូវខ្ពស់ព្រមទាំងមន្ត្រីគយនិងរដ្ឋាករក្រោមឱវាទ បានរួមគ្នាប្រឹងប្រែងអនុវត្តការងារគ្រប់គ្រង ប្រមូលពន្ធអាករ និងកម្រៃផ្សេងៗបង់ចូលថវិកាជាតិដែលជាភារកិច្ចចាំបាច់របស់អង្គភាពចូលរួមយ៉ាងសកម្មបំផុតនៅក្នុងការអនុវត្តជំនាញបច្ចេកទេសគយប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ពង្រឹងការត្រួតពិនិត្យអនុលោមភាពកណ្ដាលទី ដើម្បីបង្ការ និងបង្ក្រាបអំពើរត់ពន្ធគ្រប់ប្រភេទ ព្រមទាំងទប់ស្កាត់រាល់បាតុភាពអសកម្មផ្សេងៗជាពិសេសការអនុវត្តតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

នៅត្រីមាសទី៤ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានប្រមូលចំណូលចំនួន ៨៤៩,៣៣២,៦០០រៀល បានមកពីការបង់ពន្ធ អាករ ពិន័យផ្សេងៗ ការបង្ក្រាបទៅលើពន្ធទំនិញគេចវេះពន្ធ ការបង់ពន្ធអាករលើរថយន្តក្នុងស្រុក ការបង់ពន្ធអាករលើសឺមីរ៉ឺម៉ក និងផលពីការលក់ទំនិញរឹបអូសគ្មានការទាមទារ ដែលមានការកើនឡើងប្រមាណ ១៣.៥៣% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៥។ បើប្រៀបធៀបនឹងផែនការចំណូលសម្រេចបានប្រមាណ ១៣០.៦៧% (ផែនការចំណូលប្រចាំត្រីមាសទី៤ ៦៥០លានរៀល)។

នៅក្នុងត្រីមាសទី៤ នេះ មន្ត្រីសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានបន្តប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូលប្រចាំឆ្នាំ២០២៥ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។ នៅពាក់កណ្ដាលត្រីមាសទី៤ នេះ មន្ត្រីសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧២ នៃទិវាបុណ្យឯករាជ្យជាតិ និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ២០២៥។ សម្រាប់ចុងត្រីមាសទី៤ សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺបានធ្វើការចុះអនុវត្តសេចក្ដីណែនាំស្ដីពីការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារគយដល់សាធារណជនដែលស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។



សកម្មភាពមន្ត្រីនៃសាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺចុះប្រមូលព័ត៌មានសូចនាករហានិភ័យមួយចំនួនពីប្រតិបត្តិករនាំចេញ-នាំចូលប្រចាំឆ្នាំ២០២៥ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ



សកម្មភាពត្រួតពិនិត្យរថយន្តដឹកទំនិញចរាចរណ៍តាមដងផ្លូវ

# សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ ដែលដឹកនាំដោយ លោក **លី សារឿន** បានជំរុញការអនុវត្តការងារសំខាន់ៗ ស្របតាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏ដូចជាការអនុវត្តតាមផែនការសកម្មភាពឆ្នាំ២០២៥ និងលិខិតបទដ្ឋានជាធរមាននានារបស់ **អគរ** ទទួលបានលទ្ធផលដូចខាងក្រោម៖

**១. ការងារប្រមូលចំណូល**

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ ប្រមូលចំណូលសរុបបានចំនួន ៣,៤៤៤,៩៣១,៥០០រៀល ស្មើនឹង ១១៤.៨៣% នៃផែនការចំណូលក្នុងត្រីមាសទី៤ ឆ្នាំ២០២៥នេះ។

**២. អនុលោមភាព និងការអនុវត្តច្បាប់**

-លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគយជូនដល់សាធារណជន ដោយបានចុះផ្សព្វផ្សាយនៅស្ថានីយឬដេប៉ូផលិតផលតេលសិលា អាជីវកម្មដ្ឋានលក់រថយន្ត និងអាជីវកម្មដ្ឋានទំនិញចម្រុះ ចំនួន ១០ទីតាំង

-ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបទំនិញល្មើសកម្មសិទ្ធិបញ្ញា និងទំនិញខូចគុណភាព ដោយបានបង្ក្រាបទោចក្រយានល្មើសកម្មសិទ្ធិបញ្ញាចំនួន ៧៧៥ករណី

-ស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធ អំពើបន្លំពន្ធ បទល្មើសគយផ្សេងទៀត និងការគេចវេះទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ ដោយបានបង្ក្រាបទំនិញចំនួន ០១ករណី និងទោចក្រយានយន្តចំនួន ០១ករណី។

**៣. ការអនុវត្តការងារផ្សេងៗ**

-បានចូលរួមប្រជុំបូកសរុបការងារគយនិងរដ្ឋាករប្រចាំខែនៅ **អគរ**

-បានចូលរួមប្រជុំផ្សព្វផ្សាយលិខិតនានារបស់ **អគរ**

-បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត និងក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តរៀងរាល់ខែ

-បានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់

-បានចូលរួមសហការល្អជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។



ប្រជុំផ្សព្វផ្សាយ និងការងារផ្ទៃក្នុងសាខា



ចូលរួមប្រជុំផ្សព្វផ្សាយលិខិតនានារបស់**អគរ**



ចូលរួមប្រជុំផ្សព្វផ្សាយលិខិតនានារបស់**អគរ**



ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ

# ការិយាល័យស្រាវជ្រាវនិងបង្រ្កាបអំពើរត់ពន្ធតំបន់១

ក្រោមការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់លោក **ឆ្អែន សុវណ្ណារ៉ា** ប្រធានការិយាល័យស្រាវជ្រាវនិងបង្រ្កាបអំពើរត់ពន្ធតំបន់១ ដោយអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការណែនាំផ្ទាល់របស់លោក **នូ ស៊ីថា** ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស រួមទាំងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់មន្ត្រីក្រោមឱវាទ ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់១ បានអនុវត្តភារកិច្ច និងសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរនៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ដែលមានដូចខាងក្រោម៖

## ការបង្ក្រាបនិងការប្រមូលចំណូល

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៥ ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធតំបន់១បង្ក្រាបទំនិញល្មើសបានចំនួន ២៨ករណីធំ និង ៨៨ករណីតូច ដែលមានមុខទំនិញសំខាន់ៗដូចជា រថយន្តទេសចរណ៍ ម៉ាស៊ីនត្រជាក់ ភេសជ្ជៈចម្រុះ គ្រឿងអេឡិចត្រូនិក ម៉ូតូ ម៉ូតូអគ្គិសនី រថយន្តអគ្គិសនី និងទំនិញចម្រុះផ្សេងទៀត ដែលសរុបចំណូលពន្ធនិងអាករ ព្រមទាំងពិន័យបានចំនួនសរុបប្រមាណ ៣,៤២១លានរៀល។

## សកម្មភាពការងារសំខាន់ៗ

១. លោកប្រធានការិយាល័យ បានចុះដឹកនាំដោយផ្ទាល់រួមទាំងបែងចែកកម្លាំងចុះស្រាវជ្រាវ ទប់ស្កាត់ បង្ការ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់ប្រភេទតាមឃ្លាំងស្តុកទំនិញ អាជីវកម្មដ្ឋាន និងរថយន្តដឹកទំនិញនានា ដោយបានចុះអនុលោមភាពឃ្លាំងស្តុកទំនិញបានចំនួន២៥ឃ្លាំង (បានផ្ទៀងផ្ទាត់ឃើញចំនួន ៩ទីតាំង មានអនុលោមភាពសមស្រប និង ១៦ទីតាំង មានអនុលោមភាពទាប) និងធ្វើអនុលោមភាពរថយន្តដឹកទំនិញ-យានយន្តបានចំនួន ១៩ករណី (បានផ្ទៀងផ្ទាត់ឃើញចំនួន ៧ករណី មានអនុលោមភាពសមស្រប និងចំនួន ១២ករណី មានអនុលោមភាពទាប)

២. ការិយាល័យបានសហការជាមួយ ១) "ក្រុមការងារចម្រុះ ដើម្បីត្រួតពិនិត្យកាតព្វកិច្ចបិទតែមប្រើអាករប្រភេទថ្មីសម្រាប់បារី" ដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ រួមជាមួយអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះបង្ក្រាបមុខសញ្ញាល្មើសចំនួន៣ទីតាំងនៅចំណុចភូមិសាស្ត្រខណ្ឌច្បារអំពៅ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ២) មន្ត្រីនៃនាយកដ្ឋានគយនិងរដ្ឋាកររាជធានីភ្នំពេញ និងមន្ត្រីនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ចុះត្រួតពិនិត្យ និងវាយតម្លៃគុណវុឌ្ឍិឃ្លាំងរក្សាទុកសាច់បង្កកចំនួន ៨ទីតាំង ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ៣) អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ, នគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច, អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីប្រមូលយកសាច់បង្កកដែលមានប្រភពមកពីប្រទេសថៃចំនួន ២ទីតាំង ទៅដុតកម្ទេចចោលនៅទីលានចាក់សំរាមដង្កោ ក្នុងភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

៣. មន្ត្រីនៃការិយាល័យ បានចូលរួមក្នុងវគ្គសិក្ខាសាលា និងកិច្ចប្រជុំនានាតាមការចាត់តាំងរបស់ **អគរ** សរុបបានចំនួន ៦លើកផងដែរ។






សកម្មភាពការងាររបស់ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើគេចពន្ធតំបន់១






សកម្មភាពចូលកិច្ចសហការ និងការងារផ្សេងៗ







សកម្មភាពចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល

# ផ្នែកទី៤

## ការងារសង្គម

# សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ក្រៅពីការងារស្នូលរបស់អង្គភាព ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏បានយកចិត្តទុកដាក់លើកិច្ចដំណើរការរបស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា **"ស.ស.ម.អ.គ.រ"** ។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានបង្កើតឡើងក្នុងខែមេសា ឆ្នាំ២០១៥ និងបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ៩៤៦ សជណ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានសមាជិកសកម្មជាមន្ត្រីរាជការគយនិងរដ្ឋាករ មានចំនួន ១,២៦០នាក់ ក្នុងនោះសមាជិកាចំនួន ១៩៩នាក់ និងសមាជិកជាមន្ត្រីបុគ្គលិកជាប់កិច្ចសន្យា មានចំនួន ១០៥នាក់ ក្នុងនោះសមាជិកាចំនួន ៤៥នាក់។ សមាគមនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកយកចិត្តទុកដាក់និងសម្រាលការលំបាក ជូនមន្ត្រីគយនិងរដ្ឋាករ រួមមាន ការសម្រាលមាតុភាព មរណភាព គ្រោះថ្នាក់ពេលបំពេញការងារ និងជំងឺតម្កាត់ផ្សេងៗ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករចូលនិវត្តន៍ផងដែរ។ ជាមួយគ្នានេះ សមាគមបានបង្កើតមូលនិធិសប្បុរសធម៌ និងបានបន្តរួមចំណែកផ្តល់ជំនួយគាំទ្រដែលរួមមានគ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ និងថវិកា សម្រាប់សម្រាលការលំបាកចំពោះ មណ្ឌលកុមារកំព្រា អង្គការចាស់ជរាសមាគម ក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនងាយរងគ្រោះមួយចំនួនទៀតផងដែរ។



សកម្មភាពប្រគល់ថវិកាជូនសមាជិក និងគ្រួសាររបស់សមាជិក នៃ "ស.ស.ម.អ.គ.រ"

# ការយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ជូនប្រជាពលរដ្ឋសរុបចំនួន ៣ ០០០ គ្រួសារ ដែលបានជម្លៀស ដោយសារសង្គ្រាមឈ្លានពានរបស់ថៃ មកកាន់ជំរុំជនភៀសសឹក ក្នុងស្រុកមួយចំនួននៃខេត្តសៀមរាប

នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួន បាននាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ជាគ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាមួយចំនួន ជូនប្រជាពលរដ្ឋសរុបចំនួន ៣ ០០០ គ្រួសារ ដែលបានជម្លៀសដោយសារសង្គ្រាមឈ្លានពានរបស់ថៃ មកកាន់ជំរុំជនភៀសសឹកក្នុងស្រុកមួយចំនួននៃខេត្តសៀមរាប ដោយមានការចូលរួមពីឯកឧត្តម **ប្រាក់ សោភ័ណ** អភិបាលនៃគណៈអភិបាល អភិបាលរង និងអាជ្ញាធរមូលដ្ឋាននៃខេត្តសៀមរាប។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** និងបានជម្រាបអំពីការយកចិត្តទុកដាក់ជាប់ជានិច្ចរបស់សម្តេចចំពោះបងប្អូនប្រជាពលរដ្ឋ ដែលកំពុងរងគ្រោះដោយសារអំពើឈ្លានពានយ៉ាងព្រៃផ្សៃរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា។ ឯកឧត្តមក៏បានគូសបញ្ជាក់ថា អំណោយទាំងនេះនឹងរួមចំណែកក្នុងការជួយសម្រាលបន្ទុកមួយផ្នែករបស់បងប្អូនប្រជាពលរដ្ឋក្នុងគ្រាដ៏លំបាកនេះ។

អំណោយសម្រាប់ចែកជូនប្រជាពលរដ្ឋភៀសសឹកនាពេលនេះ ជាគ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងថវិកា សរុបចំនួន ៣០០០កញ្ចប់ (Kits) ដែល ១កញ្ចប់សម្រាប់ ១គ្រួសារ សរុបរួមមាន ភួយ ៣០០០, មុង ៣ ០០០, សារ៉ុង ៣០០០, អាវរងា ៣០០០, ទឹកស៊ីអ៊ីវ ៦០០០ ដប, ត្រីខកំប៉ុង ១៥០កេស ស្មើនឹង ១៥ ០០០កំប៉ុង, ទឹកដោះគោខាប់ ៣១៣កេស ស្មើនឹង១៥០០០កំប៉ុង, ទឹកដោះគោស្រស់ (១កេស=១២យួរ, ១យួរ=១២កំប៉ុង) ២៥០កេស ស្មើនឹង ៣,០០០យួរ, កាហ្វេកញ្ចប់ ៣០,០០០កញ្ចប់តូច, ច្រាសដុសធ្មេញ-ថ្នាំដុសធ្មេញ (១ឈុត ច្រាសដុសធ្មេញ ២, ថ្នាំដុសធ្មេញ១) ៣០០០ឈុត, សាប៊ូដុសខ្លួន ៣ ០០០ដុំ, ម្សៅសាប៊ូ ៣ ០០០កញ្ចប់, សំឡីអនាម័យ ៣ ០០០ដុំ, ផ្លែប៉ូវផ្អែម ១ ៥០០ គីឡូក្រាម, ពងទាប្រៃស្ងោររួច ១៥ ០០០ គ្រាប់, ទឹកក្រូច ៦២៥កេស ស្មើនឹង ១៥ ០០០កំប៉ុង, អង្ករ ១៥តោន, មីកញ្ចប់ ៣ ០០០កេស, ទឹកសុទ្ធ 1.5L ចំនួន ១ ២៥០កេស ស្មើ ១៥ ០០០ដប និងថវិកា ១៥០លានរៀល (ក្នុង ១គ្រួសារ ៥០ ០០០រៀល)។

ស្របតាមការអំពាវនាវរបស់ប្រមុខរាជរដ្ឋាភិបាល រួមជាមួយនឹងស្មារតីរួមសាមគ្គី «ខ្មែរតែមួយ» សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាប្តេជ្ញានឹងនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត** ដើម្បីចែកជូនវីរកងទ័ពជួរមុខដែលកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហានក្នុងបុព្វហេតុការពារបូរណភាពទឹកដីប្រឆាំងនឹងការឈ្លានពានពីសំណាក់ប្រទេសថៃ ព្រមទាំងប្រជាពលរដ្ឋភៀសសឹកនៅតាមបណ្តាខេត្តផ្សេងទៀត ជាបន្តបន្ទាប់នាពេលខាងមុខ។


















# ការប្រគល់អំណោយជូនវីរកងទ័ពជួរមុខសមរភូមិ ទិសខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ

បន្ទាប់ពីបាននាំយកអំណោយទៅចែកជូនជនភៀសសឹក ចំនួន ៣០០០គ្រួសារ ដែលបានភៀសខ្លួនមកកាន់ទីសុវត្ថិភាពក្នុងស្រុកមួយចំនួននៃខេត្តសៀមរាបកាលពីដើមសប្តាហ៍នេះមក, នៅថ្ងៃសៅរ៍ ទី២០ ខែធ្នូ ឆ្នាំ២០២៥ នេះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួនបានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ដើម្បីប្រគល់ជូនដល់វីរកងទ័ពជួរមុខ ដែលកំពុងប្រយុទ្ធជាមួយទ័ពឈ្លានពានថៃក្នុងសមរភូមិតាមបណ្តោយព្រំដែនខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ ។ពិធីប្រគល់-ទទួលអំណោយនេះបានប្រព្រឹត្តទៅនៅក្នុងទីតាំងមួយកន្លែងក្នុងខេត្តកំពង់ធំ ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានថ្លែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅជូនដល់វីរកងទ័ពជួរមុខ ដែលកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហាន និងប្តូរផ្តាច់ ក្នុងបុព្វហេតុការការពារបូរណភាពទឹកដី និងអធិបតេយ្យភាពរបស់កម្ពុជាពីអំពើឈ្លានពានយ៉ាងកំរោលនិងព្រៃផ្សៃរបស់កងទ័ពថៃ។ ឯកឧត្តម ក៏បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់រួមសុខ រួមទុក្ខ និងគិតគូរជានិច្ចដល់វីរកងទ័ពជួរមុខ។

អំណោយទាំងអស់រួមមាន Power Bank និងបន្ទះសូឡាសម្រាប់សាកថ្ម ១២០ឈុត, ម៉ាសការពារផ្សែងពុល ១៥០០ឈុត (មានតម្រងបន្ថែមសម្រាប់ប្តូរម៉ាសការពារផ្សែងពុល ២៥២ដុំ), អង្ករ ៩តោន, ទឹកពិសារ ៦០០កេស, កញ្ចប់(Kits)ចំនួន៣០០០កញ្ចប់ដែលក្នុងមួយកញ្ចប់មាន នំទាហាន ៥កញ្ចប់, ត្រីខកំប៉ុង ២កំប៉ុង, មី ៥កញ្ចប់, បាយក្តាំង ២កញ្ចប់, អំបុក ២ដប, ពងទាប្រៃឆ្អិន ៣គ្រាប់, គ្រាប់ចន្ទី ២០០ក្រាម, ទឹកដោះគោស្រស់ ២ប្រអប់តូច, ទឹកដោះគោខាប់ ២កំប៉ុង, បារី ៥កញ្ចប់, កាហ្វេលាយស្រេច ៥កញ្ចប់, ខ្ទឹមស ១កញ្ចប់, ស្ករគ្រាប់VitaminC និងសូកូឡា ២កញ្ចប់, ថ្នាំបំបាត់ការឈឺចាប់ ២បន្ទះ, Berocca Vitamin C ១ដប និងថវិកាចំនួន ៣០លានរៀល ។

ក្នុងស្មារតីគាំទ្រ និងផ្សារភ្ជាប់រវាងសមរភូមិក្រោយជាមួយសមរភូមិមុខ និងក្នុងមនោសញ្ចេតនា និងទឹកចិត្តសប្បុរសធម៌ និងមនុស្សធម៌, សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នឹងបន្តនាំយកអំណោយ ដើម្បីចែកជូនវីរកងទ័ពជួរមុខដែលកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហានជាមួយចោរឈ្លានពានសៀមនៅសមរភូមិទិសផ្សេងទៀត ក៏ដូចជាប្រជាពលរដ្ឋភៀសសឹកនៅភូមិសាស្ត្រខេត្តមួយចំនួនជាបន្តទៀត ។


CAMBODIA









# ការរៀបចំកញ្ចប់អំណោយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិតត្រៀមយកផ្តល់ជូនវីរកងទ័ពជួរមុខ

នាថ្ងៃទី១៧, ១៩ និង២០ ខែធ្នូ ឆ្នាំ២០២៥ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង លោកជំទាវ **ប៉ាន់ ត្រារាប្រណី គុណ ញឹម** បានដឹកនាំមន្ត្រីគយនិងរដ្ឋាករ, បុគ្គលិកជាប់កិច្ចសន្យានៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាថ្នាក់ដឹកនាំនិងសមាជិក នៃសមាគមសង្គហមិត្តមន្ត្រីរាជការគយ ព្រមទាំងជើងសាគយ បន្តរៀបចំវេចខ្ចប់អំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** សម្រាប់ត្រៀមយកទៅផ្តល់ជូនវីរកងទ័ពជួរមុខដែលកំពុងឈរជើងប្រយុទ្ធយ៉ាងប្តូរផ្តាច់ ក្នុងបុព្វហេតុការពារបូរណភាពទឹកដីនៃព្រះរាជា ណាចក្រកម្ពុជា និងប្រជាពលរដ្ឋភៀសសឹក ដោយសារអំពើឈ្លានពានយ៉ាងកំរោលពីសំណាក់ប្រទេសថៃ។

អំណោយដែលរៀបចំក្នុងពេលនេះមានចំនួន៥០០០កញ្ចប់ សម្រាប់ផ្តល់ជូនដល់វីរកងទ័ពនៃកងពលធំអន្តរាគមន៍លេខ២, កងពលធំអន្តរាគមន៍លេខ៣, បញ្ជាការយោធភូមិភាគទី៤ និងបញ្ជាការយោធភូមិភាគទី៥ និងចំនួន៣ ៣០៣កញ្ចប់ សម្រាប់ផ្តល់ជូនបងប្អូនប្រជាពលរដ្ឋក្នុងជំរំជនភៀសសឹកចំនួន៤ ស្ថិតក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ, ក្រុងពោធិ៍សាត់ និងស្រុកក្រគរ ខេត្តពោធិ៍សាត់។ សម្ភារៈអំណោយសម្រាប់កងទ័ព រួមមានឈុតជុំផ្ទុកអគ្គិសនីនិងបន្ទះសូឡា (Power Station), ម៉ាសការពារផ្សែងពុល និងតម្រងសម្រាប់ប្តូរ, អង្ករ ទឹកសុទ្ធ និងកញ្ចប់(Kits)ជាអាហារឆ្អិនស្រេច ថ្នាំសង្កូវ និងវីតាមីនជំនួយកម្លាំងរួមមាននំកងទ័ព,អំបុក,ត្រីខកំប៉ុង,មី,បាយក្តាំង, ពងទាប, គ្រាប់ចន្ទី,ទឹកដោះគោស្រស់, ទឹកដោះគោខាប់, ទឹកតែកំប៉ុង,កាហ្វេ 3 in 1, បារី, វីតាមីន Berroca, ថ្នាំបំបាត់ការឈឺចាប់, ស្ករគ្រាប់វីតាមីន ហើយអំណោយសម្រាប់ប្រជាពលរដ្ឋភៀសសឹក រួមមាន អង្ករ, ទឹកសុទ្ធ, មីកញ្ចប់, និងកញ្ចប់(Kits)ជាសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងចំណីអាហាររួមមានភួយ, ទឹកស៊ីអ៊ីវ, ទឹកត្រី, ត្រីខកំប៉ុង, ទឹកដោះគោខាប់, ទឹកដោះគោស្រស់, កាហ្វេ 3 in 1, ប្រាសដុសធ្មេញថ្នាំដុសធ្មេញ,សាប៊ូដុសខ្លួន,សំឡីអនាម័យ, ផែប៉ូវផ្អែម, ទឹកក្រូច, និងសារុង។ ស្របតាមតម្រូវការជាក់ស្តែង និងក្នុងស្មារតីរួបរួមសាមគ្គី "ខ្មែរតែមួយ" សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាប្តេជ្ញានឹងបន្តរៀបចំអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត** ដើម្បីផ្តល់ជូនកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក នៅតាមគោលដៅផ្សេងៗជាបន្តបន្ទាប់ទៀត។










CAMBODIA





អំណោយ
ជូនប្រជាពលរដ្ឋភៀសសឹកពីការឈ្លានពានរបស់កងទ័ពសៀម
ទីទួលសុវត្ថិភាពបុងកាល់ ស្រុកបុងកាល់ ខេត្តឧត្តរមានជ័យ
ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦



ពិធី
សំណេះសំណាល-សួរសុខទុក្ខ និងចែកអំណោយ







# ការប្រគល់អំណោយជូនវីរកងទ័ពជួរមុខសមរភូមិខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

នាថ្ងៃអាទិត្យ ទី២១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួន បន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដើម្បីប្រគល់ជូនដល់វីរកងទ័ពជួរមុខ ដែលកំពុងតស៊ូប្រយុទ្ធប្រឆាំងការឈ្លានពានពីសំណាក់ប្រទេសថៃ ក្នុងសមរភូមិខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ ពិធីប្រគល់អំណោយនេះ បានប្រព្រឹត្តនៅទីតាំងមួយកន្លែងក្នុងខេត្តបាត់ដំបង ដោយមានការចូលរួមពីតំណាងអភិបាលខេត្ត និងតំណាងវីរកងទ័ពកម្ពុជាតាមគោលដៅនីមួយៗ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានថ្លែងនូវការគោរពដឹងគុណជូនដល់យុទ្ធជនទាំងអស់របស់កម្ពុជា ដែលកំពុងប្រយុទ្ធយ៉ាងអង់អាចក្លាហាននិងប្តូរផ្តាច់ ក្នុងបុព្វហេតុការពារបូរណភាពទឹកដី និងអធិបតេយ្យភាពតាមបណ្តោយព្រំដែន ប្រឆាំងនឹងអំពើឈ្លានពានដ៏ឃោរឃៅរបស់ប្រទេសថៃមកលើកម្ពុជា។ ឯកឧត្តមបណ្ឌិតបានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ និងគិតគូរជានិច្ចចំពោះសុខទុក្ខរបស់វីរកងទ័ពទាំងអស់។ ឯកឧត្តមបណ្ឌិតក៏បានបញ្ជាក់បន្ថែមថា ការនាំយកអំណោយមកនេះ បញ្ជាក់ពីស្មារតីគាំទ្រ និងការផ្សារភ្ជាប់រវាងសមរភូមិក្រោយជាមួយសមរភូមិមុខ និងឆ្លុះបញ្ចាំងពីសាមគ្គីភាពខ្មែរតែមួយ ដើម្បីយកជ័យជម្នះលើសត្រូវឈ្លានពាន និងនាំយកសុខសន្តិភាពជូនដល់ប្រទេសជាតិនិងប្រជាពលរដ្ឋរបស់យើង។

ជាការឆ្លើយតប តំណាងវីរកងទ័ពក៏បានថ្លែងអំណរគុណជូនដល់ឯកឧត្តម និងសមាជិកសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាទាំងអស់ ដែលចុះមកជួយឧបត្ថម្ភគាំទ្រទាន់ពេលវេលា ដល់កម្លាំងជួរមុខដែលកំពុងជាប់ដៃប្រយុទ្ធជាមួយសត្រូវឈ្លានពានហើយប្តេជ្ញាថានឹងលះបង់គ្រប់បែបយ៉ាងដើម្បីការពារបូរណភាពទឹកដីកម្ពុជាជាទីស្នេហានៃយើងទាំងអស់គ្នា ។

អំណោយសម្រាប់ប្រគល់ជូនវីរកងទ័ពនាឱកាសនេះ រួមមាន៖ ឧបករណ៍ផ្ទុកអគ្គិសនី និងបន្ទះសូឡាសម្រាប់សាកថ្ម ៨០ឈុត, ម៉ាសការពារផ្សែងពុល ១០០០ ឈុត (មានតម្រងបន្ថែមសម្រាប់ប្តូរម៉ាសការពារផ្សែងពុល ១៦៨ ដុំ), អង្ករ ៦តោន, ទឹកសុទ្ធ ៤០០កេស, កញ្ចប់ (Kits) ចំនួន ២០០០កញ្ចប់ ដែលក្នុង Kits នីមួយៗ មាន នំទាហាន ៥កញ្ចប់, ត្រីខ ២កំប៉ុង, មី ៥កញ្ចប់, បាយក្តាំង ២កញ្ចប់, អំបុក ២ដប, ពងទាប្រៃឆ្អិន ៣គ្រាប់, គ្រាប់ចន្ទី ២០០ក្រាម, ទឹកដោះគោស្រស់ ២ ប្រអប់តូច, ទឹកដោះគោខាប់ ២ កំប៉ុង, បារី ៥ កញ្ចប់, កាហ្វេលាយស្រេច ៥ កញ្ចប់, ខ្ទឹមស ១កញ្ចប់, ស្ករគ្រាប់ Vitamin C និងសូកូឡា ២កញ្ចប់, ថ្នាំបំបាត់ការឈឺចាប់ ២បន្ទះ, Berocca Vitamin C ១ដប និងថវិកា ៣០លានរៀល។

គួរបញ្ជាក់ថា សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានយកអំណោយឧបត្ថម្ភជូនវីរកងទ័ពកម្ពុជាតាមបណ្តាខេត្តជាប់ព្រំដែនជាមួយថៃជាច្រើនលើករួចមកហើយ ចាប់តាំងពីមានភាពតានតឹងនៅព្រំដែន។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្តេជ្ញាបន្តគាំទ្រដល់វីរកងទ័ពជាបន្តបន្ទាប់ទៀត ។


អំណោយ




អំណោយ


អំណោយ
CAMB
CAMB
CAMB


អំណោយ







# ការនាំយកអំណោយជូនដល់ប្រជាពលរដ្ឋក្នុងជំរំជនភៀសសឹក ក្នុងខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ

នាថ្ងៃអាទិត្យ ទី២១ ខែធ្នូ ឆ្នាំ២០២៥ បន្ទាប់ពីប្រគល់អំណោយដល់វីរកងទ័ពជួរមុខ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួន បានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដើម្បីប្រគល់ជូនប្រជាពលរដ្ឋភៀសសឹក ចំនួន ៣ ៣០៣គ្រួសារ ដែលនៅក្នុងខេត្តពោធិ៍សាត់ មានចំនួន ៨៨៣គ្រួសារ និងខេត្តបន្ទាយមានជ័យ មានចំនួន ២ ៤២០គ្រួសារ។ ពិធីប្រគល់អំណោយនេះ បានរៀបចំនៅជំរំជនភៀសសឹកចំនួន ៤ ទីតាំងផ្សេងគ្នា ក្នុងខេត្តទាំង ២ ដោយមានការសហការរៀបចំដោយអាជ្ញាធរមូលដ្ឋាន និងព្រះចៅអធិការវត្ត ក្នុងទីតាំងនីមួយៗ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ រួមសុខរួមទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋភៀសសឹកដែលរងគ្រោះដោយសារអំពើឈ្លានពានដ៏ព្រៃផ្សៃរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា។ ឯកឧត្តមបណ្ឌិតបានលើកឡើងថា អំណោយដែលបានយកមកជូននាពេលនេះ ឆ្លុះបញ្ចាំងពីស្មារតីសាមគ្គីភាពខ្មែរតែមួយ នៃប្រជាពលរដ្ឋទូទាំងប្រទេស ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល បាននិងកំពុងចូលរួមលះបង់ធនធាន និងកម្លាំងកាយចិត្ត ឧបត្ថម្ភជាថវិកា និងសម្ភារៈផ្សេងៗ ដើម្បីសម្រាលការលំបាករបស់ប្រជាពលរដ្ឋភៀសសឹក និងគ្រួសារវីរកងទ័ព ដែលបានជម្លៀសមកទីសុវត្ថិភាពដោយសារការឈ្លានពានរបស់ទាហានសៀម។ ឯកឧត្តមបណ្ឌិតក៏បានក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋក្នុងជំរំជនភៀសសឹកឱ្យយកចិត្តទុកដាក់រក្សាអនាម័យ ថែទាំសុខភាព បង្ការជំងឺតម្កាត់នានា និងសូមឱ្យបងប្អូនប្រជាពលរដ្ឋមានការអត់ធ្មត់ ដោយត្រូវជឿជាក់លើការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការស្វែងរកដំណោះស្រាយ ឈានទៅបញ្ចប់សង្គ្រាម និងនាំយកសុខសន្តិភាព ជូនដល់ប្រទេសជាតិនិងប្រជាពលរដ្ឋរបស់យើងនាពេលខាងមុខនេះ ហើយបងប្អូនអាចវិលត្រឡប់ទៅលំនៅដ្ឋាន ភូមិ ស្រុក រៀងៗខ្លួនវិញ។

អំណោយសម្រាប់ចែកជូននាឱកាសនេះ រួមមាន អង្ករ ១៦ ៥១៥គីឡូក្រាម, ទឹកសុទ្ធ ១ ៣៣២កេស, មីកញ្ចប់ ៣ ៣០៣កេស និងកញ្ចប់ (Kits) ចំនួន ៣ ៣០៣ (១កញ្ចប់សម្រាប់ ១គ្រួសារ) ដោយ ក្នុង Kits នីមួយៗ រួមមាន ភួយ ១, ទឹកស៊ីអ៊ីវ ២ដប, ទឹកត្រី ២ដប, ត្រីខ ៥កំប៉ុង, ទឹកដោះគោខាប់ ៥កំប៉ុង, ទឹកដោះគោស្រស់១យួរស្មើ ៤កំប៉ុង, កាហ្វេ ១០កញ្ចប់តូច, ច្រាសដុសធ្មេញ ២, ថ្នាំដុសធ្មេញ ១, សាប៊ូដុសខ្លួន ១ដុំ, ម្សៅសាប៊ូOra ១កញ្ចប់ស្មើ ១១០ក្រាម, សំឡីអនាម័យ ១ដុំ, ឆៃប៉ូវផ្អែម កន្លះគីឡូក្រាម, ទឹកក្រូច ៥កំប៉ុង, សារុង ១, អាវរងា ១, ស្ករស ១គីឡូក្រាម និងថវិកា ៥០ ០០០រៀល។ ឯកឧត្តមបណ្ឌិត ក៏ប្រគល់ថវិកាមួយចំនួនផងដែរជូនព្រះចៅអធិការវត្តអូរប្រាសាទ និងវត្តអញ្ចាញ សម្រាប់រួមចំណែក សម្រាលបន្ទុកចំណាយប្រចាំថ្ងៃក្នុងការរៀបចំទ្រទ្រង់ប្រជាពលរដ្ឋភៀសសឹកក្នុងវត្ត។

គួរបញ្ជាក់ថា សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក៏ធ្លាប់បានយកអំណោយឧបត្ថម្ភជូនជនភៀសសឹកជាច្រើនលើករួចមកហើយចាប់តាំងពីពេលមានការប៉ះទង្គិចគ្នាតាមព្រំដែនរវាងកងទ័ពកម្ពុជា និងថៃ។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្តេជ្ញាបន្តនាំយកជំនួយឧបត្ថម្ភសម្រាប់ជនភៀសសឹក តាមបណ្តាខេត្តនានាជាបន្តបន្ទាប់ទៀត។























# ការនាំយកអំណោយជូនដល់ប្រជាពលរដ្ឋភៀសសឹក ក្នុងស្រុកបូទុមសាគរ និងស្រុកកោះកុង ខេត្តកោះកុង

នាថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួន បានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដើម្បីប្រគល់ជូនប្រជាពលរដ្ឋភៀសសឹកក្នុងភូមិសាស្ត្រខេត្តកោះកុង ចំនួន ១ ៥២៦គ្រួសារ ក្នុងនោះស្រុកបូទុមសាគរ មានចំនួន ៦៤៧គ្រួសារ និងស្រុកកោះកុង មានចំនួន ៨៧៩គ្រួសារ។ ពិធីប្រគល់អំណោយនេះ បានរៀបចំនៅជំរំជនភៀសសឹកចំនួន ២ ទីតាំងផ្សេងគ្នា ដោយមានការចូលរួមពី លោកជំទាវ **ឈី វ៉ា** អភិបាលនៃគណៈអភិបាលខេត្តកោះកុង អាជ្ញាធរមូលដ្ឋាន នាយកសាលា និងព្រះចៅអធិការវត្ត តាមទីតាំងនីមួយៗ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ រួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋយើង ពិសេសបងប្អូនប្រជាពលរដ្ឋភៀសសឹក ដែលរងគ្រោះដោយសារអំពើឈ្លានពានដ៏ព្រៃផ្សៃរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា។ ឯកឧត្តមបណ្ឌិតបានបញ្ជាក់ថា រហូតមកដល់ពេលនេះ ការវាយប្រហារឈ្លានពានរបស់យោធាសៀមកាន់តែមានភាពសាហាវឃោរឃៅនិងកាន់តែចូលជ្រៅមកក្នុងដែនអធិបតេយ្យរបស់កម្ពុជា ដែលធ្វើឱ្យចំនួនប្រជាពលរដ្ឋភៀសសឹកមានការកើនឡើងយ៉ាងខ្លាំង។ ស្ថានភាពនេះ តម្រូវឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នាដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋភៀសសឹក និងរីកងទ័ពឱ្យកាន់តែសស្រាក់សស្រាំថែមទៀត។ ឯកឧត្តមបណ្ឌិតបានលើកឡើងថា អំណោយដែលបានយកមកជូននាពេលនេះ ឆ្លុះបញ្ចាំងពីស្មារតីសាមគ្គីភាពខ្មែរតែមួយរបស់ប្រជាពលរដ្ឋទូទាំងប្រទេស ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល បាននិងកំពុងចូលរួមជាកម្លាំងកាយចិត្ត ឧបត្ថម្ភជាថវិកា និងសម្ភារៈផ្សេងៗ ដើម្បីសម្រាលការលំបាករបស់ប្រជាពលរដ្ឋភៀសសឹក និងគ្រួសាររីកងទ័ពដែលបានជម្លៀសមកទីសុវត្ថិភាពដោយសារការឈ្លានពានដ៏កំរោល ឃោរឃៅ និងព្រៃផ្សៃពីទាហានសៀម។ ឯកឧត្តមបណ្ឌិត ក៏បានក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋក្នុងជំរំជនភៀសសឹក ឱ្យយកចិត្តទុកដាក់រក្សាអនាម័យ ថែទាំងសុខភាព បង្ការជំងឺតម្កាត់នានា និងសូមឱ្យបងប្អូនប្រជាពលរដ្ឋ មានភាពនឹងនរ និងកក់ក្តៅក្នុងចិត្ត ព្រោះថារាជរដ្ឋាភិបាល និងសប្បុរសជនទាំងអស់នឹងនៅរួមសុខរួមទុក្ខជាប់ជានិច្ច ដោយមិនបោះបង់បងប្អូនចោលឡើយ។ ទន្ទឹមនេះ បងប្អូនប្រជាពលរដ្ឋត្រូវមានការអត់ធ្មត់ និងជឿជាក់លើការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការស្វែងរកដំណោះស្រាយទាំងផ្លូវការទូត ផ្លូវច្បាប់ និងយោធា ដើម្បីការពារអាយុជីវិតប្រជាជន បូរណភាពទឹកដី និងឈានទៅបញ្ចប់សង្គ្រាម នាំយកសុខសន្តិភាពនាពេលខាងមុខនេះ ហើយបងប្អូនអាចវិលត្រឡប់ទៅលំនៅដ្ឋាន ភូមិស្រុក រៀងៗខ្លួនវិញ។

លោកជំទាវ **ឈី វ៉ា** អភិបាលនៃគណៈអភិបាលខេត្តកោះកុង បានថ្លែងអំណរគុណដល់ឯកឧត្តម និងសមាជិកសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាទាំងអស់ និងបានបញ្ជាក់ថា អំណោយដ៏ថ្លៃថ្លានេះ មិនត្រឹមតែចូលរួមចំណែកជួយដោះស្រាយជីវភាពប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្តល់កម្លាំងចិត្តដ៏ធំធេងដល់បងប្អូនប្រជាពលរដ្ឋភៀសសឹក ដែលបាននិងកំពុងរងផលប៉ះពាល់ទាំងផ្នែកសុវត្ថិភាព និងផ្នែកស្មារតីយ៉ាងធ្ងន់ធ្ងរ

ដោយសារសង្គ្រាមឈ្លានពាននេះ។

អំណោយសម្រាប់ចែកជូននាឱកាសនេះ រួមមាន អង្ករ ៧ ៦៣០គីឡូក្រាម, ទឹកសុទ្ធ ៦៣៦កេស, មីកញ្ចប់ ១ ៥២៦កេស និងកញ្ចប់ (Kits) ចំនួន ១ ៥២៦ (១កញ្ចប់សម្រាប់ ១គ្រួសារ) ដោយ ក្នុង Kits នីមួយៗ រួមមាន ភួយ ១, សារុង ១, អាវរងា ១, ទឹកស៊ីអ៊ីវ ១ដប, ទឹកត្រី ១ដប, ទឹកដោះគោខាប់ ៣កំប៉ុង, ទឹកដោះគោស្រស់ ១យួរ ស្មើ ៤កំប៉ុង, ទឹកក្រូច ៥កំប៉ុង, នំប៉័ងកញ្ចប់ ១ដុំ, ច្រាសដុសធ្មេញ ២, ថ្នាំដុសធ្មេញ ១, សាប៊ូដុសខ្លួន ១ដុំ, សំឡីអនាម័យ ១ដុំ, ម្សៅសាប៊ូ ២កញ្ចប់ ស្មើ ២៥០ក្រាម, បាយក្តាំង ២កញ្ចប់, សាច់ក្រក កន្លះគីឡូក្រាម, ផៃប៉ូវ កន្លះគីឡូក្រាម, ត្រីងៀត ២, ស្ករស ១គីឡូក្រាម និងថវិកា ៥០ ០០០រៀលក្នុង ១គ្រួសារ សរុបស្មើនឹង ៧៦ ៣០០ ០០០រៀល។ ឯកឧត្តមបណ្ឌិត ក៏បានប្រគល់ថវិកាមួយចំនួនផងដែរ ជូនរដ្ឋបាលស្រុកទាំងពីរ និងព្រះចៅអធិការវត្ត សម្រាប់រួមចំណែកសម្រាលបន្ទុកក្នុងការរៀបចំទីកន្លែងនិងការទ្រទ្រង់ប្រជាពលរដ្ឋភៀសសឹកក្នុងវត្ត។

គួរបញ្ជាក់ថា ចាប់តាំងពីពេលមានសង្គ្រាមឈ្លានពានពីសំណាក់យោធាសៀមមកលើកម្ពុជាជាលើកទី២ រហូតដល់ពេលនេះ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បាននាំយកសម្ភារៈឧបត្ថម្ភជូនវីរកងទ័ព ជួរមុខជាច្រើនលើក ព្រមទាំងផ្តល់អំណោយជូនប្រជាពលរដ្ឋភៀសសឹកដែលបានជម្លៀសមកទីសុវត្ថិភាពក្នុងខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង សរុបចំនួន ៧ ៨២៩គ្រួសារ រួចមកហើយ។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាប្តេជ្ញាបន្តនាំយកជំនួយឧបត្ថម្ភសម្រាប់ជនភៀសសឹកតាមបណ្តាខេត្តនានាជាបន្តបន្ទាប់ទៀត។
















KHEMRA








ក្រុមគ្រូពេទ្យមន្ទីរសុខាភិបាលខេត្ត







# ការប្រគល់អំណោយជូនវីរកងទ័ពជួរមុខសមរភូមិទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់

នាថ្ងៃពុធ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងថ្ងៃព្រហស្បតិ៍ ទី១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួនបានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដើម្បីប្រគល់ជូនដល់វីរកងទ័ពជួរមុខ ដែលកំពុងឈរជើងការពារបូរណភាពទឹកដី តាមបណ្តោយព្រំដែនកម្ពុជា-ថៃ ក្នុងសមរភូមិទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។ ពិធីប្រគល់អំណោយនេះបានប្រព្រឹត្តនៅទីតាំង ៣កន្លែងនៃខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ដោយមានការចូលរួមពីតំណាងវីរកងទ័ពកម្ពុជាតាមគោលដៅនីមួយៗ។

ក្នុងពេលប្រគល់អំណោយនោះ ឯកឧត្តមបណ្ឌិតបានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ និងគិតគូរចំពោះសុខទុក្ខរបស់វីរកងទ័ពទាំងអស់។ ឯកឧត្តមបណ្ឌិត **គុណ ញឹម** ក៏បានថ្លែងនូវការគោរពដឹងគុណចំពោះយុទ្ធជនទាំងអស់របស់កម្ពុជា ដែលបានបូជាសាច់ស្រស់ឈាមស្រស់ក្នុងបុព្វហេតុការពារបូរណភាពទឹកដី ប្រឆាំងនឹងអំពើឈ្លានពានដ៏ឃោរឃៅរបស់ប្រទេសថៃមកលើកម្ពុជា។ឯកឧត្តមបណ្ឌិតបានលើកឡើងថាសង្គ្រាមរយៈពេល២១ថ្ងៃនេះ កងទ័ពកម្ពុជាបានតស៊ូប្រយុទ្ធយ៉ាងស្វិតស្វាញក្រាញនៀល ប្រឆាំងនឹងកងទ័ពសៀមដែលបានបើកការវាយប្រហារយ៉ាងសន្ធាប់ដោយមិនរើសអើងចូលក្នុងដែនអធិបតេយ្យរបស់កម្ពុជាដែលបានធ្វើឱ្យបាត់បង់អាយុជីវិតពលរដ្ឋស្លូតត្រង់ និងខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផ្ទះសម្បែងប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើន ព្រមទាំងបានបំផ្លិចបំផ្លាញប្រាសាទបុរាណ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។ ថ្វីត្បិតពេលនេះការប្រយុទ្ធគ្នាមានភាពស្ងប់ស្ងាត់ដែលជាលទ្ធផលនៃការចរចាបទឈប់បាញ់ ប៉ុន្តែវីរកងទ័ពកម្ពុជាក៏នៅតែបន្តឈរជើងយ៉ាងអង់អាច ប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ដែលតម្រូវឱ្យយើងទាំងអស់គ្នានៅសមរភូមិក្រោយ ត្រូវតែបន្តរួមគ្នាគាំទ្រនិងឧបត្ថម្ភទាំងសម្ភារៈនិងស្មារតី។ ការនាំយកអំណោយមកនេះ បញ្ជាក់ពីស្មារតីគាំទ្រ និងការផ្សារភ្ជាប់គ្នាជានិច្ចរវាងសមរភូមិក្រោយជាមួយសមរភូមិមុខ ហើយឆ្លុះបញ្ចាំងពីសាមគ្គីភាពខ្មែរតែមួយដើម្បីប្រយុទ្ធប្រឆាំងសត្រូវឈ្លានពាន ការពារបូរណភាពទឹកដី និងរក្សាសុខសន្តិភាព ជូនជាតិនិងប្រជាពលរដ្ឋរបស់យើង។

ជាការឆ្លើយតប តំណាងវីរកងទ័ព ក៏បានថ្លែងអំណរគុណ ជូនដល់ឯកឧត្តម និងសមាជិកសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាទាំងអស់ ដែលតែងតែចុះមកជួយឧបត្ថម្ភគាំទ្រជាប្រចាំដល់កម្លាំងជួរមុខដែលកំពុងឈរជើងនៅតាមបណ្តោយព្រំដែន ហើយប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការតស៊ូការពារបូរណភាពទឹកដីកម្ពុជាមិនឱ្យបាត់បង់ជាដាច់ខាត ក្រោមការដឹកនាំដ៏វៃឆ្លាតនិងស្វាហាប់របស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និង សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។

អំណោយសម្រាប់ប្រគល់ជូនវីរកងទ័ពនាឱកាសនេះ រួមមាន៖ ឧបករណ៍ផ្ទុកអគ្គិសនី និងបន្ទះសូឡាសម្រាប់សាកថ្ម ៤៤ឈុត, ម៉ាសការពារផ្សែងពុល ២០០០ឈុត, តម្រងបន្ថែមសម្រាប់ប្តូរម៉ាសការពារផ្សែងពុល ៤កេស ស្មើ ៥០០គូ, អង្ករ ១២តោន, ទឹកសុទ្ធ ៨០០កេស, កញ្ចប់ Kits ចំនួន ២៨០០កញ្ចប់ (ក្នុង Kits នីមួយៗ

មាន នំទាហាន ៥កញ្ចប់, មី ១០កញ្ចប់, ត្រីងៀតចម្អិនរួច ១កន្ទុយ, សាច់ក្រកចម្អិនរួច ៥ដុំ, ត្រីខ ២កំប៉ុង, បាយក្តាំង ២កញ្ចប់, អំបុក ២ដប, ពងទាប្រៃ ៤គ្រាប់, គ្រាប់ចន្ទី ២០០ក្រាម, ទឹកដោះគោស្រស់ ១យួរ ស្មើ ៤ ប្រអប់តូច, ទឹកដោះគោខាប់ ២កំប៉ុង,  ទឹកក្រូច ៣កំប៉ុង, បារី ១០កញ្ចប់, ថ្នាំ Vitamin Berocca ១ទីប, ថ្នាំបំបាត់ការឈឺចាប់ ២បន្ទះ, កាហ្វេ ១០កញ្ចប់, ស្ករចាហួយ ២កញ្ចប់តូច) និងថវិកា ៤០លានរៀល។ ក្រៅពីនេះ ក៏មានការប្រគល់នូវរថយន្តចំនួន ៧គ្រឿង និងទោចក្រយានយន្ត ចំនួន ៧គ្រឿង ដល់យោធភូមិភាគទី៥ ដែលមាន អង្គភាពកងទ័ពប្រចាំសមរភូមិទិសខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យផងដែរ ។

បន្ថែមលើការប្រគល់អំណោយដោយផ្ទាល់ជូនវីរកងទ័ព ឯកឧត្តមបណ្ឌិត **គុណ ញឹម** ក្នុងនាមសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក៏បានប្រគល់អំណោយមួយចំនួនជូនលោក **ឈុន វ៉ាន់ឌី** ដែលជាសកម្មជនស្ម័គ្រចិត្តក្នុងការដឹកជញ្ជូនស្បៀងនិងសម្ភារៈនានាទៅចែកជូនវីរកងទ័ពជួរមុខដល់ទីតាំងកៀកជិតនឹងសមរភូមិប្រយុទ្ធតែម្តង។ អំណោយទាំងនោះ រួមមាន៖ មី ១០០កេស, ទឹកសុទ្ធ ១០០កេស, អង្ករ ៥០០គីឡូក្រាម, កញ្ចប់ Kits ចំនួន ១០០កញ្ចប់ និងថវិកា ៤លានរៀល។

គួរបញ្ជាក់ថា កន្លងមកសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាធ្លាប់បានយកអំណោយជាគ្រឿងឧបភោគបរិភោគនិងសម្ភារៈនានាជូនដល់វីរកងទ័ពជួរមុខកម្ពុជា ក៏ដូចជាជូនដល់ប្រជាពលរដ្ឋភៀសសឹកជាច្រើនលើករួចមកហើយ ចាប់តាំងពីមានភាពតានតឹង និងការប៉ះទង្គិចគ្នាជាមួយយោធាសៀម។ លើសពីនេះ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ សមាគមក៏បាននាំយករថយន្តចំនួន ១៥គ្រឿង និងទោចក្រយានយន្ត ចំនួន ២១ គ្រឿង ប្រគល់ជូនអង្គភាពកងទ័ពប្រចាំសមរភូមិទិសខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យផងដែរ។ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្តេជ្ញាបន្តនាំយកនូវអំណោយដើម្បីឧបត្ថម្ភជូនវីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក ជាបន្តបន្ទាប់ទៀតនាពេលខាងមុខ។







អំណោយសម្តេចបវរធិបតី
ហ៊ុន ម៉ាណែត និងលោកជំទាវ
DC INPUT
AC OUT 200W
LED
DC OUT












អំណោយ









# ការនាំយកអំណោយជូនដល់ប្រជាពលរដ្ឋភៀសសឹក ក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ

នាថ្ងៃសុក្រ ទី៩ និងថ្ងៃសៅរ៍ ទី១០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីគយនិងរដ្ឋាករមួយចំនួន បានបន្តនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដើម្បីប្រគល់ជូនប្រជាពលរដ្ឋភៀសសឹកចំនួន ២ ២៨៥ គ្រួសារ ក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ពិធីប្រគល់អំណោយក្នុងខេត្តព្រះវិហារ ប្រព្រឹត្តទៅនៅទីតាំងជំរំជនភៀសសឹក ២ កន្លែង គឺវត្តគីឡូលេខ៨ និងវត្តត្រាវគៀត ដែលមានប្រជាពលរដ្ឋចំនួន ១ ២២៧គ្រួសារ និងមានការចូលរួមពី ឯកឧត្តម **គីម រិទ្ធី** អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ អាជ្ញាធរមូលដ្ឋាន និងព្រះចៅអធិការវត្តតាមទីតាំងនីមួយៗ។ ដោយឡែក ពីធីប្រគល់អំណោយក្នុងខេត្តឧត្តរមានជ័យ ប្រព្រឹត្តទៅនៅទីទួលសុវត្ថិភាព "ចុងកាល" ស្រុកចុងកាល ដែលមានប្រជាពលរដ្ឋចំនួន១០៥៨ គ្រួសារ និងមានការចូលរួមពីឯកឧត្តម **មាន ចាន់យ៉ាដា** អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងអាជ្ញាធរមូលដ្ឋាន។

ឯកឧត្តមអភិបាលខេត្តទាំង ២ បានលើកឡើងថា ក្នុងពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋភៀសសឹកមួយចំនួនដែលរស់នៅក្នុងតំបន់ស ជាតំបន់មានសុវត្ថិភាព បានវិលត្រឡប់ទៅគេហដ្ឋានវិញជាបណ្តើរៗហើយ។ ប៉ុន្តែចំពោះប្រជាពលរដ្ឋភៀសសឹកផ្សេងទៀត ដែលរស់នៅក្នុងតំបន់លឿង និងតំបន់ក្រហម នៅមិនទាន់អាចត្រឡប់ទៅវិញបាននៅឡើយ ត្រូវរង់ចាំអាជ្ញាធរធ្វើការបោសសម្អាតអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះឱ្យបានរួចរាល់ជាមុនសិន។ ក្នុងពេលនេះ អាជ្ញាធរខេត្តក៏កំពុងខិតខំខ្នែងក្នុងការរៀបចំស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនានា រួមមាន ផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យជាដើម ដែលរងការខូចខាតក្នុងពេលប្រយុទ្ធគ្នា ។ ដោយឡែក ចំពោះប្រជាពលរដ្ឋភៀសសឹកដែលរស់នៅតំបន់ក្រហម រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាននឹងរៀបចំឱ្យមានកន្លែងស្នាក់នៅសមរម្យបន្តទៀត។

ឯកឧត្តមអភិបាលខេត្តទាំង ២ បានថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិតនិងសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលបានយកអំណោយចូលរួមចំណែកសម្រាលបន្ទុករបស់ប្រជាពលរដ្ឋភៀសសឹក ដែលកំពុងរងផលប៉ះពាល់ទាំងផ្នែកជីវភាព និងស្មារតី ដោយសារសង្គ្រាមឈ្លានពានដ៏កំរោលរបស់ថៃមកលើកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** បានពាំនាំនូវការសាកសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**, សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ គិតគូរពីសុខទុក្ខរបស់ប្រជាពលរដ្ឋទាំងអស់។ ឯកឧត្តមបណ្ឌិត បានលើកឡើងអំពីការលំបាកដែលបងប្អូនជនភៀសសឹកជួបប្រទះមានដូចជា ការខូចខាតឬបាត់បង់ផ្ទះសំបែង ទ្រព្យសម្បត្តិ ការខកខានមិនបានប្រកបរបរចិញ្ចឹមជីវិត កូនចៅមិនបានទៅសាលារៀន ជាពិសេសគ្រួសារអ្នកមានជំងឺ ស្ត្រីមានផ្ទៃពោះ និងគ្រួសារមានកូនតូច កាន់តែមានការលំបាកថែមទៀត។ ឯកឧត្តមបណ្ឌិត បានបញ្ជាក់ថា អំណោយដែលបានយកមកជូននាពេលនេះ គឺស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ដែលតែងតែគិតគូរដល់សុខទុក្ខរបស់ប្រជាពលរដ្ឋភៀសសឹក ហើយចលនានៃការចូលរួមផ្តល់ជំនួយនេះ បង្ហាញនូវស្មារតីសាមគ្គីភាពខ្មែរជួយខ្មែរក្នុងគ្រាលំបាក។ ឯកឧត្តមបណ្ឌិត ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ដល់រដ្ឋបាលខេត្ត និងអាជ្ញាធរពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងរៀបចំ

ហេដ្ឋារចនាសម្ព័ន្ធ និងសេវាចាំបាច់នានា ដូចជាតង់ស្នាក់នៅ បន្ទប់អនាម័យ ប្រព័ន្ធចំពោះទឹកស្អាត ក្រុមគ្រូពេទ្យសង្គ្រោះបឋម និងកន្លែងរៀនបណ្តោះអាសន្ន ដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋភៀសសឹក។

ឯកឧត្តមបណ្ឌិត ក៏បានណែនាំឱ្យបងប្អូនជនភៀសសឹក ត្រូវមានការអត់ធ្មត់ និងត្រូវជឿជាក់លើការដឹកនាំដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការស្វែងរកសន្តិភាព ការបោសសម្អាតអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឱ្យបងប្អូនអាចត្រឡប់ទៅរស់នៅប្រកបដោយសុវត្ថិភាព។ ឯកឧត្តមបណ្ឌិត ក៏បានក្រើនរំលឹកឱ្យមានការយកចិត្តទុកដាក់រក្សាអនាម័យ ថែទាំសុខភាព ជាពិសេសក្នុងរដូវរងានេះ និងសូមមានភាពកក់ក្តៅក្នុងចិត្តថា ទាំងរាជរដ្ឋាភិបាល និងសប្បុរសជនទូទាំងប្រទេសនឹងនៅរួមសុខរួមទុក្ខជាប់ជានិច្ច ដោយមិនបោះបង់ពួកគាត់ចោលឡើយ។ បន្ថែមពីនេះ ពេលត្រឡប់ទៅវិញនាពេលខាងមុខ ត្រូវមានការប្រុងប្រយ័ត្នផ្នែកសុវត្ថិភាព ទាំងពេលធ្វើដំណើរតាមដងផ្លូវ និងក្នុងពេលរស់នៅក្នុងភូមិស្រុករបស់ខ្លួនដើម្បីបង្ការពីគ្រោះថ្នាក់ជាយថាហេតុ។ ក្នុងករណីមានការសង្ស័យឬជួបប្រទះអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមូលដ្ឋានដើម្បីចាត់វិធានការដោះស្រាយ។

អំណោយសម្រាប់ចែកជូនគ្រួសារជនភៀសសឹកនាឱកាសនេះ រួមមាន អង្ករ ១១ ៤២៥គីឡូក្រាម, ទឹកសុទ្ធ ៩៥៣កេស, មីកញ្ចប់ ២ ២៨៥កេស និងកញ្ចប់ (Kits) ចំនួន ២ ២៨៥ (១កញ្ចប់សម្រាប់ ១គ្រួសារ) ដោយក្នុង Kits នីមួយៗ រួមមានត្រីខ ៤កំប៉ុង, សាច់ជ្រូកផាត់ ១កញ្ចប់ស្មើ ២៥៩ក្រាម, ទឹកស៊ីអ៊ីវ ១ដប, ទឹកត្រី ១ដប, ទឹកដោះគោខាប់ ៣កំប៉ុង, ទឹកដោះគោស្រស់ ១យួរ ស្មើ ៤កំប៉ុង, ទឹកក្រូចឬតែក្រូចឆ្មារ ២កំប៉ុង, កាហ្វេ ១០កញ្ចប់តូច, នំស្រួយ ១កញ្ចប់ធំ, បាយក្តាំង ២កញ្ចប់, ស្ករស ១គីឡូក្រាម, ច្រាសដុសធ្មេញ ២, ថ្នាំដុសធ្មេញ ១, សាប៊ូដុសខ្លួន ១ដុំ, សំឡីអនាម័យ ១ដុំ, សាប៊ូម្សៅ 250g ១កញ្ចប់ ឬសាប៊ូម៉ាក ORA 110g ២កញ្ចប់តូច, សារុង ១។ ក្រៅពីនេះ ក៏មានកញ្ចប់ (Kits) ដោយឡែកសម្រាប់ស្ត្រីមានផ្ទៃពោះនិងអ្នកមានក្មេងតូច ចំនួន ១០១ កញ្ចប់ដោយក្នុង Kits នីមួយៗ រួមមាន នំ, ទឹកដោះគោ, សម្លៀកបំពាក់ និងសម្ភារៈក្មេងលេង។ ឯកឧត្តមបណ្ឌិត ក៏បានផ្តល់ថវិកាសម្រាប់គ្រួសារប្រជាពលរដ្ឋភៀសសឹក ដោយក្នុង ១គ្រួសារ ទទួល ៥០ ០០០រៀល និង ថវិកាមួយចំនួនផ្សេងទៀតដល់រដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធ និងបច្ច័យកសាងវត្តផងដែរ។

គួរបញ្ជាក់ថា ចាប់តាំងពីពេលមានសង្គ្រាមឈ្លានពានពីសំណាក់យោធាសៀមមកលើកម្ពុជា កាលពីដើមខែធ្នូ ឆ្នាំ២០២៥ កន្លងមកនេះ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បាននាំយកអំណោយឧបត្ថម្ភជូនកងទ័ពជួរមុខជាបន្តបន្ទាប់ និងអំណោយជូនប្រជាពលរដ្ឋភៀសសឹក សរុបចំនួន ១០ ១១៤គ្រួសារ ដែលបានជម្លៀសមកទីសុវត្ថិភាពនានាក្នុងខេត្តសៀមរាប, ខេត្តបន្ទាយមានជ័យ, ខេត្តពោធិ៍សាត់, ខេត្តកោះកុង, ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ដោយមើលឃើញពីស្ថានភាពដែលបងប្អូនជនភៀសសឹកមួយចំនួននៅមិនទាន់អាចត្រឡប់ទៅវិញបាននៅឡើយ សមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្តេជ្ញានឹងបន្តនាំយកជំនួយឧបត្ថម្ភបន្ថែមទៀត នាពេលខាងមុខ។
















# ការជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌របស់សមាគមសង្គហមិត្តមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រគល់ជូនសមាគមស៊ីក្លូកម្ពុជា និងអ្នកប្រកបរបរធាក់ស៊ីក្លូ

នាព្រឹកថ្ងៃសៅរ៍ ១១កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីលានដីអេលីហ្សេ នៃមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ, លោកអគ្គនាយករង **សែ សុឃន** តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងជាប្រធានសមាគមសង្គហមិត្តមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, បានដឹកនាំក្រុមការងារសប្បុរសធម៌ ជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌របស់សមាគមសង្គហមិត្ត ប្រគល់ជូនសមាគមស៊ីក្លូកម្ពុជា និងអ្នកប្រកបរបរធាក់ស៊ីក្លូចំនួន ១២០នាក់។ មានមតិក្នុងឱកាសនោះ លោកអគ្គនាយករង **សែ សុឃន** បានសម្តែងសេចក្តីរីករាយដែលបានជួបជាថ្មីម្តងទៀតជាមួយអ្នកធាក់ស៊ីក្លូទាំងអស់ និងបានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ ឯកឧត្តមបណ្ឌិត **គុណ ញឹម** និងលោកជំទាវ **ប៉ាន់ ត្រាប្រណី គុណ ញឹម** ផងដែរ។ លោកអគ្គនាយករងបានលើកឡើងពីសារតានិងតួនាទីរបស់ស៊ីក្លូ ជាយានជំនិះបែបប្រពៃណីនិងប្រវត្តិសាស្ត្រ ដែលបានបម្រើឱ្យវិស័យដឹកជញ្ជូនជាយូរឆ្នាំ ហើយចុងក្រោយនេះ មានតួនាទីបន្ថែមក្នុងវិស័យទេសចរណ៍។ ដោយពិនិត្យឃើញការលំបាករបស់អ្នកធាក់ស៊ីក្លូដែលបណ្តាលមកពីការប្រកួតប្រជែងជាមួយនឹងយានជំនិះសម័យទំនើប,រាជរដ្ឋាភិបាលបានបង្កើត "មូលនិធិត្រីចក្រយានយន្ត ឬមូលនិធិស៊ីក្លូ" ចាប់តាំងពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន និងបានក្លាយជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គម ដើម្បីជួយសម្រាលការលំបាករបស់ប្រជាពលរដ្ឋជាអ្នកប្រកបរបរធាក់ស៊ីក្លូ ស្របតាមគោលនយោបាយជាតិគាំពារសង្គម ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយភាពស្វាហាប់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លោកអគ្គនាយករងក៏បានជម្រាបអំពីព្រឹត្តិការណ៍ថ្មីៗពាក់ព័ន្ធនឹងបញ្ហាព្រំដែន ដោយគូសរំលេចនូវសមត្ថភាព និងយុទ្ធសាស្ត្រដ៏ប៉ិនប្រសប់ "ស្ងាត់តែមិនស្ងៀម" របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី ក្នុងការសម្រេចបាននូវសន្តិភាព តាមរយៈសេចក្តីប្រកាសរួមរវាងកម្ពុជានិងថៃ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ នាទីក្រុងគូឡាឡាំពួរ ដោយមានការជួយជ្រោមជ្រែង និងសម្របសម្រួលពីសហរដ្ឋអាម៉េរិក និងម៉ាឡេស៊ី ។ ដើម្បីរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល សមាគមសង្គហមិត្តមន្ត្រីរាជការគយនិងរដ្ឋាករតែងបានរៀបចំកម្មវិធីសប្បុរសធម៌ជារៀងរាល់ឆ្នាំ ដើម្បីជួយសម្រាលការលំបាករបស់កុមារកំព្រា ជនងាយរងគ្រោះផ្សេងៗ និងអ្នកធាក់ស៊ីក្លូ ដែលគិតមកដល់ពេលនេះ គឺជាកម្មវិធីឆ្នាំទី៦។ សម្រាប់អំណោយសប្បុរសធម៌ដែលបានប្រគល់ជូនអ្នកធាក់ស៊ីក្លូម្នាក់ៗនាពេលនេះ រួមមាន មីជាតិ ១កេស, ត្រីខកំប៉ុង ១យួរ, ភេសជ្ជៈ ១កេស, អាហារសម្រន់ ១ប្រអប់ និងថវិកាមួយចំនួន។ជំនួសមុខឱ្យអ្នកប្រកបរបរធាក់ស៊ីក្លូទាំងអស់ លោកស្រី **ឡុង សុខហ៊ួយ** ប្រធានសមាគមស៊ីក្លូកម្ពុជា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ឯកឧត្តមបណ្ឌិត **គុណ ញឹម** និងលោកជំទាវ **ប៉ាន់ ត្រាប្រណី គុណ ញឹម** ព្រមទាំងសហការីទាំងអស់ ដែលតែងផ្តល់ការឧបត្ថម្ភគាំទ្រជាប្រចាំដល់អ្នកប្រកបរបរធាក់ស៊ីក្លូ ដើម្បីលើកទឹកចិត្ត និងអភិរក្សស៊ីក្លូនៅកម្ពុជាឱ្យមានវត្តមានយូរអង្វែងតទៅមុខ៕


























ប្រវត្តិរដ្ឋបាលគយកម្ពុជាវីដេអូ

គេហទំព័ររដ្ឋបាលគយកម្ពុជា

អាសយដ្ឋាន : លេខ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥)២៣ ២១៤ ០៦៥

អ៊ីម៉ែល : info-pru@customs.gov.kh

គេហទំព័រ : www.customs.gov.kh

Facebook : អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា